# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ២០២២ - ២០២៦

ខែមេសា ឆ្នាំ ២០២២

ឧបត្ថម្ភដោយៈ កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្ម កម្ពុជា-អូស្ត្រាលី (កាវ៉ាក់)

Australian Aid

CAVAC Innovation in Agriculture

# មាតិកា

**បុព្វកថា** ..... i

**សេចក្តីថ្លែងអំណរគុណ** ..... ii

**សាវតានៃគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ** ..... ១

១. **ទិដ្ឋភាពទូទៅ៖ ទស្សនៈវិស័យយេនឌ័រនៅកម្ពុជា** ..... ២

២. **យេនឌ័រ និងកសិកម្ម** ..... ៣

ទិដ្ឋភាពទូទៅ ..... ៣

និន្នាការថ្មី ឱកាស និងហានិភ័យ ..... ៥

ផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ..... ៥

ការប្រែប្រួលអាកាសធាតុ ..... ៦

ស្ត្រីនិងការទទួលបាននូវឧបករណ៍ និងបច្ចេកវិទ្យាឌីជីថល ..... ៧

ចំណាកស្រុក ..... ៧

ការមើលឃើញ ការទទួលស្គាល់ និងតួនាទីរបស់ស្ត្រីក្នុងការសម្រេចចិត្តក្នុងវិស័យកសិកម្ម ..... ៨

ស្ត្រីនៅក្នុងការធ្វើកសិកម្ម និងនេសាទរួមគ្នា ..... ៨

តំណាងស្ត្រីនៅក្នុងរដ្ឋបាលកសិកម្ម ..... ៩

លទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាកម្មផ្សព្វផ្សាយកសិកម្ម និងការបណ្តុះបណ្តាល ..... ៩

យេនឌ័រ សេវាហិរញ្ញវត្ថុ និងបំណុល ..... ១០

យេនឌ័រ និងលទ្ធភាពទទួលបានដីធ្លី ..... ១១

យេនឌ័រ និងលទ្ធភាពទីផ្សារ ..... ១២

យេនឌ័រ និងអនុវិស័យកសិកម្ម ..... ១៣

យេនឌ័រ និងផលិតកម្មដំណាំ ..... ១៣

យេនឌ័រ និងព្រៃឈើ ..... ១៣

យេនឌ័រ និងផលិតកម្មកៅស៊ូ ..... ១៤

យេនឌ័រ និងផលិតកម្មសត្វ ..... ១៥

យេនឌ័រ និងជលផល ..... ១៥

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ..... ១៦

៣. **សមិទ្ធិផលនៃការអនុវត្តគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឆ្នាំ ២០១៦ - ២០២០** ..... ១៧

៤. **គោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឆ្នាំ ២០២២ - ២០២៦** ..... ១៩

៥. **ការតាមដាន និងវាយតម្លៃ** ..... ២១

**ឧបសម្ព័ន្ធទី១៖ ការប៉ាន់ប្រមាណពីសមិទ្ធផលនៃការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម ២០១៦-២០២០** ..... ២២

**ឧបសម្ព័ន្ធទី២ ៖ គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម ឆ្នាំ ២០២២-២០២៦** ..... ៣០

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហា
សេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា
ក្នុងការរក្សាបានយ៉ាងពេញលេញនូវសុខសន្តិភាព បូរណភាពទឹកដី និងស្ថិរភាពនយោបាយដោយប្រកាន់ភ្ជាប់នូវ
គោលការណ៍នីតិរដ្ឋ និងប្រជាធិបតេយ្យ។ និយាយដោយឡែក ក្នុងការដោះស្រាយបញ្ហាវិសមភាពយេនឌ័រ ធ្វើឱ្យល្អ
ប្រសើរឡើងនូវការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ដូចបានចែងច្បាស់នៅក្នុងយុទ្ធសាស្ត្រ
ចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នភាពឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រ
នារីរតនៈឆ្នាំ២០១៩-២០២៣។ ក្នុងចំណោមគោលដៅទាំងអស់នៃផែនការយុទ្ធសាស្ត្រចតុកោណទី៤ សម្រាប់
កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ការកសាងមូលដ្ឋានដើម្បីឈានទៅសម្រេចទស្សនៈវិស័យរបស់កម្ពុជានៅ
ឆ្នាំ២០៥០ គឺត្រូវខិតខំពង្រឹងផងដែរនូវសមភាពយេនឌ័រ ដោយទទួលស្គាល់ថា ស្ត្រីកម្ពុជាគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិង
សង្គមជាតិ។ ក្នុងបរិការណ៍នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តប្រកបដោយ
ប្រសិទ្ធភាពនូវអភិក្រមថ្នាក់ជាតិទាំងនេះនិងបង្កើតឡើងនូវទិសដៅជាយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីសម្រេច បាននូវសមភាព
យេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម(ASDP)
ឆ្នាំ២០១៩-២០២៣ ក៏ដូចជាគោនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០ផងដែរ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ចប់ការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ
បញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០ ដោយទទួលបាននូវសមិទ្ធផលគួរជាទីមោទនៈ។ ដើម្បីបញ្ជាក់នូវ
ការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងលើកកម្ពស់ការ
ផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី គឺត្រូវបង្កើនលទ្ធភាពដល់ស្ត្រី ក្នុងការទទួលបាននូវធនធាន សេវាកម្ម ការគាំទ្រ
លទ្ធភាពទីផ្សារ ដោយត្រូវបង្កើនការចូលរួមនិងភាពជាតំណាងរបស់ស្ត្រីក្នុងវិស័យកសិកម្មជាចាំបាច់ផងដែរ។ ប្រាកដ
ណាស់ថា កិច្ចការនេះនឹងអាចសម្រេចបានតាមរយៈការពង្រឹងសកម្មភាព ធនធាន និងការប្តេជ្ញាចិត្ត ក្នុងការបញ្ជ្រាបយេនឌ័រ
ក្នុងវិស័យកសិកម្ម។ ដើម្បីគាំទ្រឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពថែមទៀតនោះ ក្រុមការងារយេនឌ័រ និងកុមាររបស់
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ
ក្នុងវិស័យកសិកម្មឆ្នាំ២០២២-២០២៦ ដោយយោងទៅតាមស្ថានភាពនៃវិស័យកសិកម្មនាពេលបច្ចុប្បន្ននិងអនាគត
ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងបច្ចេកវិទ្យាឌីជីថល។ ម្យ៉ាងទៀតយើងក៏ទទួលស្គាល់ថាបច្ចុប្បន្ននេះ ប្រជាជន
កម្ពុជាយើងទាំងស្ត្រីនិងបុរស ក៏បានជួបប្រទះនូវបញ្ហាប្រឈមនានា រួមទាំងឥទ្ធិពលនៃវិបត្តិជាសកល បណ្តាលមកពី
ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ លើវិស័យទាំងអស់នៃសេដ្ឋកិច្ចជាតិ និងហានិភ័យនៃបម្រែបម្រួលអាកាសធាតុ ដែល
កំពុងបន្តកើតមានឡើងផងដែរ។

ជាថ្មីម្តងទៀត ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសង្ឃឹមថា អង្គភាពជំនាញគ្រប់លំដាប់ថ្នាក់
ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវចូលរួមសហការអនុវត្ត
ឱ្យបានពេញលេញនូវគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០២២-២០២៦
នេះ តាមទស្សនៈវិស័យ និងគោលបំណងរំពឹងទុក ដើម្បីឈានឆ្ពោះទៅសម្រេចបានសមភាពយេនឌ័រ និងការរួមចំណែក
អភិវឌ្ឍមាតុភូមិកម្ពុជាក្នុងកាលៈទេសបច្ចុប្បន្ន និងនាពេលអនាគតក្រោមការសម្របសម្រួលរបស់ក្រុមការងារយេនឌ័រ
និងកុមារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យទទួលបានជោគជ័យក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ១៣កើត ខែ ...ពិសាខ.... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០២២

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# សេចក្ដីថ្លែងអំណរគុណ

តាងនាមឱ្យក្រុមការងារយេនឌ័រ និងកុមារប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់ នាងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានគាំទ្រយ៉ាងពេញទំហឹងទាំងស្មារតី សម្ភារៈ ហិរញ្ញវត្ថុ និងបច្ចេកទេស ក្នុងដំណើរការនៃការរៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០២២-២០២៦ ។

នៅក្នុងដំណើរការធ្វើបច្ចុប្បន្នភាពគោលនយោបាយនេះ មានការរៀបចំសិក្ខាសាលាផ្ទៃក្នុងជាបន្តបន្ទាប់ជាមួយសមាជិក៣៣រូបនៃក្រុមការងារយេនឌ័រ និងកុមារ មន្ត្រីក្រសួង និងមន្ត្រីបង្គោលយេនឌ័រ២៥រាជធានីខេត្ត ដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធផល និងបញ្ហាប្រឈមរបស់ក្រសួង ក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មពីមុនរបស់ខ្លួន (២០១៦-២០២០) និងកំណត់អាទិភាពសម្រាប់ប្រាំឆ្នាំបន្ទាប់។ សារៈសំខាន់នៅក្នុងដំណើរការនេះគឺកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍និងអ្នកពាក់ព័ន្ធ។ ការពិគ្រោះយោបល់និងសម្របសម្រួលជាមួយក្រសួងកិច្ចការនារី និងការពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់កម្ពុជា សម្រាប់សមភាពយេនឌ័រក្នុងវិស័យកសិកម្មសំយោគបណ្ណាល័យសាស្ត្រ និងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ គោលនយោបាយនេះត្រូវបានបង្កើតឡើងដោយស្របគ្នានឹងផែនការយុទ្ធសាស្ត្របច្ចុប្បន្ននៃវិស័យកសិកម្ម និងអនុវិស័យកសិកម្ម ។

ក្រុមការងារយេនឌ័រ និងកុមារ ក៏សូមថ្លែងអំណរគុណ ចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្រោមឱវាទទាំងអស់ ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលបានផ្តល់ធាតុចូលយោបល់ ទិន្នន័យ និងរបាយការណ៍សំខាន់ៗ សម្រាប់ដំណើរការរៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រសមភាពយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០២២-២០២៦។

លើសពីនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់កម្មវិធីកាវ៉ាក់(CAVAC) ដែលបានគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់រៀបចំបច្ចុប្បន្នភាពគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មឆ្នាំ២០២២ - ២០២៦។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះសមាជិក សមាជិកាក្នុងក្រុមការងារយេនឌ័រ និងកុមារទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្តទាំងអស់ ដែលបានខិតខំប្រឹងប្រែងអនុវត្តន៍ សម្របសម្រួល សហការ និងចូលរួមផ្តល់យោបល់ ក្នុងដំណើរការរៀបចំបច្ចុប្បន្នភាពគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រឆ្នាំ២០២២-២០២៦។

**រដ្ឋលេខាធិការនិងជាប្រធានក្រុមការងារយេនឌ័រនិងកុមារ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ហោ ម៉ាលីន**

# សាវតានៃគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) សម្រាប់វិស័យកសិកម្ម គឺការប្រែក្លាយវិស័យកសិកម្មឱ្យទៅជាកសិកម្មពាណិជ្ជកម្ម តាមរយៈការធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងការធ្វើពិពិធកម្ម ព្រមទាំងលទ្ធភាពទទួលបានទីផ្សារ។ ការយល់ដឹងអំពីដំណើរការដ៏ស្វាហាប់នៃការផ្លាស់ប្តូរ និន្នាការដែលកំពុងលេចចេញ និងឥទ្ធិពលខុសគ្នារបស់វាទៅលើស្ត្រី និងបុរស គឺជាកត្តាសំខាន់ក្នុងការកំណត់វិស័យនេះឱ្យមានការអភិវឌ្ឍប្រកបដោយបរិយាប័ន្នមានល្បឿនជាងមុន និងប្រកបដោយចីរភាព។ នៅក្នុងបរិបទនេះ ទស្សនៈយេនឌ័រមានសារៈសំខាន់ជាពិសេសដើម្បីស្វែងយល់ពីផលប៉ះពាល់នៃការវិនិយោគលើដីទ្រង់ទ្រាយធំ និងការផ្លាស់ប្តូរទៅជាកសិ-ពាណិជ្ជកម្មខ្នាតធំ។ ការផ្លាស់ប្តូរទាំងនេះជារឿយៗ ធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងសក្តានុពល និងតួនាទីរបស់គ្រួសារ សកម្មភាពបង្កើតប្រាក់ចំណូល និងសិទ្ធិកាន់កាប់ដីធ្លី។ រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ថាទាំងបុរស និងស្ត្រីរួមចំណែកដល់ការអភិវឌ្ឍ ហើយសមភាពយេនឌ័រមានសារៈសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម។

ចក្ខុវិស័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់វិស័យកសិកម្មកម្ពុជា គឺកសិកម្មកម្ពុជា ជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុនិងនិរន្តរភាព ដែលនឹងធ្វើឱ្យកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា[1]។

ក្រុមការងារយេនឌ័រ និងកុមារ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ ហើយនៅឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រដំបូងគេក្នុងវិស័យកសិកម្ម ។ ការធ្វើបច្ចុប្បន្នភាព និងការអភិវឌ្ឍគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម ២០១៦-២០២០ ត្រូវបានផ្តួចផ្តើម និងដឹកនាំដោយក្រុមការងារយេនឌ័រនិងកុមាររបស់ក្រសួង ដោយមានការសម្របសម្រួលជាមួយនាយកដ្ឋានផែនការ និងស្ថិតិ។ ដំណើរការនេះមានសិក្ខាសាលាផ្ទៃក្នុងជាបន្តបន្ទាប់ជាមួយសមាជិក ៣៣ រូបនៃក្រុមការងារយេនឌ័រ និងកុមារ មន្ត្រីក្រសួង និងមន្ត្រីបង្គោលយេនឌ័រ២៥រាជធានីខេត្ត ដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធិផល និងបញ្ហាប្រឈមរបស់ក្រសួង ក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្មពីមុនរបស់ខ្លួន(២០១៦-២០២០) និងកំណត់អាទិភាពសម្រាប់ប្រាំឆ្នាំបន្ទាប់។ សារៈសំខាន់នៅក្នុងដំណើរការនេះគឺកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍និងអ្នកពាក់ព័ន្ធ ការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយក្រសួងកិច្ចការនារី និងការពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់កម្ពុជា សម្រាប់សមភាពយេនឌ័រក្នុងវិស័យកសិកម្ម ចំណេះវិជ្ជាដែលអាចប្រើជាប្រយោជន៍បាន និងគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ គោលនយោបាយនេះត្រូវបានបង្កើតឡើងដោយស្របគ្នានឹងផែនការយុទ្ធសាស្ត្របច្ចុប្បន្ននៃវិស័យកសិកម្ម និងអនុវិស័យកសិកម្ម។

ការធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឆ្នាំ២០២០-២០២៦ ត្រូវធ្វើឡើងក្នុងធនធានមានកម្រិត ដូចជាធនធានមនុស្ស ធនធានហិរញ្ញវត្ថុ រួមទាំងសមត្ថភាព ស្ថាប័នក្នុងការប្រែក្លាយគោលនយោបាយនិងក្របខណ្ឌយុទ្ធសាស្ត្រឱ្យទៅជាការអនុវត្តជាក់ស្តែង និងអះអាងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ទាក់ទងនឹងសមភាពយេនឌ័រ។ ឯកសារនេះបង្ហាញពីចក្ខុវិស័យ បេសកកម្ម គោលដៅរួម គោលដៅយុទ្ធសាស្ត្រ និងជំហានអនុវត្តរបស់ក្រសួង ក្នុងការបញ្ជ្រាបទស្សនៈទានយេនឌ័រនៅក្នុងនាយកដ្ឋាន/ស្ថាប័នពាក់ព័ន្ធទាំងអស់ និងសកម្មភាពនៃអនុវិស័យនៃវិស័យកសិកម្ម។ គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មនេះសង្កត់ធ្ងន់ទៅលើការសម្រួលសម្រួល

[1] MAFF Agriculture Sector Strategic Development Plan 2019 - 2023

ការកសាងសមត្ថភាព ភាពជាអ្នកដឹកនាំ និងការពង្រឹងទិន្នន័យ និងការវិភាគយេនឌ័រក្នុងវិស័យកសិកម្ម ក៏ដូចជាការពង្រឹងអំណាចផ្នែកសេដ្ឋកិច្ច សម្រាប់ស្ត្រីនៅតំបន់ជនបទក្នុងបរិបទបច្ចុប្បន្ន។

គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម (GEPSFA) ឆ្នាំ ២០២២-២០២៦ ទទួលស្គាល់ការរួមចំណែកយ៉ាងសំខាន់របស់ស្ត្រីកម្ពុជាក្នុងការងារកសិកម្ម ផលិតកម្ម ការប្រមូលផល ការកែច្នៃ និងទីផ្សារ។ វាកំណត់បញ្ហា ឧបសគ្គជាក់លាក់នៅក្នុងផ្នែកទាំងនេះ និងកំណត់លទ្ធផលជាក់លាក់តាមវិស័យមួយចំនួន និងសូចនាករគោលដៅ ដើម្បីដោះស្រាយឧបសគ្គដែលបានកំណត់នោះ។ គោលនយោបាយនេះទទួលស្គាល់ការចូលរួមរបស់ស្ត្រីក្នុងវិស័យដំណាំ ជលផល ផលិតកម្មសត្វ កៅស៊ូ និងការគ្រប់គ្រងធនធានព្រៃឈើ រួមទាំងផលិតផល អនុផលព្រៃឈើ និងទទួលស្គាល់ការពឹងផ្អែកខ្ពស់របស់ស្ត្រីនៅតាមជនបទ ជាពិសេសលើជីវម៉ាសសម្រាប់ការបំពេញតម្រូវការថាមពលគ្រួសារជាមូលដ្ឋាន។ ឯកសារនេះទទួលស្គាល់បន្ទុករបស់ស្ត្រីនៅក្នុងគ្រួសារ និងសហគមន៍ ដោយសារជំងឺរាតត្បាតកូវីដ-១៩។ ជាចុងក្រោយ គោលនយោបាយនេះទទួលស្គាល់ថាការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រយោល ដែលប៉ះពាល់ដល់កសិកម្ម ផលិតកម្មសត្វ ជលផល កៅស៊ូ និងព្រៃឈើ ដែលមិនមានអព្យាក្រឹតយេនឌ័រ។ ដូច្នេះដំណោះស្រាយចាំបាច់ត្រូវតែជានាទាំងគំនិតផ្តួចផ្តើម កាត់បន្ថយនិងបន្សាំទៅនឹងការបម្រែបម្រួលអាកាសធាតុ ដើម្បីទទួលបានលទ្ធផលដែលរំពឹងទុក និងរួមចំណែកដល់ការសម្រេចបានសមភាពយេនឌ័រ។

## ១. ទិដ្ឋភាពទូទៅ៖ ទស្សនៈវិស័យយេនឌ័រនៅកម្ពុជា

ការលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រីលើគ្រប់វិស័យ និងគ្រប់កម្រិត គឺជាអាទិភាពចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា។ កិច្ចសហការ ភាពជាដៃគូ និងការគាំទ្រពីក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍បាននឹងកំពុងរួមចំណែកដល់ការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងគោលនយោបាយជាតិ និងក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗ រួមទាំងការគ្រប់គ្រងដណ្តប់លើការគ្រប់គ្រងសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្របខ័ណ្ឌការពារសង្គម ។

ស្ថានភាពសមភាពយេនឌ័រនៅកម្ពុជា ជាទូទៅមានភាពប្រសើរឡើងក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ប៉ុន្តែបញ្ហាប្រឈមនៅតែមាន។ របាយការណ៍គម្លាតយេនឌ័រសកលឆ្នាំ២០២១ ពីវេទិកាសេដ្ឋកិច្ចពិភពលោកបង្ហាញថា ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ១០៣ ក្នុងចំណោមប្រទេសសរុបចំនួន១៥៦ និងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន៩ ក្នុងចំណោម១៦ប្រទេសនៅក្នុងតំបន់អាស៊ីប៉ូស៊ី និងប៉ាស៊ីហ្វិក[2]។ កម្ពុជាជាប់ចំណាត់ថ្នាក់សមភាពមធ្យមទៅទាបនៅលើសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័ររបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP)[3] និងការប្រៀបធៀបសមិទ្ធិផលសន្ទស្សន៍អភិវឌ្ឍន៍សម្រាប់ស្ត្រី និងបុរសរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP 2020)[4]។ ចំណាត់ថ្នាក់សន្ទស្សន៍វិសមភាពយេនឌ័រឆ្នាំ២០១៩ របស់កម្ពុជាគឺ១១៧ ក្នុងចំណោមប្រទេសចំនួន ១៦២[5]។ ក្នុងសន្ទស្សន៍នីមួយៗនេះ កម្ពុជាបានអនុវត្តវិធានការមួយចំនួនល្អប្រសើរជាងវិធានការផ្សេងៗទៀត។ ផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ (COVID-19) មិនទាន់ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍សន្ទស្សន៍សកលទាំងនេះនៅឡើយទេ។

ការអប់រំរបស់ស្ត្រី មានកម្រិតទាបជាងបុរសនៅគ្រប់កម្រិតទាំងអស់ ក្រៅពីបឋមសិក្សា។ ស្ត្រីពេញវ័យចំនួន ១៥,១ ភាគរយ បានសិក្សាដល់កម្រិតមធ្យមសិក្សា បើប្រៀបធៀបទៅនឹងបុរសមានចំនួន ២៨,២ ភាគរយ[6] ហើយ

[2] https://www3.weforum.org/docs/WEF_GGGR_2021.pdf

[3] Ranked Group 4 out of 5 categories

[4] UNDP 2020

[5] ibid

[6] UNDP, 2020

មានស្ត្រីតែ៨ភាគរយប៉ុណ្ណោះ ដែលបានបញ្ចប់វិទ្យាល័យ បើធៀបនឹងបុរសមាន១១ភាគរយ[7]។ អនក្ខរកម្មមានភាពប្រសើរឡើងជាលំដាប់សម្រាប់ទាំងស្ត្រី និងបុរស ប៉ុន្តែក្នុងឆ្នាំ២០១៩ កម្រិតអនក្ខរកម្មសម្រាប់បុរសគឺ៨៧,២ភាគរយ បើធៀបនឹងស្ត្រីមាន៧៧,១ ភាគរយ[8]។

ក្នុងចំណោមមន្ត្រីរាជរដ្ឋាភិបាលជាន់ខ្ពស់ តំណាងស្ត្រីនៅតែមានចំនួនទាបក្នុងប្រទេសកម្ពុជា។ ការចូលរួមកម្លាំងពលកម្មស្ត្រីសម្រាប់ស្ត្រីនៅកម្ពុជាមាន៧៦,៣ ភាគរយធៀបនឹង៨៨,៩ សម្រាប់បុរស[9] ស្ត្រីទំនងជាស្ថិតក្នុងការងារដែលងាយរងគ្រោះ ហើយទំនងជាស្ថិតក្នុងប្រភេទអ្នកធ្វើការងារបរិច្ចាគដើម្បីគ្រួសារដែលមិនមានប្រាក់កម្រៃ[10] រួមទាំងការងារកសិកម្មក្នុងគ្រួសារផងដែរ[11]។

គម្លាតយេនឌ័រនៅកម្ពុជាក្នុងការចំណាយពេលវេលាលើការថែទាំដែលមិនមានប្រាក់កម្រៃ និងការងារផ្ទះ គឺខ្ពស់បំផុតក្នុងចំណោមប្រទេសអាស៊ាន ស្ត្រីចំណាយពេលវេលាលើសកម្មភាពទាំងនេះ ច្រើនជាងបុរស១០ដង[12]។ បន្ទុកការងារនេះនាំឱ្យស្ត្រីមានលទ្ធភាពក្នុងការធ្វើដំណើរតិចជាងបុរស និងកាត់បន្ថយឱកាសរបស់ពួកគាត់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាល ធ្វើការងារ និងចូលរួមការសម្រេចចិត្តក្នុងសហគមន៍។

ការបញ្ចប់អំពើហិង្សាលើស្ត្រី គឺជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយស្ថាប័នរាជរដ្ឋាភិបាលទាំងអស់ តំណាងវិស័យឯកជន និងអង្គការសង្គមស៊ីវិល បានចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ អាចផ្តល់សេវាកម្មទាន់ពេលវេលា និងមានប្រសិទ្ធភាពសម្រាប់អ្នករស់រានមានជីវិត។ ផែនការសកម្មភាពជាតិលើកទី៣ របស់កម្ពុជាស្តីពីអំពើហឹង្សាលើស្ត្រី ត្រូវបានដាក់ឱ្យដំណើរការនៅឆ្នាំ២០២១។

ការរីករាលដាលជំងឺកូវីដ-១៩ (COVID-19) បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ត្រី និងកុមារីនៅកម្ពុជា ។ ស្ត្រីមានតំណាងជាច្រើន ក្នុងវិស័យមួយចំនួន ទទួលរងគ្រោះខ្លាំងបំផុតដោយសារជំងឺកូវីដ-១៩ កំពុងធ្វើការងារដែលមិនមានប្រាក់កម្រៃ និងការងារថែទាំគ្រួសារកាន់តែច្រើន ហើយប្រឈមមុខនឹងហានិភ័យនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពានកាន់តែច្រើន[13]។ ហានិភ័យកើតមានឡើង ដែលបង្កការលំបាកថែមទៀតក្នុងការធ្វើឱ្យសមភាពយេនឌ័រ និងអាចធ្វើឱ្យស្ថានភាពត្រូវផ្លាស់ប្តូរទៅក្រោយវិញ។ ការគំរាមកំហែងទាំងនេះកំពុងតែបន្តនិងកើនឡើងពីការប្រែប្រួលអាកាសធាតុ។ ដោយសារហេតុផលទាំងនេះ វាមានសារៈសំខាន់ជាងពេលណាៗទាំងអស់ក្នុងការដោះស្រាយតម្រូវការជាក់ស្តែងរបស់ស្ត្រី និងកុមារីក្នុងវិស័យកសិកម្ម ហើយធានាថាពួកគេអាចចូលរួមប្រកបដោយអត្ថន័យក្នុងការសម្រេចចិត្តក្នុងអំឡុងពេល និងក្រោយពេលជំងឺរាតត្បាត។

# ២. យេនឌ័រ និងកសិកម្ម

## ទិដ្ឋភាពទូទៅ

វិស័យកសិកម្មនៅកម្ពុជា បន្តតួនាទីយ៉ាងសំខាន់ក្នុងកំណើនសេដ្ឋកិច្ច ធានាសមភាព សន្តិសុខស្បៀង និងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។ កសិកម្មបានរួមចំណែកជាមធ្យម ២៧,៤ ភាគរយ ពីឆ្នាំ ២០១០ដល់

---

[7] NIS, 2019

[8] UN Women and CDRI, 2021

[9] UNDP, 2020

[10] HRM Asia, 2021

[11] Gavalyugova and Cunningham, 2020

[12] The next highest in the region was Laos PDR, with women spending four times more time than their partners on unpaid care and domestic work.

[13] ILO, 202; and UN Women, 2020

ឆ្នាំ ២០១៩ (ធ្លាក់ចុះបន្តិចក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ) នៃផលិតផលក្នុងស្រុកសរុប (GDP)។ វាស្រូបយកកម្លាំងពលកម្មជាង៤,៥ លាននាក់[14]។ ក្នុងឆ្នាំ ២០១៩ ស្ត្រីដែលធ្វើប្រកបការងារកសិកម្មមានច្រើនរហូត ៥២,២ ភាគរយ និង ៤៧,៨ភាគរយ ជាបុរស[15]។ ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ ២០១៩ បង្ហាញថា ក្នុងចំណោមស្ត្រីសរុបចំនួន៤ ២២៤ ១៧២នាក់ ដែលមានអាយុចាប់ពី៥ ឆ្នាំឡើងទៅ ដែលចាត់ទុកថាមានការងារ៥៦,៥ភាគរយ នៅក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ[16]។ ទោះបីជាស្ត្រី និងបុរសបានផ្លាស់ប្តូរពីវិស័យកសិកម្ម ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ក៏នៅតែមានស្ត្រីចំនួន ៤៤ភាគរយ និងបុរស៣៩ ភាគរយ ដែលធ្វើការងារក្នុងវិស័យនេះ នៅប្រទេសកម្ពុជា[17]។

ស្ត្រីនិងបុរសមានការចូលរួមផ្សេងៗគ្នា ក្នុងការងារកសិកម្ម។ យោងតាមវិទ្យាស្ថានជាតិស្ថិតិ បានរកឃើញថា ក្នុងចំណោមគ្រួសារជនបទ ស្ត្រីមានច្រើនជាងបុរសដែលពាក់ព័ន្ធក្នុងការចិញ្ចឹមសត្វ តែបុរសចូលរួមក្នុងការដាំដុះដំណាំ ការធ្វើវារីវប្បកម្មឬនេសាទ និងនៅក្នុងសកម្មភាពមិនមែនកសិកម្មច្រើនជាងស្ត្រី ហើយក្នុងករណីនីមួយៗ មានភាពខុសប្លែកគ្នាខ្លាំងនៅរដូវប្រាំងជាងនៅរដូវវស្សា។ ពួកគេក៏បានរកឃើញថាស្ត្រីត្រូវបានជួលជាកម្លាំងក្នុងការចិញ្ចឹមសត្វច្រើនជាងបុរស ហើយបុរសត្រូវបានជួលក្នុងការដាំដុះដំណាំនៅខាងក្រៅច្រើនជាងស្ត្រី[18]។

ស្ត្រីមានតំណាងលើសលប់ក្នុងចំណោមតួនាទីដែលមានជំនាញទាប និងប្រាក់ខែតិចក្នុងវិស័យកសិកម្ម។ ស្ត្រី៦៨,៤ភាគរយនៅជនបទ ធ្វើការងារគ្រួសារដែលមិនបានប្រាក់កម្រៃ ខ្ពស់ជាងបុរសដែលមានត្រឹមតែ២៨,៤ ភាគរយ[19]។ វិទ្យាស្ថានជាតិស្ថិតិ (NIS) បានរកឃើញថា សមាជិកគ្រួសារភាគច្រើន មិនបានទទួលកម្រៃសម្រាប់ការងាររបស់ពួកគេ ដែលរួមចំណែកដល់ការងារកសិកម្ម[20]។ ក្នុងឆ្នាំ ២០១៦ គម្លាតនៃប្រាក់ចំណូលប្រចាំម៉ោងរវាងស្ត្រី និងបុរសក្នុងវិស័យកសិកម្មមានចំនួន១៨ភាគរយ[21]។ របាយការណ៍របស់អង្គការ OECD បានរកឃើញថា សកម្មភាពផលិតកម្ម និងទីផ្សារដែលផ្តួចផ្តើមដោយស្ត្រីកម្ពុជាក្នុងវិស័យកសិកម្ម មានការទទួលស្គាល់តិចតួច ហើយនៅពេលដែលស្ត្រីរីកចម្រើន ស្វាមីតែងតែគ្រប់គ្រងអាជីវកម្មរបស់គេ[22]។

នៅកម្ពុជា កសិករជាស្ត្រីដើរតួនាទីយ៉ាងសំខាន់ ក្នុងការប្រែក្លាយផលិតផលកសិកម្មទៅជាស្បៀង និងអាហារូបត្ថម្ភសម្រាប់គ្រួសាររបស់ពួកគេ។ ស្ត្រីមានទំនួលខុសត្រូវលើការផលិតអាហារ ការជ្រើសរើស ការរៀបចំ ការថែទាំ ការចិញ្ចឹមកូន និងជាគន្លឹះនៃសន្តិសុខស្បៀងសម្រាប់គ្រួសាររបស់ពួកគេ។ នៅក្នុងឆ្នាំ២០០៩ ស្ត្រីមាន ៥១% នៃកម្លាំងការងារបឋមក្នុងវិស័យកសិកម្មសម្រាប់ចិញ្ចឹមជីវិតនៅក្នុងប្រទេសកម្ពុជា[23]។ ស្ត្រីបានចូលរួមកាន់តែខ្លាំងឡើងនៅក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្មសម្រាប់ពាណិជ្ជកម្ម ជាចំណុចកណ្តាលនៅក្នុងទីផ្សារលក់ដុំនិងរាយនៃផលិតផលកសិកម្ម និងនៅក្នុងការធ្វើកសិ-ធុរកិច្ច។ ពួកគេជាអ្នកប្រមូលទិញឬពាណិជ្ជករ ហើយជាអ្នកលក់រាយដ៏សំខាន់ នៅក្នុងទីផ្សារនៅថ្នាក់មូលដ្ឋាន ខេត្ត និងថ្នាក់ជាតិ។ លើសពីនេះ ស្ត្រីជាច្រើនជាម្ចាស់ឬជាដៃគូយ៉ាងសកម្ម

[14] UN Women and CDRI, 2021

[15] ibid

[16] ibid

[17] Gavalyugova and Cunningham, 2020

[18] NIS, 2019

[19] UN Women and CDRI, 2021

[20] NIS,2019

[21] Gavalyugova and Cunningham, 2020

[22] OECD, 2021

23 UNSDG, 2020

ក្នុងការផ្គត់ផ្គង់ផលិតផលកសិ-ពាណិជ្ជកម្ម ទំនាក់ទំនងដោយផ្ទាល់ជាមួយអតិថិជន ផ្តល់ព័ត៌មាន និងចំណេះដឹងលើការប្រើប្រាស់ធាតុចូល ជី និងថ្នាំសម្លាប់សត្វល្អិត។

## និន្នាការថ្មី ឱកាស និងហានិភ័យ

ផ្នែកនេះបង្ហាញពីបញ្ហាបរិបទសំខាន់ៗមួយចំនួន ដែលបច្ចុប្បន្នមានផលប៉ះពាល់លើស្ត្រី និងបុរសក្នុងវិស័យកសិកម្មដែលចាំបាច់ត្រូវពិចារណា និងដោះស្រាយក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ ការផ្លាស់ប្តូរ និងនិន្នាការទាំងនេះបង្ហាញពីឱកាស ប៉ុន្តែក៏បង្កឱ្យមានបញ្ហាប្រឈមសំខាន់ៗ និងភាពមិនច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាយេនឌ័រក្នុងវិស័យនេះផងដែរ។

## ផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩

ជំងឺកូវីដ-១៩ កំពុងរីករាលដាលពាសពេញពិភពលោក រួមទាំងប្រទេសកម្ពុជា បានជះឥទ្ធិពលអវិជ្ជមានដល់កសិករ ជាពិសេសកសិករខ្នាតតូច រួមទាំងស្ត្រីផងដែរ ។ វាកាត់បន្ថយប្រាក់ចំណូល បញ្ហាប្រឈមទីផ្សារ និងការចំណាយកាន់តែខ្ពស់[24]។ ការចំណាយក្នុងការរស់នៅមានកម្រិតខ្ពស់ បានធ្វើឱ្យមានភាពតានតឹងជាក់លាក់សម្រាប់ស្ត្រី ដែលមានការទទួលខុសត្រូវជាចម្បង ក្នុងការបំពេញតម្រូវការគ្រួសារ។ សេដ្ឋកិច្ចក្នុងកម្រិតទូលំទូលាយ បន្តរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ប៉ុន្តែកសិកម្មទទួលបាននូវអត្ថប្រយោជន៍មួយចំនួន រួមបញ្ចូលទាំងការបង្កើនការផ្តល់ប្រាក់កម្ចីដល់ វិស័យកសិកម្ម និងការកែច្នៃផលិតផលកសិកម្ម ដែលមានសន្ទុះឆ្ពោះទៅរកពិពិធកម្មសេដ្ឋកិច្ច[25]។

ការរីករាលដាលជំងឺកូវីដ-១៩ (COVID-19) បានជំរុញឱ្យកាន់តែមានវិសមភាពយេនឌ័រ[26]។ ផលប៉ះពាល់មិនសមាមាត្រលើស្ត្រី និងកុមារី ត្រូវបានកត់ត្រាយ៉ាងល្អ រួមទាំងការកើនឡើងភាពមិនច្បាស់លាស់នៃការងារ ហានិភ័យនៃអំពើហិង្សាកាន់តែធ្ងន់ធ្ងរ ការរំលោភបំពាន ការកេងប្រវ័ញ្ចនិងបង្កើនការងារថៃទាំយ៉ាងខ្លាំង។ កសិករជាស្ត្រីខ្នាតតូចមានលទ្ធភាពតិចតួចក្នុងការទទួលបាននូវធនធានផលិតភាព សេវាកម្ម បច្ចេកវិទ្យា ទីផ្សារ និងដើមទុនវិនិយោគ ហើយត្រូវប្រឈមមុខនឹងជំងឺកូវីដ ដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះក្នុងការបាត់បង់ប្រាក់ចំណូល[27]។ ជំងឺរាតត្បាតក៏បានបង្កើនភាពងាយរងគ្រោះដល់ស្ត្រី ទាក់ទងនឹងបម្រែបម្រួលអាកាសធាតុផងដែរ។ ស្ត្រីស្ថិតក្នុងការលំបាករួចទៅហើយទាក់ទងនឹងគ្រោះមហន្តរាយអាកាសធាតុ ដែលជះឥទ្ធិពលអវិជ្ជមានទៅលើទីជម្រក ផលិតកម្មកសិកម្ម ការរក្សាទុកស្បៀងអាហារ និងលទ្ធភាពទទួលបានគ្រាប់ពូជ ដែលធ្វើឱ្យភាពងាយរងគ្រោះកាន់តែធ្ងន់ធ្ងរ[28]។ នៅពេលដែលជំងឺរាតត្បាតបានធូរស្រាលនិងការរឹតបន្តឹងនៅតាមព្រំដែន ការធ្វើចំណាកស្រុកអាចកើនឡើង ប៉ុន្តែស្ត្រីមានឱកាសធ្វើចំណាកស្រុកបានតិចតួច។ ការធ្វើចំណាកស្រុកបានបង្កការលំបាកដល់ស្ត្រីជាអ្នកគ្រប់គ្រងគ្រួសារនៅជនបទមានការកើនឡើង ព្រមទាំងបន្ថែមបន្ទុកការងារដល់ស្ត្រី ដែលជាលទ្ធផលទៀតផង ។

បន្ទាប់ពីជំងឺរាតត្បាតកូវីដបានធូរស្រាល វិស័យកសិកម្មនឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឱ្យប្រសើរឡើងវិញ រួមទាំងការធានានូវភាពធន់នឹងសេដ្ឋកិច្ច និងសន្តិសុខស្បៀង ប៉ុន្តែវាមានសារៈសំខាន់ណាស់ក្នុងការធានាថាស្ត្រីចូលរួមចំណែកស្មើគ្នា នៅក្នុងដំណើរការធ្វើឱ្យប្រសើរឡើងវិញ និងវិស័យដែលកំពុងដំណើរការទៅមុខ។

---

[24] DFAT, 2021; Sok Piseth et al, 2021

[25] DFAT, 2021

[26] Oxfam Cambodia 2020

[27] Huot and Jensen, 2022

[28] ibid

បើគ្មានការប្រឹងប្រែងយកចិត្តទុកដាក់ផ្តោតលើការងារនេះទេ ភាពជោគជ័យឆ្ពោះទៅរកសមភាពយេនឌ័រមិនងាយនឹងទទួលបានទេ ហើយអាចនឹងមានការធ្លាក់ចុះមកវិញ។ ផលប៉ះពាល់នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ លើស្ត្រី បានបង្ហាញដល់ពិភពលោកអំពីវិសមភាពយេនឌ័រ ព្រមទាំងបង្កើតឱកាសសម្រាប់រាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ក្នុងការធ្វើការរួមគ្នាដើម្បីអនុវត្តយុទ្ធសាស្ត្រដែលមានស្រាប់ និងយុទ្ធសាស្ត្រថ្មី និងការប្តេជ្ញាចិត្តជាមួយនឹងភាពបន្ទាន់ដែលត្រូវការ ដើម្បីបន្តដំណើរការទៅមុខ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលខ្លី ធនធានថវិកាដ៏សន្ធឹកសន្ធាប់ត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយជំងឺរាតត្បាត ហើយស្ត្រីបន្តខ្វះសំឡេងក្នុងការសម្រេចចិត្តដែលទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងជំងឺរាតនេះ និងនៅគ្រប់វិស័យនៃគោលនយោបាយនិងការអនុវត្ត។

## ការប្រែប្រួលអាកាសធាតុ

កម្ពុជាជាប់ចំណាត់ថ្នាក់ទី១៥ លើសន្ទស្សន៍ហានិភ័យអាកាសធាតុសកលលោក ទាំងទឹកជំនន់ ដែលជាគ្រោះមហន្តរាយដ៏សាហាវបំផុតសម្រាប់ប្រជាជនកម្ពុជា និងគ្រោះរាំងស្ងួតកាន់តែខ្លាំងឡើង ។ គ្រោះរាំងស្ងួតឆ្នាំ២០១៦ គឺអាក្រក់បំផុតក្នុងរយៈពេលជាច្រើនទសវត្សរ៍[29]។ ផ្អែកលើការវិភាគរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អត្រាគ្រោះមហន្តរាយបានកើនឡើងជាលំដាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៩ រួមទាំងការកើនឡើងគួរឱ្យកត់សម្គាល់នៃចំនួនគ្រោះមហន្តរាយក្នុងឆ្នាំ ២០១៣ ដែលឈានដល់ ១៨៣៦ ករណីនៅឆ្នាំនោះ[30]។ ការប្រែប្រួលអាកាសធាតុត្រូវបានគេគិតថាជាកត្តាមួយក្នុងការកាត់បន្ថយទិន្នផលកសិកម្ម ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះដោយសារតែគ្រោះមហន្តរាយកើនឡើង[31]។

ការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់ដល់ស្ត្រី បុរស និងជនងាយរងគ្រោះតាមរូបភាពផ្សេងៗគ្នា ដែលជាហេតុធ្វើឱ្យមានវិសមភាពយេនឌ័រកាន់តែកើនឡើង ដែលបញ្ហាទាំងនេះទាមទារ ឱ្យមានការយកចិត្តទុកដាក់ដើម្បីឆ្លើយតបទៅនឹងវិសមភាពយេនឌ័រនិងបញ្ហាផ្សេងរបស់ស្ត្រីនិងបុរសក្នុងការប្រែប្រួលអាកាសធាតុ ពាក់ព័ន្ធនឹងការធានាសន្តិសុខស្បៀង ជីវភាពរស់នៅ ការទប់ទល់នឹងគ្រោះថ្នាក់និងហានិភ័យ។ ស្ត្រីមិនមានលទ្ធភាពដូចគ្នានឹងបុរស ក្នុងការទទួលបាននូវធនធានហិរញ្ញវត្ថុ ដីធ្លី ធនធានធម្មជាតិ និងបច្ចេកវិជ្ជានៃការប្រែប្រួលអាកាសធាតុ ការអប់រំ និងសេវាកម្មអភិវឌ្ឍន៍ផ្សេងៗទៀត ចាំបាច់សម្រាប់ការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពក្នុងវិស័យកសិកម្ម ។ សន្ទស្សន៍ភាពធន់របស់កម្ពុជា បានរកឃើញថាស្ត្រីងាយប្រឈមនឹងគ្រោះមហន្តរាយមានចំនួនច្រើនជងជាងបុរស ដោយសារស្ត្រីមានប្រភពចំណូលមិនស្ថិតស្ថេរនិងមិនទៀងទាត់ ហើយស្ត្រីមិនសូវមានលទ្ធភាពទទួលបានការគាំទ្រជារចនាសម្ព័ន្ធសម្រាប់កិច្ចការពារគ្រោះធម្មជាតិ មានលទ្ធភាពតិចជាងក្នុងការទទួលបាននូវជម្រក ឬទីកន្លែងសុវត្ថិភាព ការទទួលបាននូវព័ត៌មានជាមុនអំពីគ្រោះធម្មជាតិ លំនៅដ្ឋានមិនសមរម្យ និងមិនសូវមានបណ្តាញសុវត្ថិភាពសង្គម[32]។

ជាងនេះទៅទៀត ទំនួលខុសត្រូវរបស់ស្ត្រីក្នុងការចាត់ចែងធនធានគ្រួសារ ធ្វើឱ្យពួកគេចូលរួមចំណែកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតបានយ៉ាងល្អ សម្របខ្លួនទៅនឹងការផ្លាស់ប្តូរបរិស្ថាន។ ទោះយ៉ាងណាក៏ដោយ ការខ្វះខាតព័ត៌មាន និងការទទួលបានដំណើរការរៀបចំផែនការ និងកាតព្វកិច្ចថែទាំ កំណត់សមត្ថភាពរបស់ពួកគេក្នុងការរួមចំណែកក្នុងយុទ្ធសាស្ត្រនោះ[33]។

[29] Tanyag and True, 2018

[30] UN Women and CDRI

[31] ibid

[32] ibid

[33] Tanyag and True, 2018

ការបង្កើនការទទួលស្គាល់នូវភាពបន្ទាន់នៃការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងទំនាក់ទំនងរវាងបញ្ហាយេនឌ័រ និងអាកាសធាតុ បង្កើតឱកាសសក្តានុពល ដើម្បីជះឥទ្ធិពលដល់ការផ្លាស់ប្តូរ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រីកាន់តែច្រើនក្នុងការដើរតួនាទីជាអ្នកដឹកនាំក្នុងវិស័យកសិកម្ម និងឧស្សាហកម្មបៃតង សហគ្រិន ឬអ្នកជំនាញផ្នែកឧស្សាហកម្ម។ នៅក្នុងបរិបទនេះ ក្រសួងកិច្ចការនារី បានកំណត់យកការបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុ និងកំណើនបៃតង ថាជាយុទ្ធសាស្ត្រមួយ សម្រាប់ការពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រី។

## ស្ត្រីនិងការទទួលបាននូវឧបករណ៍ និងបច្ចេកវិទ្យាឌីជីថល

ការបង្ហាញបច្ចេកវិទ្យា និងយន្តការដើម្បីលើកកម្ពស់ផលិតភាព គឺជាទិដ្ឋភាពដ៏សំខាន់សម្រាប់ជំរុញទំនើបកម្មកសិកម្មកម្ពុជា។ ទោះជាយ៉ាងណាក្តី យន្តការ និងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មី មានឥទ្ធិពលលើកសិករជាបុរស និងស្ត្រីខុសៗគ្នា។ ការប្រើប្រាស់គ្រឿងយន្ត អាចបង្កើនផលិតកម្ម កាត់បន្ថយបន្ទុកការងារ និងការលំបាកមួយចំនួនរបស់កសិករជាស្ត្រី។ នៅកម្ពុជា មានកិច្ចខិតខំប្រឹងប្រែងតិចតួច កំពុងត្រូវបានធ្វើឡើង ដើម្បីធានាថាស្ត្រីមានលទ្ធភាពស្មើគ្នានឹងបុរស ក្នុងការប្រើប្រាស់គ្រឿងយន្ត ឬការបណ្តុះបណ្តាលអំពីការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មី ជាពិសេសគ្រឿងម៉ាស៊ីន។ ជាទូទៅការងារប្រមូលផល និងក្រោយពេលប្រមូលផល ភាគច្រើនធ្វើឡើងដោយស្ត្រី បច្ចុប្បន្នការងារទាំងនេះត្រូវបានធ្វើឡើងដោយម៉ាស៊ីនដែលប្រើប្រាស់ដោយបុរស។ គ្រឿងម៉ាស៊ីនអាចជះឥទ្ធិពលដោយអចេតនា ជាពិសេសលើស្ត្រីគ្មានដីនិងកម្មករជាស្ត្រី។ ភាពលំអៀងក្នុងសង្គមដែលភ្ជាប់គ្រឿងយន្តជាមួយបុរស រឹតត្បិតការប្រើប្រាស់របស់ស្ត្រីក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រើបច្ចេកវិទ្យា[34]។

ការរឹតបន្តឹងលើការធ្វើដំណើរក្នុងអំឡុងពេលការរីករាលដំងឺរាតត្បាតCOVID-19 បានរួមចំណែកយ៉ាងឆាប់រហ័សនៃការប្រើប្រាស់ឌីជីថលនៅក្នុងអាជីវកម្ម រួមទាំងក្នុងវិស័យកសិកម្ម និងខ្សែច្រវ៉ាក់តម្លៃកសិកម្ម។ បច្ចុប្បន្ននេះ ស្ត្រីត្រូវបានគេរំពឹងថានឹងទទួលយកការងារជាអាទិភាពដូចជា ការថែទាំ និងការងារផ្ទះភាគច្រើន ដើម្បីទទួលបានអត្ថប្រយោជន៍ជាសក្តានុពលពីការផ្លាស់ប្តូរទៅជាឌីជីថល ព្រោះវាអាចអនុញ្ញាតឱ្យពួកគាត់ធ្វើការពីផ្ទះ ស្ត្រីប្រឈមមុខនឹងគម្លាតយេនឌ័រក្នុងការទទួលបានបច្ចេកវិទ្យា និងការបណ្តុះបណ្តាលបែបនេះសម្រាប់អភិវឌ្ឍជំនាញចាំបាច់។

## ចំណាកស្រុក

ការធ្វើចំណាកស្រុកប៉ះពាល់ដល់កម្លាំងពលកម្ម ប៉ុន្តែវាជួយបង្កើនប្រាក់ចំណូលរបស់គ្រួសារនៅតាមជនបទជាច្រើនតាមរយៈប្រាក់បញ្ញើពីកម្មករចំណាកស្រុកទៅឱ្យគ្រួសារ តែវាក៏គំរាមកំហែងយ៉ាងខ្លាំងទៅលើកម្លាំងពលកម្មកសិកម្មដែលមាន។ ស្ត្រី ៣៥,៧ ភាគរយ ច្រើនជាងបុរស ៣២,៤ភាគរយ ធ្វើចំណាកស្រុកពីជនបទទៅទីក្រុង។ ស្ទើរតែពាក់កណ្តាលនៃជនចំណាកស្រុក មានអាយុចន្លោះពី ២០ ទៅ ៣៩ ឆ្នាំ ទាំងបុរសនិងស្ត្រី ហើយ ៩០ភាគរយមានអាយុពី១៥ ទៅ៦៤ឆ្នាំ។ ការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង មានទំហំធំជាងពីទីក្រុងទៅទីក្រុង។ ការវិភាគយេនឌ័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ឆ្នាំ២០១៨ បានរកឃើញថា ការធ្វើចំណាកស្រុកដាក់បន្ទុកកាន់តែច្រើនលើស្ត្រីវ័យចំណាស់នៅក្នុងសហគមន៍ជនបទ ក្នុងការមើលថែកូនចៅ និងទទួលបន្ទុកទាំងការងារដែលមិនមានកម្រៃ និងការងារមានកម្រៃផងដែរ[35]។

ការធ្វើចំណាកស្រុកមានឥទ្ធិពលខ្លាំងលើតួនាទីយេនឌ័រ និងការបែងចែកការងារតាមទីជនបទនៅកម្ពុជា។ ចំណុចនេះមានផលប៉ះពាល់ដល់ការចូលរួមរបស់ស្ត្រី នៅក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម។ កត្តាសំខាន់ដែលរួមចំណែកដល់ការផ្លាស់ប្តូរនេះគឺការបង្កើនការធ្វើចំណាកស្រុករបស់នារី និងបុរសវ័យក្មេងទៅកាន់រោងចក្រកាត់ដេរ ការងារ

[34] Forthcoming CAVAC study on Gender and Mechanisation

[35] ibid

សំណង់ ឧស្សាហកម្មសេវាកម្ម និងផ្សេងៗទៀត។ ភាពក្រីក្រ ប្រាក់ចំណូលមិនគ្រប់គ្រាន់ពីសកម្មភាពធ្វើស្រែចំការ និងបំណុល គឺជាហេតុផលដ៏សំខាន់ដែលធ្វើឱ្យគ្រួសារជនបទសម្រេចចិត្តធ្វើចំណាកស្រុក ឬបញ្ជូនសមាជិកគ្រួសារទៅធ្វើការជំនួស។ គ្រួសារនៅជនបទជាច្រើន មានតែមនុស្សវ័យចំណាស់និងកុមារ នៅពេលដែលបុរសធ្វើចំណាកស្រុកចាកចោលស្ត្រី និងកុមារ។

ការធ្វើចំណាកស្រុករបស់បុរស ផ្តល់ឱកាសថ្មីសម្រាប់ស្ត្រី ដូចជាការធ្វើឱ្យស្ត្រីក្លាយជាអ្នកគ្រប់គ្រងកសិដ្ឋាន ទទួលបានការគ្រប់គ្រងកាន់តែខ្លាំងលើធនធានគ្រួសារ និងការកែលម្អស្ថានភាពសេដ្ឋកិច្ចសង្គម។ ការធ្វើចំណាកស្រុកក៏អាចបង្កើនតម្រូវការ និងឱកាសដើម្បីបង្កើតសេវាកម្ម ដូចជាសេវាផ្ទេរប្រាក់ ជម្រើសថែទាំកុមារនៅតាមភូមិ និងការអភិវឌ្ឍអាជីវកម្មក្នុងវិស័យកសិកម្មសម្រាប់ស្ត្រីជនបទវ័យក្មេង ។

## ការមើលឃើញ ការទទួលស្គាល់ និងតួនាទីរបស់ស្ត្រីក្នុងការសម្រេចចិត្តក្នុងវិស័យកសិកម្ម

ស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យកសិកម្ម និងកសិពាណិជ្ជកម្ម ប៉ុន្តែសំឡេង និងតំណាងរបស់ពួកគាត់ក្នុងកម្រិតសហគមន៍ជនបទនៅមានកម្រិត[36]។ ទិន្នន័យវិទ្យាស្ថានជាតិស្ថិតិ បានបង្ហាញថា សម្រាប់សមាជិកគ្រួសារដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ៦១ ភាគរយនៃស្ត្រី និង ៦៣ ភាគរយនៃបុរសបានរាយការណ៍ថា បានចូលរួមក្នុងការសម្រេចចិត្ត រួមទាំងការសម្រេចចិត្តទាក់ទងនឹងការដាំដុះដំណាំនិងការចិញ្ចឹមសត្វ[37]។ ទោះយ៉ាងណាក៏ដោយ សំឡេងរបស់ស្ត្រីនៅក្រៅគ្រួសារនៅក្នុងការសម្រេចចិត្តនៅមានកម្រិត ឧទាហរណ៍ ស្ត្រីមិនសូវបានចូលរួមវេទិកាកសិកម្មជាតិកម្ពុជា និងអ្នកដែលចូលរួម កម្រមានយោបល់ណាស់[38]។ ការវិភាគដោយអង្គការសហប្រជាជាតិដើម្បីស្ត្រី (UN Women) បង្ហាញថាតំណាងស្ត្រីនៅក្នុងវិស័យសាធារណៈ នៅមានកម្រិតទាប គំនិតនិងកង្វល់របស់ពួកគាត់ មិនសូវបានយកចិត្តទុកដាក់ ហើយសំឡេងរបស់ស្ត្រីក្នុងការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ កម្រត្រូវបានគេពិចារណាក្នុងដំណើរការធ្វើការសម្រេចចិត្ត។ កត្តាចំបងដែលធ្វើឱ្យស្ត្រីមិនសូវបានចូលរួមគឺៈ បទដ្ឋាន និងប្រពៃណី កម្រិតនៃការអប់រំទាប អនក្ខរភាព កម្រិតនៃភាពក្រីក្រ និងបន្ទុកការងារក្នុងគ្រួសារកាន់តែច្រើន ដែលផ្នែកនីមួយៗកំណត់លទ្ធភាពទទួលបានព័ត៌មាន ធនធាន និងការអប់រំរបស់ស្ត្រី[39]។ មានភស្តុតាងដ៏គួរឱ្យចាប់អារម្មណ៍ដែលបង្ហាញថាស្ត្រីកម្ពុជានៅតាមជនបទ ចូលរួមនិងដឹកនាំកិច្ចការសហគមន៍[40] ទោះបីជាបទដ្ឋានយេនឌ័រមិនលើកទឹកចិត្តចំណុចនេះក៏ដោយ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការរួមចំណែករបស់ស្ត្រីនៅក្នុងគ្រួសារ និងផលប៉ះពាល់នៃបន្ទុកការងារគ្រួសារមកលើស្ត្រីកំពុងត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើង ផ្តល់ឱកាសសម្រាប់ការតស៊ូមតិ និងកម្មវិធីបន្ថែមទៀត ដើម្បីបង្កើនកាលានុវត្តភាព និងអត្ថប្រយោជន៍សម្រាប់ស្ត្រីនៅតាមជនបទ។ ការលើកកម្ពស់សំឡេងរបស់ស្ត្រីក្នុងការសម្រេចចិត្ត នៅតែជាអាទិភាពសម្រាប់ក្រសួង នៅក្នុងគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម ។

## ស្ត្រីនៅក្នុងការធ្វើកសិកម្ម និងនេសាទរួមគ្នា

សហគមន៍កសិកម្ម និងក្រុមកសិកម្មផ្សេងទៀត ដូចជាក្រុមអ្នកផលិត មានសារៈសំខាន់ក្នុងការលើកកម្ពស់ការរួមចំណែករបស់ស្ត្រី ក្នុងការចូលរួមនិងទទួលបានអត្ថប្រយោជន៍ ពីសកម្មភាពក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម។ ក្នុងឆ្នាំ ២០១៨ មានសហគមន៍កសិកម្មចំនួន ១១១៦ នៅទូទាំងប្រទេស ដែលមានភាគហ៊ុនសរុបចំនួន ១៣០ ០៥៩

[36] OECD, 2021

[37] NIS,2019

[38] ibid

[39] UN Women and CDRI, 2021

[40] Tanyag and True, 2018; Oxfam, 2012

ស្ត្រី៦២ ភាគរយ (MAFF, ២០១៩)។ នៅឆ្នាំ២០១៨ សហគមន៍នេសាទមានចំនួន ៥១៦ ក្នុងនោះ៤៧៥ ជាសហគមន៍ទឹកសាប និង ៤១ ជាសហគមន៍ទឹកប្រៃ ដែលមានសមាជិកសរុបចំនួន៣៣២ ១៦៨នាក់ ស្ត្រី៣៥ ភាគរយ។

សហគមន៍កសិកម្ម និងក្រុមអ្នកផលិតទទួលបានការគាំទ្រ និងអន្តរាគមន៍ប្រភេទផ្សេងៗគ្នាពីក្រសួង ដៃគូអភិវឌ្ឍន៍ អង្គការ និងកម្មវិធីអភិវឌ្ឍន៍កសិកម្មនានា ដើម្បីលើកកម្ពស់អាជីវកម្មកសិកម្ម រួមមានៈ ការអភិវឌ្ឍជំនាញកសិកម្ម ការលើកកម្ពស់ការធ្វើសួនដំណាំសម្រាប់គ្រួសារក្រីក្រ ការសម្របសម្រួលសកម្មភាពអាជីវកម្មរួមគ្នាតាមរយៈការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា។ អន្តរាគមន៍ដោយដៃគូនានាដើម្បីលើកកម្ពស់យេនឌ័រ ជាពិសេសការបង្កើនចំនួនស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ ផ្តោតលើការកសាងសមត្ថភាព និងការបង្កើតផែនការអាជីវកម្មជាដើម។ ដៃគូផ្សេងទៀតជ្រើសរើសសហគមន៍កសិកម្មជាក្រុមគោលដៅ ប្រសិនបើពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យយេនឌ័ររបស់ពួកគាត់ ដូចជាសហគមន៍កសិកម្មដឹកនាំដោយស្ត្រី ឬមានសមាជិកភាគច្រើនជាស្ត្រី។ ការសិក្សាថ្មីមួយបានរកឃើញថាស្ត្រីមានលទ្ធភាពប្រើប្រាស់គ្រឿងយន្តតាមរយៈសមាជិកភាពសហគមន៍កសិកម្ម ជាងកសិករជាបុគ្គលម្នាក់ៗ[41]។

## តំណាងស្ត្រីនៅក្នុងរដ្ឋបាលកសិកម្ម

ក្នុងឆ្នាំ២០២០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានមន្ត្រីរាជការសរុបចំនួន ៥.៨៥០នាក់ ស្ត្រី ២៤.២៧% ក្នុងនោះស្ត្រីនៅថ្នាក់កណ្តាល ២៨,២១% និងនៅតាមខេត្តមាន ២០,៣៨%។ នៅទូទាំងអនុវិស័យផ្សេងៗគ្នា ស្ត្រីមាន ២៣,៥៥% នៃមន្ត្រីរាជការធ្វើការក្នុងវិស័យព្រៃឈើ ២៩,៨៣% ផលិតកម្មសត្វ ៣១,២៥ % កៅស៊ូ និង វិស័យជលផល ២៣,១៧% ។ ស្ត្រីមាន ៣៥,២៤% នៃមន្ត្រីសេវាផ្សព្វផ្សាយកសិកម្ម។ តំណាងស្ត្រីនៅក្នុងមុខតំណែងធ្វើការសម្រេចចិត្តនៅក្រសួង មានកម្រិតទាបជាប្រវត្តិសាស្ត្រសម្រាប់គ្រប់អនុវិស័យ។

## លទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាកម្មផ្សព្វផ្សាយកសិកម្ម និងការបណ្តុះបណ្តាល

សេវាផ្សព្វផ្សាយកសិកម្មសំដៅលើការផ្តល់ព័ត៌មាន ដំបូន្មាន ការបណ្តុះបណ្តាល និងចំណេះដឹងទាក់ទងនឹងកសិកម្ម ជលផល ឬផលិតកម្មសត្វ កៅស៊ូ ការកែច្នៃ និងទីផ្សារ។ សេវាផ្សព្វផ្សាយកសិកម្មកើតឡើងនៅក្នុងបរិបទសង្គម-វប្បធម៌ជាក់លាក់មួយ ហើយប្រសិទ្ធភាពនៃសេវាកម្មទាំងនេះទទួលបានឥទ្ធិពលពីលក្ខខណ្ឌសង្គម និងសក្តានុពលនយោបាយសង្គម ដែលបង្កើតទំនាក់ទំនងយេនឌ័រ។ វិសមភាពយេនឌ័រក្នុងការទទួលបានសេវាផ្សព្វផ្សាយកសិកម្ម និងជំនួយក្នុងប្រទេសកម្ពុជា គឺជាបញ្ហាប្រឈមរយៈពេលវែង។ ទោះបីជាមានការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការពង្រីកសេវាបន្ថែមសម្រាប់បុរស និងស្ត្រីក៏ដោយ សេវាផ្សព្វផ្សាយកសិកម្មនៅក្នុងប្រទេសកម្ពុជា នៅតែមានអ្នកផ្សព្វផ្សាយភាគច្រើនជាបុរស ដែលមាននិន្នាការផ្តោតលើការផ្តល់សេវាឱ្យបុរស។ ទោះជាយ៉ាងណាក៏ដោយ សេវានេះមានភាពប្រសើរឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ។ ក្នុងឆ្នាំ២០១៨ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំមានសរុបចំនួន១ ២២០នាក់ ស្រី៤១ ភាគរយ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ៩ ២៧៦នាក់ ស្រី៩ ភាគរយ (MAFF,២០១៩)។ ក្នុងឆ្នាំដដែល អ្នកផ្សព្វផ្សាយកសិកម្មខេត្ត ស្រុក ឃុំ ភូមិ និងកសិករចំនួន ២១ ៦២៧នាក់ បានផ្តល់ការបណ្តុះបណ្តាល ក្នុងនោះមានស្ត្រី ៣១ ភាគរយ[42]។ ដោយឡែក ក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ សេវាផ្សព្វផ្សាយបច្ចេកទេស ការថែទាំ ការការពារ ពាក់ព័ន្ធនឹងការចិញ្ចឹមសត្វ ក្រសួងក៏មានភ្នាក់ងារសុខភាពសត្វភូមិប្រចាំការតាមភូមិចំនួន៩ ២៦២នាក់ក្នុងនោះស្ត្រី៧២២នាក់ សហការជាមួយជំនាញនៅតាមបណ្តាខេត្ត ។

[41] Forthcoming study by CAVAC on gender and mechanisation

[42] MAFF, 2019

កត្តាប្រឈមដែលប៉ះពាល់ដល់សមត្ថភាពស្ត្រីខ្មែរនៅជនបទ ក្នុងការទទួលបានសេវាផ្សព្វផ្សាយកសិកម្ម បានគ្រប់គ្រាន់នៅមានកម្រិត ដូចជាទីកន្លែងផ្តល់សេវានៅឆ្ងាយ ភាពមិនច្បាស់លាស់ចំពោះកម្រិតអក្ខរកម្ម ពេលវេលា កង្វះជម្រើសថែទាំកុមារ ទំនួលខុសត្រូវក្នុងគ្រួសារ ការធ្វើដំណើរឆ្ងាយមិនបាន និងលក្ខណៈសង្គម-វប្បធម៌។ បុរស ដែលត្រូវបានគេចាត់ទុកជាមេគ្រួសារ ច្រើនតែជាអ្នកទទួលព័ត៌មានថ្មីៗដោយស្វ័យប្រវត្តិ។

## យេនឌ័រ សេវាហិរញ្ញវត្ថុ និងបំណុល

លទ្ធភាពទទួលបានឥណទានមានសារៈសំខាន់សម្រាប់ស្ត្រី និងបុរសក្នុងវិស័យកសិកម្ម មិនថាជាកសិករ ឬ ជាសហគ្រិន (ឧទាហរណ៍ កសិករចូលរួមក្នុងការងារបន្ថែមតម្លៃលើផលិតផលរបស់ពួកគេ ឬអាជីវកម្មផ្សេងទៀតនៅ ក្នុងខ្សែច្រវាក់តម្លៃកសិកម្ម)។ ជាទូទៅ ស្ត្រីមានលទ្ធភាពទទួលបានឥណទានពីស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI) និង ប្រភពក្រៅផ្លូវការផ្សេងទៀត។ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) រាយការណ៍ថា ៨០ភាគរយនៃអតិថិជនរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជាស្ត្រី[43]។ ទោះយ៉ាងណាក៏ដោយ ប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនេះមានទំហំ តូចជាង និងអត្រាការប្រាក់ខ្ពស់ជាងធនាគារពាណិជ្ជ។ ប៉ុន្តែនៅតែមានស្ត្រីនិងបុរសមួយចំនួន ដែលស្ថិតក្នុងស្ថាន ភាពសេដ្ឋកិច្ចសង្គមពីកម្រិតមធ្យមនិងទាប ទៅប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI) ដោយសារ ពួកគេមានការិយាល័យសាខានៅថ្នាក់ឃុំ ហើយតម្រូវការកម្ចី និងនីតិវិធីរបស់ពួកគេមានលក្ខណៈសាមញ្ញ។ ការសិក្សា របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ថ្មីៗនេះបានបង្ហាញថា ៩០ភាគរយនៃសហគ្រាសធុនតូច និងមធ្យម ដែល គ្រប់គ្រងដោយស្ត្រីនៅកម្ពុជា ទទួលបានផលចំណេញកាលពីឆ្នាំមុនៗ ប៉ុន្តែមានតែ៣ ភាគរយនៃសហគ្រិនស្ត្រីប៉ុណ្ណោះ ដែលទទួលបានឥណទានផ្លូវការ។

ការទទួលបានសេវាហិរញ្ញវត្ថុកាន់តែច្រើនសម្រាប់ស្ត្រី អាចរួមចំណែកជាច្រើនដល់ការពង្រឹងអំណាចផ្នែក សេដ្ឋកិច្ច។ តាមរយៈការសន្សំ ឥណទាន ធានារ៉ាប់រង និងការអប់រំហិរញ្ញវត្ថុ ស្ត្រីអាចកែលម្អសកម្មភាពសេដ្ឋកិច្ច របស់ពួកគាត់ បង្កើតនិងការពារទ្រព្យសម្បត្តិ ឈានចូលទីផ្សារ ធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ច និងបង្កើនឯករាជ្យ ភាពសេដ្ឋកិច្ច។ នៅកម្ពុជា ទោះបីជាសេវាហិរញ្ញវត្ថុមានសក្តានុពលជាច្រើននៅជនបទសម្រាប់ស្ត្រីក៏ដោយ ក៏នៅ មានវិធីច្រើនទៀតដែលត្រូវអនុវត្ត មុនពេលស្ត្រីមានលទ្ធភាពទទួលបានសេវាកម្មទាំងនេះស្មើៗគ្នា ឬទទួលបានអត្ថ ប្រយោជន៍ពេញលេញ។ ការសម្រេចបាននូវគោលដៅទាំងពីរនេះ មិនមែនអាស្រ័យតែលើការពង្រីកសេវាហិរញ្ញវត្ថុ ប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានប្រភេទសេវាកម្មហិរញ្ញវត្ថុជាក់លាក់ សម្រាប់ផ្តល់ដល់ស្ត្រីមកពីមជ្ឈដ្ឋាន និងបរិបទផ្សេងៗគ្នា និងតាមប្រភេទស្ថាប័នឬកម្មវិធីផ្សេងៗ។

កសិករជាស្ត្រីតែងតែខ្ចីធនធានឬទិញធាតុចូលនិងសម្ភារៈកសិកម្មជំពាក់អ្នកផ្គត់ផ្គង់ (គ្រាប់ពូជ ថ្នាំសម្លាប់ សត្វល្អិត ជីគីមី ម៉ាស៊ីនបូមទឹក) ដែលបន្ទាប់មកត្រូវបានគណនាជាតម្លៃរូបិយវត្ថុ ហើយសងបំណុលទាំងនោះទៅឱ្យ អ្នកផ្គត់ផ្គង់វិញ ក្នុងអំឡុងពេលប្រមូលផល ឬពេលលក់កសិផលបានភ្លាម។ ទោះជាយ៉ាងណាក៏ដោយ ទិន្នផលទាប ឬការខូចខាតដំណាំដែលបណ្តាលមកពីគ្រោះធម្មជាតិ អាចជំរុញឱ្យស្ត្រី ជាពិសេសស្ត្រីជាមេគ្រួសារ កាន់តែមាន ស្ថានភាពធ្ងន់ធ្ងរទាក់ទងនឹងការសងប្រាក់កម្ចីនិងកង្វះស្បៀងអាហារ។ បញ្ហាបំណុលជាមួយអ្នកផ្គត់ផ្គង់ធាតុចូល អាចជះឥទ្ធិពលដល់សមត្ថភាពស្ត្រីក្នុងការលក់ផលិតផលក្នុងតម្លៃល្អ ឬតាមរយៈសហគមន៍កសិកម្ម ឬការធ្វើ កសិកម្មតាមកិច្ចសន្យា។

កម្ពុជាបានទទួលស្គាល់ពីសារៈសំខាន់នៃបរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី។ ប្រទេសកម្ពុជាបានអំពាវនាវដល់ ស្ថាប័នហិរញ្ញវត្ថុទាំងអស់ ឱ្យពិចារណាពីគោលដៅអតិថិជន សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ជាពិសេសផ្តោតលើស្ត្រី

[43] CMA, 2021

ដែលជាមេគ្រួសារ។ ទោះបីជាមានការខិតខំប្រឹងប្រែងទាំងនេះក៏ដោយ បរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី នៅតែជាបញ្ហាប្រឈមនៅក្នុងប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍[44]។ ជាការពិត សហគ្រិនស្ត្រីកម្ពុជាមានតែបីភាគរយប៉ុណ្ណោះ ដែលទទួលបានឥណទានផ្លូវការ។ ការប៉ាន់ស្មានពីតម្រូវការឥណទានរបស់សហគ្រិនស្ត្រីដែលមិនទាន់ទទួលបាន មានចំនួន៤,២ពាន់លានដុល្លារ។ ស្ត្រីភាគច្រើននៅក្នុងប្រទេស ប្រើប្រាស់ធនធានផ្ទាល់ខ្លួន ដើម្បីចាប់ផ្តើមអាជីវកម្ម ឬពឹងផ្អែកលើប្រភពក្រៅផ្លូវការ និងការសន្សំដើម្បីពង្រីកអាជីវកម្មរបស់ពួកគេ។ ពួកគេមិនមានជម្រើសផ្សេងទៀតទេ ព្រោះស្ត្រីមិនបានទទួលសេវាពីធនាគារ[45]។

## យេនឌ័រ និងលទ្ធភាពទទួលបានដីធ្លី

គ្រួសារកសិករដែលដឹកនាំដោយបុរស មានសិទ្ធិទទួលបានដីកសិកម្ម ច្រើនជាងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។ ការស្ទាបស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ២០១៩ ដល់២០២០ បង្ហាញថាប្រហែល ១២ភាគរយ (៤៨៨ពាន់ហិកតា) នៃផ្ទៃដីកសិកម្មសរុប៣៣ ៨១៩ពាន់ហិកតា នៅក្នុងប្រទេសកម្ពុជា ត្រូវបានកាន់កាប់ដោយស្ត្រីជាមេគ្រួសារ ។ ភាពខុសប្លែកគ្នាមួយទៀតរវាងសិទ្ធិទទួលបានដីសម្រាប់បុរសជាមេគ្រួសារ និងស្ត្រីនៅក្នុងប្រទេសកម្ពុជា គឺចំនួនក្បាលដីកាន់កាប់។ ស្ថិតិជាតិបង្ហាញថា៤៩% នៃស្ត្រីជាមេគ្រួសារ មានដីតែមួយក្បាល ខណៈជាង ៦១% នៃបុរសជាមេគ្រួសារ មានដីច្រើនជាងមួយក្បាល[46]។ នៅក្នុងប្រទេសកម្ពុជា គ្រួសារកសិករសរុប៨៥% មានលទ្ធភាពទទួលបានដី កសិកម្ម ជាមធ្យមក្នុងមួយគ្រួសារចំនួន១,៤ ហិកតា។ បុរស១,៤ លាននាក់ ឬ៧៣% នៃអ្នកកាន់កាប់ដីទាំងអស់ ចំណែកស្ត្រីកាន់កាប់ដីតែ ០,៥ លាននាក់ ឬស្មើ២៧% (សមាមាត្រនៃអ្នកកាន់កាប់ជាបុរស ២៦៨នាក់ សម្រាប់អ្នកកាន់កាប់ជាស្ត្រី១០០នាក់)[47]។ ក្នុងចំណោមប្រជាជនដែលប្រកបមុខរបរកសិកម្មសរុប មានតំណាងស្ត្រី៥១ភាគរយដែលជាម្ចាស់កម្មសិទ្ធិដីកសិកម្ម ដែលក្នុងនោះស្ត្រីមានតែ ៣០.២% ធៀបនឹង បុរសជាម្ចាស់ដី ឬមានសិទ្ធិពេញលេញលើដីកសិកម្ម មានដល់ទៅ ៣៤,១%[48] ។

ក្នុងចំណោមផ្ទៃដីកសិកម្មប្រមាណ ២ លានហិកតា ប្រើប្រាស់ក្នុងរដូវវស្សា ២៧៣ ពាន់ហិកតាត្រូវបានប្រើប្រាស់ដោយស្ត្រីជាមេគ្រួសារនិង១ ៦៨២ ពាន់ហិកតាប្រើប្រាស់ដោយបុរសជាមេគ្រួសារ ។ នៅរដូវប្រាំងផ្ទៃដីកសិកម្មដែលប្រើប្រាស់មានចំនួនតិចជាង ៣៦ ពាន់ហិកតា ដែលប្រើប្រាស់ដោយស្ត្រីជាមេគ្រួសារ និង៣៣៦ពាន់ហិកតាប្រើប្រាស់ដោយបុរសជាមេគ្រួសារ។ ប្រភេទដីទូទៅទីពីរ (លើកលែងតែដីរដូវវស្សានិងប្រាំង) គឺសួនដំណាំ ដែលមានផ្ទៃដី ៤៤២ពាន់ហិកតា សម្រាប់មេគ្រួសារទាំងពីរភេទ (ស្ត្រីនិងបុរស)[49]។

បញ្ហាយេនឌ័រនៅក្នុងការចុះបញ្ជីដីធ្លីមានលទ្ធភាពទទួលបានព័ត៌មានអំពីដំណើរការចុះបញ្ជីដីធ្លី ការលំបាកសម្រាប់ស្ត្រីជាមេគ្រួសារក្នុងការទទួលបានឯកសារដែលបញ្ជាក់ថាពួកគេនៅលីវ និងអតុល្យភាពយេនឌ័រលើការគ្រប់គ្រងនិងការធ្វើសេចក្តីសម្រេចចិត្ត។ ស្ត្រីអាចប្រើប្រាស់ដីកសិកម្មដែលជាកម្មសិទ្ធរបស់បុរសប្រកបដោយប្រសិទ្ធភាព និងផលិតភាពបាន ទោះបីជាមានឧបសគ្គចំពោះសិទ្ធកាន់កាប់ដីក៏ដោយ ។

---

44 Women's World Banking, 2015

45 Exploring the Opportunities for Women-owned SMEs in Cambodia, 2021, page 6

46 Cambodia Inter-Censal Agriculture Survey 2018

47 Cambodia Inter-Censal Agriculture Survey 2018

48 FOA Rural Livelihood Informaiton System data, 2009, courtesy of FAO

49 NIS, 2020, page 39

## យេនឌ័រ និងលទ្ធភាពទីផ្សារ

ក្នុងទសវត្សរ៍ចុងក្រោយនេះ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការប្រើប្រាស់វិធីសាស្ត្រខ្សែច្រវ៉ាក់តម្លៃដោយភាគីពាក់ព័ន្ធផ្សេងៗ ក៏ដូចជាការប្រើប្រាស់ទូរស័ព្ទចល័តយ៉ាងទូលំទូលាយ និងបច្ចេកវិទ្យាឌីជីថលផ្សេងទៀត បានជួយសម្រួលដល់ការចូលទៅកាន់ទីផ្សារកាន់តែងាយស្រួល ការកំណត់តម្លៃ និងកាត់បន្ថយថ្លៃដើមទីផ្សារសម្រាប់ស្ត្រី និងបុរស។ វិធីសាស្ត្រខ្សែច្រវ៉ាក់តម្លៃពង្រឹងទំនាក់ទំនងអាជីវកម្មរវាងក្រុមអ្នកផលិត អ្នកផ្តល់សេវាកម្ម និងតួអង្គផ្សេងទៀត ដូចជាអ្នកកែច្នៃ និងអ្នកនាំចូល មិនមែនផ្តោតទាំងស្រុងតែទៅលើការធ្វើសកម្មភាពកសិកម្មនោះទេ។

ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា តាមរយៈក្រុមហ៊ុនកែច្នៃកសិផលខ្នាតធំ ឬពាណិជ្ជករដែលស្វែងរកការធានាឱ្យបាននូវការផ្គត់ផ្គង់ផលិតផលប្រកបដោយគុណភាព បានកើនឡើងជាយន្តការមួយនៃការធ្វើទំនើបកម្មខ្សែច្រវ៉ាក់តម្លៃកសិកម្មនៅកម្ពុជា។ គ្រោងការណ៍បែបនេះអាចជួយកសិករខ្នាតតូច អ្នកចិញ្ចឹមសត្វ សហគមន៍កសិកម្ម និងសហគមន៍នេសាទ មានលទ្ធភាពទទួលបានធាតុចូលកសិកម្ម ធានាបាននូវតម្លៃមានស្ថេរភាពជាងមុនសម្រាប់ផលិតផល ហើយទីបំផុតបង្កើនប្រាក់ចំណូលខ្ពស់ជាងមុន។ លើសពីនេះ វារួមចំណែកដោះស្រាយរបាំងបច្ចេកទេស និងការចំណាយលើមុខជំនួញ ដែលពាក់ព័ន្ធនឹងការបំពេញតម្រូវការទីផ្សារក្នុងស្រុកនិងអន្តរជាតិបានប្រសើរ។ ទោះជាបែបនេះក្តី ភស្តុតាងបង្ហាញថា ស្ត្រីតិចតួចដែលមានលទ្ធភាពចូលរួមធ្វើកសិកម្មតាមកិច្ចសន្យា[50]។

ភាពខុសគ្នាយេនឌ័រ មានឥទ្ធិពលលើគ្រប់សកម្មភាពនៃខ្សែច្រវ៉ាក់តម្លៃ។ អភិក្រមយេនឌ័រក្នុងការវិភាគក្នុងខ្សែច្រវ៉ាក់តម្លៃ អាចធ្វើឱ្យមានការពិចារណាអំពីលទ្ធភាពសកម្មភាពផលិតរបស់បុរសនិងស្ត្រីជាបុគ្គលម្នាក់ៗនិងជាក្រុម ព្រមទាំងភាពខុសគ្នានៃកាលានុវត្តភាពសម្រាប់ការធ្វើឱ្យប្រសើរឡើងក្នុងការបែងចែកសកម្មភាព និងរបៀបដែលទំនាក់ទំនងអំណាចយេនឌ័រ ប៉ះពាល់ដល់សេដ្ឋកិច្ចក្នុងចំណោមតួអង្គក្នុងខ្សែច្រវ៉ាក់នោះ។

ស្ត្រីកម្ពុជាបានផ្គត់ផ្គង់ទីផ្សារក្នុងស្រុកកាន់តែខ្លាំងឡើង នូវផលិតផលតាមប្រពៃណីនិងមានតម្លៃខ្ពស់ ប៉ុន្តែបើធៀបនឹងបុរស ស្ត្រីនៅតែប្រឈមនឹងគុណវិបត្តិមួយចំនួន រួមទាំងការការធ្វើដំណើរមិនបានឆ្ងាយ កម្រិតចំណេះដឹងទាបពុំសូវទទួលបានការបណ្តុះបណ្តាល មិនសូវមានលទ្ធភាពទទួលបានព័ត៌មានទីផ្សារនិងធនធានផលិត។ ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ស្ត្រីនៅមានកម្រិតទាបជាងបុរស រួមទាំងសុវត្ថិភាពក្នុងការធ្វើដំណើរ ត្រូវបានកំណត់ថាជាគម្លាតយេនឌ័រដ៏សំខាន់នៅក្នុងប្រទេសកម្ពុជាក្នុងការចូលទៅកាន់ទីផ្សារ។ ដោយសារឱកាសនាំចេញក្នុងវិស័យកសិកម្ម និងកែច្នៃកសិផលបន្តកើនឡើង បុរសមានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការទទួលបាននូវអត្ថប្រយោជន៍ ដោយសារគេមានលទ្ធភាពទទួលបានព័ត៌មានទីផ្សារ និងបណ្តាញកាន់តែច្រើន ធ្វើឱ្យពួកគេយល់កាន់តែច្បាស់ និងធ្វើការនៅក្នុងប្រព័ន្ធ។ ភ័ស្តុតាងក៏បង្ហាញដែរថា បុរសអាចនឹងកាន់កាប់ផលិតកម្ម និងទីផ្សារ នៅពេលដែលមានការចំណេញផ្នែកហិរញ្ញវត្ថុ ក្នុងការធ្វើដូច្នេះ[51]។

ស្ត្រីនៅក្នុងប្រទេសកម្ពុជាត្រូវការព័ត៌មានទីផ្សារដ៏គួរឱ្យទុកចិត្តបាន និងទាន់ពេលវេលាដើម្បីលក់ផលិតផល។ កម្ចីហិរញ្ញវត្ថុនិងឥណទានក៏មានសារៈសំខាន់ផងដែរ ក្នុងការជួយឱ្យស្ត្រីកសិករខ្នាតតូច អាចទិញធាតុចូល កែលម្អការធ្វើកសិកម្ម និងអភិវឌ្ឍន៍សហគ្រាសខ្នាតតូច ដើម្បីផ្តល់អំណាចដល់ខ្លួនឯងផ្នែកសេដ្ឋកិច្ចនិងផ្គត់ផ្គង់គ្រួសារ។ សកម្មភាពរួម ដូចជាតាមរយៈសហគមន៍កសិកម្ម ឬក្រុមអ្នកផលិត អាចដើរតួនាទីយ៉ាងសំខាន់សម្រាប់ស្ត្រីកសិករខ្នាតតូចក្នុងការបង្កើនផលិតភាព និងលទ្ធភាពទទួលបានទីផ្សារ ។ ជាងនេះទៅទៀត គំនិតផ្តួចផ្តើមដើម្បីជួយសម្រួលដល់លទ្ធភាពទីផ្សារ ចាំបាច់ត្រូវគិតគូរ និងដោះស្រាយបញ្ហាប្រឈមជាក់លាក់របស់យេនឌ័រ សម្រាប់ស្ត្រីកសិករខ្នាតតូច និង

---

[50] Unpublished literature review on contract farming by CAVAC, 2020

51 Forthcoming study on gender and agricultural mechanisation, CAVAC

សហគ្រិន កសិ-ពាណិជ្ជកម្ម។ ដូច្នេះការពង្រឹងលទ្ធភាពរបស់ពួកគេទៅកាន់ទីផ្សារ ទាមទារឱ្យមានការវិភាគខ្សែច្រវ៉ាក់តម្លៃគោលដៅនិងការធ្វើអន្តរាគមន៍ឱ្យចំគោលដៅ។

## យេនឌ័រ និងអនុវិស័យកសិកម្ម

### យេនឌ័រ និងផលិតកម្មដំណាំ

សម្រាប់ផលិតកម្មដំណាំ ស្ត្រីជាអ្នកដឹកនាំគ្រប់គ្រងមានតួនាទីជាច្រើន ដូចជាអ្នកផលិតខ្នាតតូច អ្នកប្រមូលទិញ អ្នកលក់រាយ អ្នកលក់ដុំនៅក្នុងខ្សែច្រវ៉ាក់ដំណាំ។ តាមរយៈការទទួលបានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ស្ត្រីបានចូលរួមក្នុងកម្មវិធីមួយចំនួនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងការផលិតដំណាំ ជាពិសេសគឺស្រូវ បន្លែ និងដំណាំកសិឧស្សាហកម្ម។ សកម្មភាពរួមមានការកែលម្អបច្ចេកវិទ្យា ការធ្វើបង្ហាញគ្រាប់ពូជថ្មីៗដើម្បីបង្កើនទិន្នផល និងការពិនិត្យតាមដានពូជស្រូវដើម្បីធានាគុណភាព។ សម្រាប់ដំណាំសាកវប្បកម្ម ដូចជាបន្លែ ផ្លែឈើ និងរុក្ខជាតិលម្អ ឬផ្កា ស្ត្រីចូលរួមក្នុងការបង្កើតអ្នកជំនាញកសិកម្មជាស្ត្រី ឬសហគ្រិនស្ត្រី តាមរយៈការបន្សុទ្ធពូជ ការអភិរក្សនិងការផលិត។ ទាក់ទងនឹងដំណាំឧស្សាហកម្ម ស្ត្រីបានចូលរួមក្នុងការផលិតពូជ ការបន្តពូជដំណាំ ដូចជាសណ្តែកសៀង សណ្តែកបាយ ដំឡូងមី ពោត ម្រេច និងចន្ទី។ មានសកម្មភាពពិសេសមួយគឺគម្រោងបង្កើតស្ត្រីកសិករឆ្នើម ដែលមានគោលបំណងលុបបំបាត់ឥរិយាបថអវិជ្ជមានចំពោះស្ត្រី ទាក់ទងនឹងតួនាទីរបស់ស្ត្រីក្នុងវិស័យកសិកម្ម ដើម្បីឱ្យស្ត្រីអាចទំនាក់ទំនង ពិភាក្សា និងផ្លាស់ប្តូរជំនាញកសិកម្មនិងការលំបាកនានា។ បណ្តាញស្ត្រី៥២១នាក់បានជួយឱ្យស្ត្រីចែករំលែកការអនុវត្តល្អៗជាមួយគ្នាតាមរយៈប្រព័ន្ធអនឡាញ និងស្វែងរកដំណោះស្រាយដើម្បីជំនះលើការលំបាកនានាក្នុងវិស័យកសិកម្ម។ សៀវភៅស្ត្រីកសិករឆ្នើម បានបង្ហាញរឿងរបស់កសិករស្ត្រីចំនួន១០០នាក់ អំពីតួនាទី និងការចូលរួមរបស់ពួកគាត់ក្នុងវិស័យកសិកម្ម។

### យេនឌ័រ និងព្រៃឈើ

សកម្មភាពព្រៃឈើនៅកម្ពុជា ជាធម្មតាមានភាពខុសគ្នាទាក់ទងនឹងយេនឌ័រ៖ ជារឿយៗបុរសចាប់អារម្មណ៍លើអនុផលព្រៃឈើសម្រាប់គោលបំណងពាណិជ្ជកម្ម ចំណែកស្ត្រីមានទំនោរទៅរកផលិតផលអនុផលព្រៃឈើ (NTFP) (ស្លឹកឈើព្រៃ ផ្តៅ ដំណាំមើម ឬស្សី រុក្ខជាតិឱសថ គ្រាប់ពូជ គ្រាប់ និងផ្សិត) សម្រាប់ការចិញ្ចឹមជីវិត ដូចជាអាហារ និងសម្រាប់បង្កើតប្រាក់ចំណូល។ ស្ត្រីជាញឹកញាប់មានចំណេះដឹងច្រើនអំពីស្លឹកឈើព្រៃ ប្រភេទព្រៃឈើ និងការប្រើប្រាស់សម្រាប់គោលបំណងផ្សេងៗ ព្រមទាំងការយល់ដឹងដ៏ល្អអំពីការអភិរក្ស។ ការយល់ដឹងនេះអាចផ្តល់នូវឱកាសដ៏ល្អសម្រាប់ទាញយកចំណេះដឹង និងជំនាញរបស់ស្ត្រី ដើម្បីគាំទ្រសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុទាក់ទងនឹងព្រៃឈើ ដែលកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ហើយនៅពេលអនាគត អាចនឹងផ្តល់ភាគលាភផ្នែកសេដ្ឋកិច្ច ឬអត្ថប្រយោជន៍ផ្សេងៗទៀត។ នៅក្នុងប្រទេសកម្ពុជា ជាពិសេសស្ត្រីដើរតួនាទីចម្បងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ដំណើរការ និងសកម្មភាពទីផ្សារអនុផលព្រៃឈើ( NTFP) ។

ក្នុងឆ្នាំ ២០១៦ ប្រជាជន១៤២ ៩៤១ គ្រួសាររស់នៅក្នុងសហគមន៍ព្រៃឈើចំនួន ៥៨០ ដែលមានផ្ទៃដីព្រៃចំនួន៤៧០ ៩៧០ហិកតា។ ជំរឿនឆ្នាំ ២០១៩[52] បានកត់ត្រាថាស្ត្រីមានចំនួន ៤១,៤ ភាគរយនៃអ្នកធ្វើការក្នុងព្រៃឈើ រួមទាំងសេវាកម្មប្រមាញ់ កាប់ឈើ ការប្រមូលអនុផលព្រៃឈើ និងការគាំទ្រសេវាកម្មទាក់ទងនឹងព្រៃឈើផ្សេងទៀត។ ការប្រមូលអនុផលព្រៃឈើមានចំនួន៦៥,១ ភាគរយ នៃការងារនេះ មាន៤៥,៧ ភាគរយជាស្ត្រី[53]។ ផ្អែកលើមូលដ្ឋានទិន្នន័យឃុំឆ្នាំ២០១៩ មានការប៉ាន់ប្រមាណថា មានគ្រួសារសរុបចំនួន២២៩ ០៩៤ គ្រួសារ ក្នុងនោះ

[52] General Population Census Cambodia 2019

[53] UN Women and CDRI, 2021

មានស្ត្រី៥២១ ៨៥៩នាក់ បានចូលរួមក្នុងសហគមន៍ព្រៃឈើ ប្រមូលផលព្រៃឈើ និងប្រមាញ់ដើម្បីចិញ្ចឹមជីវិតរបស់ពួកគាត់។ របាយការណ៍អង្គការសហប្រជាជាតិដើម្បីស្ត្រី និងវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជា ២០២១ បានសរសេរថា គ្រួសារដែលមានស្ត្រីជាមេគ្រួសារចំនួន៥៣ភាគរយ បានចូលរួមក្នុងសកម្មភាពព្រៃឈើ និងប្រមាញ់ក្នុងប្រទេសកម្ពុជា ទាបជាងគ្រួសារដែលមានបុរសជាមេគ្រួសារ ៥៩ ភាគរយ[54]។

វិស័យព្រៃឈើកំពុងរងផលប៉ះពាល់ដោយការផ្លាស់ប្តូរគម្របព្រៃឈើ ការបង្កើនការផ្លាស់ប្តូរព្រៃឈើ ការផ្លាស់ប្តូរការប្រើប្រាស់ដី ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើសហគមន៍ព្រៃឈើ និងការគំរាមកំហែងដោយការកើនឡើងកម្ពស់ទឹកសមុទ្រ។ អង្គការសហប្រជាជាតិដើម្បីស្ត្រី និងវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជា ២០២១ បង្ហាញថា គម្របព្រៃឈើរបស់ប្រទេសកម្ពុជាបានកាត់បន្ថយពី៧៣,០៤ភាគរយ មកនៅត្រឹម ៤៩,៤៨ ភាគរយ ចន្លោះឆ្នាំ ១៩៦៥ និង ២០១៤។ ចំណុចនេះប៉ះពាល់ដល់សហគមន៍ជនបទ ដែលពឹងផ្អែកលើធនធានព្រៃឈើ ជាសំណាញ់សុវត្ថិភាព ឬជាប្រភពបន្ថែមនៃអាហារូបត្ថម្ភនិងថ្នាំ ជាពិសេសក្នុងគ្រាមានវិបត្តិ និងមានផលប៉ះពាល់ទៅលើស្ត្រី។ តាមអង្គការសហប្រជាជាតិដើម្បីស្ត្រី និងវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជាឆ្នាំ២០២១បង្ហាញថា ផលប៉ះពាល់នៃការកាប់បំផ្លាញព្រៃឈើ និងការរិចរិលព្រៃឈើ លើស្ត្រីនិងបុរសមានភាពខុសប្លែកគ្នា ដោយសារស្ត្រីចំណាយពេលវេលាច្រើនក្នុងការប្រមូលអុស ឬអនុផលព្រៃឈើ នៅពេលដែលព្រៃឈើត្រូវបានបំផ្លាញ។

លទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានព័ត៌មាន និងការអប់រំ និងការចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តមានកម្រិតខ្លាំងណាស់។ តួនាទីរបស់ស្ត្រីក្នុងខ្សែច្រវ៉ាក់តម្លៃព្រៃឈើនៅមានកម្រិត ជាទូទៅមានការគាំទ្រតិចតួច។ ស្ត្រីមិនមានលទ្ធភាពដូចបុរស ក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មី ឥណទាន ការបណ្តុះបណ្តាល ដីសមស្រប ទីផ្សារ និងការសម្រេចចិត្ត។ ដោយសារបទដ្ឋាន និងឥរិយាបទសង្គម សកម្មភាពព្រៃឈើ និងការប្រមាញ់ត្រូវបានគេសន្មត់ថាជាអាជីវកម្មរបស់បុរស។ ឧទាហរណ៍ ស្ត្រីមិនត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងគណៈកម្មាធិការសហគមន៍ព្រៃឈើទេ ព្រោះវាមិនសមរម្យសម្រាប់ស្ត្រីក្នុងការបំពេញភារកិច្ចរបស់ពួកគេនៅពេលយប់ និងការព្រួយបារម្ភអំពីសុវត្ថិភាពស្ត្រី។ ការស្រាវជ្រាវសំណូមពរថា ការចូលរួមរបស់ស្ត្រី និងដំណើរការបរិយាប័ន្នយេនឌ័រ នឹងអាចដោះស្រាយបញ្ហាកង្វល់នានាទាក់ទងនឹងការគ្រប់គ្រងព្រៃឈើ និងបរិស្ថានប្រកបដោយនិរន្តរភាព[55]។

## យេនឌ័រ និងផលិតកម្មកៅស៊ូ

ការអភិវឌ្ឍផលិតកម្មកៅស៊ូមានការរីកចម្រើនខ្លាំង និងរឹងមាំនៅក្នុងប្រទេសកម្ពុជា ដោយសារការកើនឡើងនៃការប្រើប្រាស់នៅក្នុងពិភពលោក និងតម្លៃ រួមជាមួយនឹងសក្តានុពលដីដ៏សមស្របទៅនឹងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់។ នៅក្នុងប្រទេសកម្ពុជា កម្មសិទ្ធិចម្ការកៅស៊ូអាចបែងចែកជាបីប្រភេទ៖ ចម្ការរបស់រដ្ឋ ដីកម្មសិទ្ធិគ្រួសារ និងចម្ការឧស្សាហកម្មឯកជន។

នាពេលបច្ចុប្បន្ន ស្ត្រីតំណាងឱ្យ ៣០ ភាគរយនៃកម្លាំងផលិតកម្មកៅស៊ូ ១០ ភាគរយជាម្ចាស់ និង២០ភាគរយជាកម្មករ[56]។ វិធីសាស្ត្រណែនាំការងារសមរម្យនៅជនបទ ការពង្រឹងសមាគមស្ត្រី និងសិទ្ធិការងារយេនឌ័រដែលងាយរងគ្រោះ (លទ្ធភាពទទួលបានការងារ ប្រាក់ឈ្នួលស្មើគ្នា និងការអភិវឌ្ឍសមត្ថភាពស្មើគ្នា) អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងអនុវិស័យកៅស៊ូ និងលើកកម្ពស់តំណាង និងការចូលរួមយ៉ាងសកម្មរបស់ពួកគាត់។

---

[54] NIS, 2020
[55] UN Women and CDRI, 2021
[56] Annual report, 2020, of Directorate of Rubber Development, MAFF

## យេនឌ័រ និងផលិតកម្មសត្វ

ស្ត្រីនៅទីជនបទភាគច្រើន បានចូលរួមក្នុងការចិញ្ចឹមសត្វតូចៗដូចជាបក្សី (មាន់ ទា) និងជ្រូក ដែលជាប្រភពសំខាន់នៃអាហារ និងប្រាក់ចំណូលបន្ថែមរបស់គ្រួសារ។ សម្រាប់ស្ត្រីក្រីក្រជាច្រើន ការចិញ្ចឹមសត្វគឺជាការសន្សំ ការធានារ៉ាប់រងប្រឆាំងនឹងគ្រោះថ្នាក់ ជំងឺ ការស្លាប់ និងគ្រោះធម្មជាតិ ដូចជាគ្រោះរាំងស្ងួត។ ផលិតផលអាហារដែលមានប្រភពពីសត្វ ភាគច្រើនត្រូវបានផលិតដោយក្រុមផលិតខ្នាតតូចៗ ជាស្ត្រី និងលក់នៅក្នុងទីផ្សារ។ ទោះជាយ៉ាងណាក៏ដោយ អន្តរាគមន៍ខ្សែច្រវាក់តម្លៃមានទំនោរទៅរកបុរស ដោយសារតែពួកគាត់គ្រប់គ្រងថវិកាដែលបានពីការលក់។ ស្ត្រីមិនត្រូវបានគេទទួលស្គាល់ និងទទួលបានអត្ថប្រយោជន៍តិចជាង បើទោះជាពួកគេធ្វើការច្រើនក៏ដោយ។

ចំនួនគ្រួសារសរុបដែលប្រកបរបរចិញ្ចឹមសត្វ និងបក្សី មានប្រមាណជិត១ ៩៥៧ពាន់ (៥៤ ភាគរយនៃគ្រួសារទាំងអស់)។ បើប្រៀបធៀបតាមភេទ បុរសដែលជាមេគ្រួសារមាន៥៦,៨ ភាគរយ ច្រើនជាងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ៤២,៩ ភាគរយចិញ្ចឹមសត្វ និងបក្សី។ ប្រភេទសត្វ និងបក្សី ដែលចិញ្ចឹមច្រើនបំផុតគឺមាន់ ដែលមានចំនួនប្រហែល ៥៧ ភាគរយ ទា ៣៥ ភាគរយ និងគោក្របី ៤ ភាគរយ។ ជាទូទៅ ស្ត្រីចិញ្ចឹមបក្សី បុរសចិញ្ចឹមគោក្របី និងជ្រូក[57]។

## យេនឌ័រ និងជលផល

បច្ចុប្បន្នវិស័យជលផលបានរួមចំណែក១២ភាគរយ ដល់ផលិតផលក្នុងស្រុកសរុប (អង្គការសហប្រជាជាតិដើម្បីស្ត្រី និងវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជា )។ នៅក្នុងប្រទេសកម្ពុជា ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យជលផល ហើយវិសាលភាពនៃការចូលរួមរបស់ពួកគាត់នៅក្នុងខ្សែច្រវាក់តម្លៃវារីវប្បកម្ម គឺមានភាពទូលំទូលាយ។

ស្ត្រីដើរតួយ៉ាងសំខាន់ក្នុងទិដ្ឋភាពផ្សេងៗនៃសកម្មភាពជលផល វារីវប្បកម្ម និងក្រោយការប្រមូលផលនេសាទ ជាពិសេសការកែច្នៃ និងទីផ្សារត្រី ប៉ុន្តែនៅតែមិនត្រូវបានគេមើលឃើញ និងមានតំណាងតិចតួចនៅក្នុងវិស័យនេះ។ របាយការណ៍ស្តីពី "ការវិភាគយេនឌ័រក្រោយការប្រមូលផលនេសាទនៅប្រទេសកម្ពុជា" បានរកឃើញថាសហគ្រាសធុនតូច និងមធ្យម ពាក់ព័ន្ធក្រោយការប្រមូលផលនេសាទមានប្រមាណ៧៤ភាគរយ (MSMEs) ជាកម្មសិទ្ធិរបស់ស្ត្រី។ ស្ត្រីបានគ្រប់គ្រងផ្នែកកែច្នៃ ដែលមានចំនួន៥៤ ភាគរយនៃផលិតផលផ្អាប់ (fermented) ៦៧ភាគរយនៃផលិតផលត្រីសមុទ្រ និង៧៥ ភាគរយនៃផលិតកម្មទឹកត្រី និងពាក់កណ្តាលនៃការផលិតបង្គាក្រៀម។ ស្ត្រីគ្រប់គ្រងកិច្ចការភាគច្រើនដែលតម្រូវឱ្យមានជំនាញជាក់លាក់ ដូចជាការទិញវត្ថុធាតុដើម ការជ្រើសរើសត្រី ការចាត់ថ្នាក់ប្រភេទត្រី ការសម្អាត ការប្រឡាក់អំបិល ការធ្វើប្រហុក ឬផ្អក និងការឆ្អើរត្រី[58]។

ទោះបីជាមានការរួមចំណែកជាក់ស្តែងរបស់ស្ត្រីនៅគ្រប់ដំណាក់កាលនៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់ និងការចូលរួមរបស់ពួកគាត់ក្នុងការលក់ និងកែច្នៃត្រីក៏ដោយ តួនាទីរបស់ស្ត្រីត្រូវបានសន្មតថាជា "ការពង្រីកការងារផ្ទះ" ដូច្នេះហើយត្រូវបានគេឱ្យតម្លៃទាបក្នុងន័យសេដ្ឋកិច្ច។ ដោយសារបញ្ហាប្រឈមយេនឌ័រក្នុងការធ្វើដំណើរឆ្ងាយ ការប្រើពេលវេលា លទ្ធភាពទទួលបានការអប់រំ និងការកសាងសមត្ថភាព និងឱកាសអាជីវកម្ម មានចំនួនកំណត់សម្រាប់ស្ត្រី ។ អាស្រ័យហេតុនេះ ការគាំទ្របន្ថែមលើផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុគឺជាតម្រូវការចាំបាច់ ដើម្បីផ្តល់សិទ្ធិអំណាច

[57] NIS, 2020

[58] Article in Phnom Penh Post, dated 25 June, 2021

ដល់ស្ត្រីក្នុងវិស័យជលផល ក្រោយការប្រមូលផល រួមទាំងការធ្វើឱ្យមានភាពប្រសើរឡើងនូវបរិក្ខារ វឌ្ឍនភាពបច្ចេកវិទ្យាក៏ដូចជាការពង្រឹងជំនាញ និងចំណេះដឹង[59]។

គ្រួសារប្រហែល ៤៧ពាន់គ្រួសារ តិចជាង ១ ភាគរយ នៃគ្រួសារទាំងអស់នៅក្នុងប្រទេសកម្ពុជា បានចូលរួមក្នុងសកម្មភាពវារីវប្បកម្មក្នុងឆ្នាំ ២០១៩-២០២០។ ទោះជាយ៉ាងណាក៏ដោយ គ្រួសារដែលមានមេគ្រួសារជាស្ត្រី (២៣ ភាគរយ) តិចជាងគ្រួសារដែលមានមេគ្រួសារជាបុរស (៣៨ ភាគរយ) ចូលរួមក្នុងសកម្មភាពនេសាទ[60]។

## ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

ឱកាសនិងការចាប់ផ្តើមនៃការអភិវឌ្ឍយេនឌ័រក្នុងវិស័យកសិកម្ម ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌនៃការប្តេជ្ញាចិត្តគោលនយោបាយ និងក្របខ័ណ្ឌច្បាប់របស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញការគាំទ្រយ៉ាងច្រើនសម្រាប់សមភាពយេនឌ័រ ចាប់តាំងពីមានសន្តិភាពឡើងវិញ។ សមភាពរវាងបុរសនិងស្ត្រីមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣។ ការប្តេជ្ញាចិត្តនេះត្រូវបានបំពេញបន្ថែមដោយការផ្តល់សច្ចាប័នរបស់កម្ពុជា លើអនុសញ្ញានៃការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ក្នុងឆ្នាំ ១៩៩២ និងការចុះហត្ថលេខាលើ "វេទិកាសម្រាប់សកម្មភាព" បានយល់ព្រមនៅឯសន្និសីទពិភពលោកលើកទី៤ ស្តីពីស្ត្រី ឆ្នាំ ១៩៩៥ នៅទីក្រុងប៉េកាំង។ នារីរតនៈ (NR) ដែលជាផែនការយុទ្ធសាស្ត្រសម្រាប់សមភាពយេនឌ័រ បានគូសបញ្ជាក់អំពីភាពពាក់ព័ន្ធយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីលើគ្រប់វិស័យ។ ក្រសួងកិច្ចការនារី បានចាប់ផ្តើមដំណើរការរៀបចំផែនការនារីរតនៈក្នុងឆ្នាំ ២០១៤។

សមភាពយេនឌ័រគឺជាប្រធានបទទាក់ទងដ៏សំខាន់មួយ នៃគោលនយោបាយសេដ្ឋកិច្ចសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី III របស់រាជរដ្ឋាភិបាល (២០១៤-២០១៨) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ក៏ដូចជាកម្មវិធីជាតិរយៈពេល ១០ ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រចតុកោណ បញ្ជាក់អំពីតម្រូវការដើម្បី "លើកកម្ពស់ស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសង្គម និងសេដ្ឋកិច្ចកម្ពុជា"។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មានចែងក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs)។

គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការកសិកម្មទទួលស្គាល់តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងវិស័យនេះ ក្នុងដំណើរការផលិតកម្ម និងការអភិរក្សបរិស្ថាន។ ផែនការមេនៃវិស័យកសិកម្មឆ្នាំ ២០៣០ រួមជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ ផែនការសកម្មភាពសម្រាប់កសិកម្ម និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ទទួលស្គាល់តួនាទីយេនឌ័រ ដែលខុសប្លែកគ្នា និងរួមបញ្ចូលបទប្បញ្ញត្តិដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងដំណើរការនៃការអនុវត្ត (អង្គការសហប្រជាជាតិដើម្បីស្ត្រី និងវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជា ឆ្នាំ២០២១) ។

រដ្ឋាភិបាលប្តេជ្ញាលើកកម្ពស់ គិតគូរអំពីយេនឌ័រក្នុងវិស័យព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិ។ ទោះជាយ៉ាងណាក៏ដោយ ការបញ្ជ្រាបយេនឌ័រទៅក្នុងការអនុវត្តគម្រោងនៅតែជាបញ្ហាប្រឈម ដោយសារកង្វះការគាំទ្រពីអ្នកផ្តល់ជំនួយ (អង្គការសហប្រជាជាតិដើម្បីស្ត្រី និងវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍនកម្ពុជា ឆ្នាំ២០២១) ។

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រជលផល ទទួលស្គាល់តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងអនុវិស័យនេះ។ រដ្ឋបាលជលផលបានអនុម័តលើផែនការអនុវត្តសកម្មភាពសមភាពយេនឌ័រក្នុងវិស័យជលផលឆ្នាំ ២០១៦-២០២០ ដើម្បីគាំទ្រ

---

[59] ibid

[60] Report of Cambodia Socio-Economic Survey, 2019 -2020, National Institute of Statistics, MoP

ដល់ការអនុវត្តគោលនយោបាយបញ្ជ្រាបយេនឌ័ររបស់ក្រសួង (អង្គការសហប្រជាជាតិដើម្បីស្ត្រី និងវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជា ឆ្នាំ២០២១)។ បច្ចុប្បន្ននេះ ក្រសួងកំពុងរៀបចំផែនការសកម្មភាពមួយ សម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល ឆ្នាំ ២០២២ – ២០២៦ ជាមួយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។

ក្របខ័ណ្ឌគោលនយោបាយដ៏ទូលំទូលាយ គាំទ្រដល់ការបញ្ជ្រាបយេនឌ័រទាក់ទងនឹងវិស័យកសិកម្ម និងអនុវិស័យផងដែរ។ ឧទាហរណ៍ ផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCAP) ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) គោលនយោបាយជាតិនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET) បានបញ្ជ្រាបយេនឌ័រ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយផ្សេងទៀត បានបញ្ចូលតិចតួច ឬមិនបានលើកឡើងអំពី "យេនឌ័រ" ឬ "ស្ត្រី" ហើយក្របខ័ណ្ឌគោលនយោបាយទាំងមូលចាំបាច់ត្រូវពង្រឹងជាបន្តបន្ទាប់ ដើម្បីដោះស្រាយសមភាពយេនឌ័រ ផ្តត់គំនិតយេនឌ័រ និងរួមបញ្ចូលទិន្នន័យបែងចែកតាមភេទ។ ការសម្របសម្រួល និងការធ្វើសមាហរណកម្មកាន់តែធំ រួមទាំងការកសាងសមិទ្ធផលដែលកំពុងបន្ត និងការបង្កើនធនធាន រួមទាំងកំណើននៃការគាំទ្រ និងជាប់លាប់ពីអ្នក ផ្តល់ជំនួយក្នុងការអនុវត្តកម្មវិធី និងពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការបំពេញអាណត្តិសមភាពយេនឌ័ររបស់ខ្លួន (អង្គការសហប្រជាជាតិដើម្បីស្ត្រី និងវិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជា) ឆ្នាំ២០២១។

យន្តការថ្នាក់ជាតិរបស់ប្រទេសកម្ពុជា ក្នុងការបញ្ជ្រាបយេនឌ័រនៅតាមស្ថាប័ន រួមមានធាតុសំខាន់ៗចំនួនបួននៅក្នុងក្រសួងពាក់ព័ន្ធ ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ (TWG-G) និងក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAG) និងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ ដែលប្រតិបត្តិការថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។

## ៣. សមិទ្ធិផលនៃការអនុវត្តគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឆ្នាំ ២០១៦ - ២០២០

ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងដៃគូ ទទួលបានសមិទ្ធិផលគួរឱ្យចាប់អារម្មណ៍ទាក់ទងនឹងគោលបំណង និងលទ្ធផលរំពឹងទុកនិមួយៗ នៅក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យកសិកម្ម ។ ប៉ុន្តែ នៅមានការលំបាកមួយចំនួនទាក់ទងនឹងផ្នត់គំនិតសង្គមចំពោះស្ត្រី កង្វះការគាំទ្រពីថ្នាក់ដឹកនាំ កង្វះធនធាន សមត្ថភាពក្នុងការបញ្ជ្រាប និងការវិភាគយេនឌ័រនៅមានកម្រិត កង្វះការសម្របសម្រួល និងកិច្ចសហការជាមួយភ្នាក់ងារអភិវឌ្ឍន៍វិស័យកសិកម្ម។

នៅក្នុងដំណើរការរៀបចំធ្វើបច្ចុប្បន្នគោលនយោបាយយេនឌ័រនេះ ក្រុមការងារយេនឌ័រ និងកុមាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានធ្វើការវាយតម្លៃអំពីសមិទ្ធិផល ដោយធៀបទៅនឹងគោលបំណងនៃគោលនយោបាយយេនឌ័រសម្រាប់រយៈពេលប្រាំឆ្នាំកន្លងមក តាមរយៈកិច្ចពិគ្រោះយោបល់ និងការពិនិត្យមើលឯកសារសំខាន់ៗ និងការសំយោគឯកសារលើកទីពីរដែលមានព័ត៌មានពាក់ព័ន្ធនឹងបរិបទនេះ (secondary literature) ។

សមិទ្ធផលចម្បងៗសម្រាប់រយៈពេលប្រាំឆ្នាំ និងចំណុចដែលត្រូវពង្រឹង រួមមាន៖

**គោលបំណងទី១. លើកកម្ពស់សិទ្ធអំណាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី តាមរយៈការបង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបាននូវទំនិញ និងសេវាកម្មសម្រាប់ការអភិវឌ្ឍកសិកម្ម និងទីផ្សារ**

- ស្ត្រីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបាននូវព័ត៌មាន ជំនាញបច្ចេកទេស ធនធាន និងបច្ចេកវិទ្យា រួមទាំងបច្ចេកវិទ្យាឌីជីថល ដែលបានណែនាំតាមរយៈក្រុមអាជីវកម្ម និងសហគមន៍កសិកម្ម ដើម្បីគាំទ្រកសិករក្នុងការទទួលបាននូវព័ត៌មាន និងសេវាកម្មកសិកម្មដែលប្រកបដោយបច្ចុប្បន្នភាព
- ស្ត្រីមានលទ្ធភាពប្រសើរជាងមុនក្នុងការប្រើប្រាស់សេវាគ្រឿងយន្តកសិកម្ម តាមរយៈការចូលជាសមាជិកសហគមន៍កសិកម្ម
- ស្ត្រីមានលទ្ធភាពទទួលបានឥណទានតាមរយៈក្រុមសន្សំប្រាក់ សហគមន៍កសិកម្ម និងមួយចំនួនទៀតទទួលបានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ស្ត្រីទទួលបានព័ត៌មាន និងការបណ្តុះបណ្តាល។ ក្នុងចំណោមកសិករចំនួន១១៧ ០១០នាក់ដែលបានទទួលការបណ្តុះបណ្តាលមាន ៤៦ភាគរយ ជាស្ត្រី
- កសិករនិងក្រុមអ្នកផលិតបានរៀបចំ និងបង្កើនយន្តការយ៉ាងល្អ សម្រាប់ពង្រឹងកាលានុវត្តភាព និងលទ្ធផលដល់ស្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងដៃគូបានខិតខំប្រឹងប្រែងក្នុងការពង្រឹងឱ្យស្ត្រីមានលទ្ធភាពទីផ្សារ។

**គោលបំណងទី២. ពង្រឹងសមត្ថភាព ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម**

- ការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការដាក់បញ្ចូលយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការសម្រាប់អនុវិស័យនានា
- សមត្ថភាពយេនឌ័រសម្រាប់អនុវត្តការប្តេជ្ញាចិត្ត ត្រូវបានពង្រឹងនៅក្នុងវិស័យ រួមទាំងការដាក់បញ្ចូលយេនឌ័រទៅក្នុងកម្មវិធីបណ្តុះបណ្តាលកសិកម្មនៅតាមគ្រឹះស្ថានអប់រំកសិកម្ម ប៉ុន្តែការពង្រឹងសមត្ថភាពបន្ថែមទៀតគឺមានភាពចាំបាច់ តាមរយៈការបង្កើនការសម្របសម្រួល
- ដៃគូអភិវឌ្ឍន៍បានចាត់ទុកថាគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ មានសារសំខាន់នៅក្នុងការរៀបចំ និងអនុវត្តកម្មវិធី។ ក្រសួងគួរចាត់តាំងមន្ត្រីយេនឌ័រឱ្យចូលរួមក្នុងក្រុមអនុវត្តគម្រោង
- សកម្មភាពតាមដាន មានភាពប្រសើរ ដោយមានទិន្នន័យបែងចែកតាមភេទ ប៉ុន្តែក្រសួងគួរប្រមូលទិន្នន័យគុណភាព និងធ្វើការវិភាគឱ្យបានប្រសើរជាងនេះ
- មន្ត្រីជាស្ត្រី និងបុរសនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានលទ្ធភាពទទួលបានការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស ប៉ុន្តែស្ត្រីនៅតែជួបឧបសគ្គមួយចំនួន។

**គោលបំណងទី៣. បង្កើនភាពជាតំណាង និងការចូលរួមស្មើភាពគ្នាទាំងស្ត្រី និងបុរសក្នុងវិស័យកសិកម្ម**

- ការលើកកម្ពស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត មានការប្រែប្រួលក្នុងរយៈពេលប្រាំឆ្នាំ ប៉ុន្តែជាទូទៅសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺនៅមានកម្រិតនៅឡើយ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងដៃគូបានខិតខំជាបន្តបន្ទាប់ក្នុងការពង្រឹងសម្លេងរបស់ស្ត្រី នៅក្នុងវិស័យកសិកម្ម នៅកម្រិតសហគមន៍
- ការលើកកម្ពស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត នៅគ្រឹះស្ថានកសិកម្ម នៅតែជាបញ្ហាប្រឈម

- មិនមានភាពរីកចម្រើនចំពោះការចុះឈ្មោះសិក្សា ឬការបញ្ចប់ការសិក្សារបស់សិស្សជាស្ត្រី នៅក្នុងមុខជំនាញកសិកម្ម ប៉ុន្តែមានភាពខុសប្លែកគ្នាក្នុងចំណោមគ្រឹះស្ថានកសិកម្មទាំងបី។

ព័ត៌មានលម្អិតអំពីលទ្ធផលនៃគោលបំណងនិមួយៗ មាននៅក្នុងឧបសម្ព័ន្ធទី ១។

## ៤. គោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឆ្នាំ ២០២២ - ២០២៦

ចក្ខុវិស័យ បេសកម្ម និងគោលបំណង

ចក្ខុវិស័យ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូទាំងអស់ចូលរួមអភិវឌ្ឍវិស័យកសិកម្មឱ្យមានភាពទាក់ទាញ និងផ្តល់ផលចំណេញសម្រាប់ស្ត្រីនិងបុរស ហើយស្ត្រីទទួលបានផលប្រយោជន៍ប្រកបដោយសមធម៌

បេសកម្ម៖ ពង្រឹងឥទ្ធិពលសមភាពយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅគ្រប់អនុវិស័យ ដោយបន្ថែមតម្លៃប្រកបដោយប្រសិទ្ធភាព និងសមធម៌

គោលបំណង

**គោលបំណងទី១. លើកកម្ពស់សិទ្ធអំណាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រីតាមរយៈការបង្កើនលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបាន និងប្រើប្រាស់ធនធាននិងសេវាកម្ម និងកែលម្អលក្ខខណ្ឌនានា ប្រកបដោយសមធម៌សម្រាប់ស្ត្រីក្នុងវិស័យកសិកម្ម**

លទ្ធផល

ក. ស្ត្រីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបាន និងប្រើប្រាស់នូវធាតុចូលកសិកម្ម ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា

ខ. ស្ត្រីមានលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបាននូវព័ត៌មាន ចំណេះដឹង និងសេវាកម្មជំនាញបច្ចេកទេស ដើម្បីគាំទ្រដល់ការងាររបស់ពួកគាត់ក្នុងវិស័យកសិកម្ម រួមទាំងវិស័យដែលលេចធ្លោមានដូចជា ប្រពលវប្បកម្មដំណាំ ពិពិធកម្ម និងកាលានុវត្តភាពដែលទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ

គ. ស្ត្រីមានបណ្តាញកាន់តែរឹងមាំ ជាមួយនឹងទីផ្សារតាមបែបប្រពៃណី និងទីផ្សារថ្មីៗ

ឃ. បន្ទុកការងាររបស់ស្ត្រីជនបទ ត្រូវបានកាត់បន្ថយ ហើយការចូលរួមរបស់ពួកគាត់ត្រូវបានទទួលស្គាល់និងផ្តល់តម្លៃ ច្រើនជាងមុន ។

**គោលបំណងទី២. ពង្រឹងសមត្ថភាព ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម**

លទ្ធផល

ក. តម្រូវការនិងកង្វល់របស់ស្ត្រី ក៏ដូចជាបុរសត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ លិខិតបទដ្ឋាន និងក្របខ័ណ្ឌច្បាប់

ខ. ការអនុវត្តសមភាពយេនឌ័រនិងធនធានត្រូវបានពង្រឹង និងបានបញ្ចូលទៅក្នុងការរៀបចំផែនការ ការអនុវត្ត ការតាមដាន និងការវាយតម្លៃលើគ្រប់សកម្មភាព សេវាកម្មបច្ចេកទេស គម្រោង កម្មវិធី និងថវិកា

គ. ការវិភាគយេនឌ័រត្រូវបានពង្រឹង តាមរយៈការប្រមូលទិន្នន័យដែលអាចយល់បាន រួមទាំងទិន្នន័យគុណភាព ការវិភាគ ការធ្វើរបាយការណ៍ដែលមានទិន្នន័យយេនឌ័រគ្រប់កម្មវិធី និងសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឃ. ជំនាញ ចំណេះដឹងអំពីយេនឌ័រ និងកសិកម្មត្រូវបានពង្រឹងទូទាំងវិស័យ រួមទាំងមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារយេនឌ័រនិងកុមារ និងគ្រឹះស្ថានអប់រំកសិកម្ម។

**គោលបំណងទី៣. បង្កើនភាពជាតំណាង និងការចូលរួមស្មើភាពគ្នាទាំងស្ត្រី និងបុរសក្នុងវិស័យកសិកម្ម**

លទ្ធផល

ក. វត្តមាន និងឥទ្ធិពលរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការកើនឡើង

ខ. វត្តមាននិងឥទ្ធិពលរបស់ស្ត្រី ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត នៅតាមសហគមន៍ក្នុងក្របខណ្ឌការងារកសិកម្ម ក្រុមគ្រប់គ្រងធនធានធម្មជាតិ និងបម្រែបម្រួលអាកាសធាតុ មានការកើនឡើង

គ. ស្ត្រីកាន់តែមានលទ្ធភាពទទួលបានឱកាសអភិវឌ្ឍន៍ជំនាញ និងការសិក្សា ដើម្បីគាំទ្រដល់ការចូលរួមរបស់គាត់ក្នុងវិស័យកសិកម្ម រួមមានផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ជលផល ព្រៃឈើ និងកៅស៊ូ

**គោលបំណងទី៤. បង្កើនកិច្ចសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធទាំងអស់ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍ អង្គការក្រៅរដ្ឋាភិបាល និងឯកជន) នៅក្នុងវិស័យកសិកម្ម និងជាមួយអ្នកពាក់ព័ន្ធក្នុងការងារបម្រែបម្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិ**

លទ្ធផល

ក. ដៃគូដាក់បញ្ចូលយេនឌ័រទៅគ្រប់កម្មវិធី ដែលស្របគ្នាជាមួយយុទ្ធសាស្ត្រនេះ

ខ. អ្នកពាក់ព័ន្ធនានា មានឱកាសច្រើនជាងមុនក្នុងការលើកឡើង និងពិភាក្សាអំពីបញ្ហាយេនឌ័រ បទពិសោធន៍ និងសមិទ្ធផលនានាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការអនុវត្ត

ការយល់ដឹងអំពីសារសំខាន់នៃការបញ្ជ្រាបយេនឌ័រ គឺជាជំហានមួយដ៏ចាំបាច់ក្នុងការដោះស្រាយបញ្ហាមិនសូវយកចិត្តទុកដាក់ទៅលើតួនាទី ការទទួលខុសត្រូវ តម្រូវការ ផលប្រយោជន៍ និងការលំបាកខុសប្លែកគ្នារបស់ស្ត្រី និងបុរស នៅក្នុងវិស័យកសិកម្ម។ ទោះបីជាយ៉ាងនេះក្តី ការប្រែក្លាយពីការស្វែងយល់ឱ្យទៅជាសកម្មភាព បង្កការលំបាកសម្រាប់អ្នកដឹកនាំក្រសួង មន្ត្រីបច្ចេកទេស និងសមាជិកនៃក្រុមការងារយេនឌ័រនិងកុមារ និងជនបង្គោលយេនឌ័រនៅគ្រប់កម្រិត និងតាមអនុវិស័យ។ ការអនុវត្តទាមទារការប្តេជ្ញាចិត្ត ការទទួលខុសត្រូវ ធនធានថវិកានិងធនធានមនុស្ស ព្រមទាំងការពង្រឹងសមត្ថភាព និងគាំទ្រការផ្លាស់ប្តូរវប្បធម៌នៅក្នុងស្ថាប័នពាក់ព័ន្ធទាំងអស់។

ការទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម គឺជាការទទួលខុសត្រូវរបស់អ្នកដឹកនាំក្រសួងកម្រិតខ្ពស់ (ការិយាល័យ នាយកដ្ឋាន និងរដ្ឋបាល) នៃអនុវិស័យនៅគ្រប់កម្រិត ។

ទោះបីជាយ៉ាងណាក្តី មន្ត្រីទាំងអស់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយនេះ។ ក្រុមការងារយេនឌ័រ និងកុមារ ត្រូវគាំទ្រស្ថាប័ន និងផ្តល់ការណែនាំផ្នែកបច្ចេកទេសសម្រាប់ការអនុវត្ត។ ជាពិសេស ក្រុមការងារយេនឌ័រ និងកុមារទទួលខុសត្រូវចំពោះ៖ ក) រៀបចំធ្វើសេចក្តីព្រាង និង

កែសម្រួលការបញ្ជ្រាបយេនឌ័រក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ខ) ដាក់បញ្ចូលផែនការបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំទៅក្នុងផែនការប្រចាំឆ្នាំរបស់ក្រសួង គ) សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ ឃ) សម្របសម្រួលការអនុវត្តផែនការសកម្មភាព ង) រៀបចំ និងអនុវត្តសកម្មភាពកសាងសមត្ថភាព ច) រៀបចំរបាយការណ៍វឌ្ឍនភាព សម្រាប់ធ្វើបទបង្ហាញក្នុងក្រុមការងារបច្ចេកទេសតាមវិស័យ និងក្រុមការងារបច្ចេកទេសយេនឌ័រ ។

ព័ត៌មានលម្អិតមានជូនភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ២។

## ៥. ការតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃជាប្រព័ន្ធនិងជាប្រចាំ គឺជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ទិន្នន័យបរិមាណ និងគុណភាពសម្រាប់សូចនាករនិមួយៗ ត្រូវតែប្រមូលសម្រាប់វាស់វែងលទ្ធផលសម្រេចបាន ព្រមទាំងកំណត់និងដោះស្រាយបញ្ហាប្រឈម ឬឧបសគ្គនានា និងកសាងបន្ថែមទៅលើជោគជ័យ និងទទួលបាននូវផលប្រយោជន៍ពីកាលានុវត្តភាព។

អនុវិស័យ និងនាយកដ្ឋាននានានៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍នានាដែលអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវវាយការណ៍ឱ្យបានទៀងទាត់ជូនដល់ក្រសួង (ក្រុមការងារយេនឌ័រ និងកុមារ) អំពីសមិទ្ធផលតាមរយៈរបាយការណ៍ប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ។

កង្វះទិន្នន័យដែលអាចយល់បាន គឺជាការលំបាកសម្រាប់វាយតម្លៃអំពីសមិទ្ធផល និងការធ្វើបច្ចុប្បន្នភាពគោលបំណង និងលទ្ធផលសម្រាប់យុទ្ធសាស្ត្រនេះ។ ទិន្នន័យដើមគ្រាគួរតែប្រមូល តាមរយៈកិច្ចសហការជាមួយដៃគូដែលមានចំណាប់អារម្មណ៍ និងមានធនធានសម្រាប់ចំណុចជាក់លាក់នៃយុទ្ធសាស្ត្រនេះ។ ការវាយតម្លៃពាក់កណ្ដាលអណត្តិ គួរត្រូវរៀបចំឡើង ដើម្បីវាស់វែងពីសមិទ្ធផល ព្រមទាំងធ្វើការព្យាករណ៍ថាតើគោលដៅសម្រាប់ឆ្នាំ២០២៦ អាចនឹងសម្រេចបានឬយ៉ាងណា និងផ្តល់ឱកាសធ្វើការកែសម្រួលសកម្មភាព សូចនាករ និងចំណុចដៅ ឱ្យស្របទៅតាមស្ថានភាពដែលកំពុងវិវត្តន៍។

ក្រុមការងារយេនឌ័រ និងកុមារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវរៀបចំធ្វើការវាយតម្លៃចុងក្រោយអំពីការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ដើម្បីធ្វើការវាស់វែងនូវសមិទ្ធផលសម្រាប់រយៈពេល៥ឆ្នាំ លើការលើកកម្ពស់សមភាពយេនឌ័រ និងកុមារ នៅក្នុងវិស័យកសិកម្ម និងកំណត់អាទិភាពសម្រាប់អាណត្តិបន្ទាប់។

កិច្ចការទាំងនេះអាចទទួលបានជោគជ័យ តាមរយៈកិច្ចសហការជាមួយក្រុមការងារយេនឌ័រ នាយកដ្ឋានផ្នែកគ្រប់គ្រង និងការអនុវត្តគម្រោង អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។

## ឧបសម្ព័ន្ធទី១៖ ការប៉ាន់ប្រមាណពីសមិទ្ធផលនៃការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម ២០១៦-២០២០

គោលបំណងទី១៖ លើកកម្ពស់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី តាមរយៈការបង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបាននូវធនធាន និងសេវាកម្មសម្រាប់ការអភិវឌ្ឍកសិកម្ម និងទីផ្សារ

### លទ្ធផលរំពឹងទុកទី១៖ ស្ត្រីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបាននូវធនធានកសិកម្ម

យោងតាមព័ត៌មានទទួលបានពីអ្នកដឹកនាំសហគមន៍កសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមខេត្ត អ្នកលក់ធាតុចូល និងអ្នកពាក់ព័ន្ធដទៃទៀត ដែលបានចូលរួមនៅក្នុងការប៉ាន់ប្រមាណអំពីសមិទ្ធផលនេះ លទ្ធភាពរបស់ស្ត្រី និងបុរសក្នុងការទទួលបានធាតុចូលកសិកម្ម មានភាពខុសប្លែកគ្នា អាស្រ័យប្រភេទសេវា និងធាតុចូល។ សម្រាប់គ្រាប់ពូជ ជី និងថ្នាំកសិកម្ម ស្ត្រី និងបុរសមានលទ្ធភាពស្មើគ្នា ប៉ុន្តែវាខុសប្លែកប្រសិនបើគេជាសមាជិកសហគមន៍ និងមិនមែនជាសមាជិកសហគមន៍។ សហគមន៍កសិកម្មខ្លះ ដែលលក់ធាតុចូលកសិកម្ម ដូចនេះគេទទួលបាននូវការបញ្ចុះតម្លៃ ដោយសារគេទិញបរិមាណច្រើន ។ ក្រៅពីនេះ សមាជិកសហគមន៍កសិកម្មជាស្ត្រី មិនចំណាយពេលវេលាក្នុងការធ្វើដំណើរ ហើយមិនចាំបាច់ចំណាយលើការធ្វើដំណើរ។ ចំណុចនេះ ធ្វើឱ្យមានភាពងាយស្រួលសម្រាប់ស្ត្រីក្នុងការទទួលបានធាតុចូល ដោយសារពួកគេមានការទទួលខុសត្រូវក្នុងគ្រួសារ និងមានពេលវេលាតិចតួចសម្រាប់ធ្វើដំណើរ។

ក្រុមអាជីវកម្ម និងសហគមន៍កសិកម្មខ្លះ ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីស្វែងរកអ្នកផ្គត់ផ្គង់ធាតុចូល និងបច្ចេកទេសកសិកម្មចុងក្រោយ។ ឧទាហរណ៍ ក្រុមហ៊ុនអង្គរគ្រីនបានបង្កើតក្រុមតេឡេក្រាមឈ្មោះថាភូមិចំណេះដឹងកសិកម្ម ដែលមានកសិករជាស្ត្រី បុរស អ្នកលក់ធាតុចូល អ្នកផ្តល់សេវាចំនួន៥ ៦២៩នាក់ចូលរួម។ កសិករអាចសុំដំបូន្មាននៅពេលពួកគេជួបប្រទះបញ្ហាទាក់ទងនឹងការធ្វើស្រែ ឬការងារកសិកម្មផ្សេងៗទៀត ហើយទទួលបានចម្លើយពីក្រុមហ៊ុន អ្នកលក់ធាតុចូល និងកសិករដទៃទៀតដែលមានបទពិសោធន៍ជាក់ស្តែង។ ពួកគេចែករំលែកព័ត៌មានទីផ្សារ នៅពេលមានក្រុមហ៊ុនចង់ទិញផលិតផលកសិកម្មក្នុងចំនួនច្រើន។ ស្ត្រីដែលចូលរួមក្នុងក្រុមនេះយល់ថាក្រុមនេះមានសារប្រយោជន៍ ដោយសារវាជួយឱ្យពួកគេទទួលបានព័ត៌មានភ្លាមៗ និងការគាំទ្រដែលគេត្រូវការ។ នៅក្នុងអំឡុងពេលការរីករាលដាលជម្ងឺកូវីដ-១៩ មានគំនិតផ្តួចផ្តើមមួយទៀតទាក់ទងនឹងសេវាតាមបណ្តាញតេឡេក្រាម (tele-based extension services) រួមមានការសន្ទនាតាមស្កាយ (skype calls) ការផ្ញើសារតាមទូរស័ព្ទ ការសន្ទនាតាមទូរស័ព្ទ នៅអំឡុងពេលស្ថានភាពតឹងតែង[61] ។

ការសិក្សាយេនឌ័រអំពីគ្រឿងយន្តកសិកម្ម ដែលបានធ្វើឡើងដោយកម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជាអូស្ត្រាលី (CAVAC) នាពេលថ្មីៗនេះ បានបង្ហាញថា កសិករជាបុរសមានលទ្ធភាពប្រើប្រាស់គ្រឿងយន្តកសិកម្មច្រើនជាងស្ត្រី ដោយសារមូលហេតុមួយចំនួន។ ក្រៅពីនេះ ការសិក្សានេះបានបង្ហាញថា ស្ត្រីជួបប្រទះនឹងបញ្ហាមួយចំនួនដែលទាក់ទងគ្នា និងឧបសគ្គក្នុងការលើកឡើងពីតម្រូវការគ្រឿងយន្តដែលបញ្ជាដោយបុរស ឬឧបករណ៍ណាខ្លះដែលសមស្របសម្រាប់ពួកគេ។

ទោះបីជាយ៉ាងនេះក្តី ស្ត្រីទទួលបាននូវអត្ថប្រយោជន៍មួយចំនួនពីគ្រឿងយន្តកសិកម្ម រួមមាន៖ វាជួយសន្សំសំចៃពេលវេលារបស់ស្ត្រី ធ្វើឱ្យការងាររបស់ស្ត្រីមានភាពងាយស្រួលជាងមុន សន្សំថវិកា និងបង្កើនប្រាក់ចំណូល

[61] OECD, 2021

សុខភាពល្អប្រសើរជាង (ដោយសារការងារដ៏លំបាករបស់ស្ត្រី ត្រូវបានកាត់បន្ថយដោយគ្រឿងម៉ាស៊ីន)។ ចំណុចទាំងនេះធ្វើឱ្យមានភាពសុខដុមក្នុងក្រុមគ្រួសារ។

សហគមន៍កសិកម្មខ្លះមានគ្រឿងយន្តកសិកម្ម ដូចជាម៉ាស៊ីនដាំគ្រាប់ស្រូវ ត្រាក់ទ័រ តាមរយៈការទិញដោយប្រើប្រាស់ធនធានរួមគ្នា ឬជាអំណោយពីអង្គការក្រៅរដ្ឋាភិបាល។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់សេវាដល់សមាជិក និងកសិករដែលមិនមែនជាសមាជិក។ ចំណុចនេះធ្វើឱ្យស្ត្រីមានលទ្ធភាពទទួលបានសេវាគ្រឿងយន្តកសិកម្ម ដូចជាសេវាកៀរដីឱ្យស្មើ ការរៀបចំដី ការដាំគ្រាប់ស្រូវ ច្រូតស្រូវ និងការបាញ់ថ្នាំសម្លាប់សត្វល្អិតដោយប្រើម៉ាស៊ីនជ្រូន។ សហគមន៍ខ្លះផ្តល់អាទិភាពដល់សមាជិកជាស្ត្រីដែលមានវ័យចំណាស់ ស្ត្រីមេម៉ាយ ឬស្ត្រីដែលប្តីធ្វើចំណាកស្រុក ក្នុងការផ្តល់សេវា[62] ។

ក្រុមសន្សំប្រាក់ គឺជាយន្តការហិរញ្ញវត្ថុដ៏ល្អសម្រាប់ស្ត្រី និងបុរសក្រីក្រ ដោយសារពួកគេមិនត្រូវការវត្ថុបញ្ចាំ។ ក្នុងអំឡុងពេលប្រាំឆ្នាំកន្លងមកនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតក្រុមសន្សំប្រាក់បានចំនួន៨១៧ក្រុម នៅទូទាំងប្រទេស ដោយមានសមាជិកចំនួន៤៣ ០២៤នាក់ (៦៨ភាគរយជាស្ត្រី)។ ដូចគ្នានេះដែរ សហគមន៍កសិកម្មក៏ផ្តល់សេវាហិរញ្ញវត្ថុសម្រាប់សមាជិកខ្លួន ហើយកិច្ចការនេះមានផលល្អសម្រាប់ស្ត្រី ក្នុងការដាក់ប្រាក់សន្សំ និងទទួលបាននូវប្រាក់កម្ចីនៅពេលត្រូវការ។ ដូចនេះ ក្រុមសន្សំប្រាក់ និងសហគមន៍កសិកម្ម ជួយស្ត្រី និងក្រុមដែលងាយរងគ្រោះដទៃទៀត តាមវិធីផ្សេងៗគ្នា[63] ។

### លទ្ធផលរំពឹងទុកទី២៖ ស្ត្រីមានលទ្ធភាពកាន់តែល្អ ក្នុងការទទួលបាននូវព័ត៌មាន ចំណេះដឹង និងសេវាកម្មជំនាញបច្ចេកទេស ដើម្បីគាំទ្រដល់ការងាររបស់ពួកគាត់ក្នុងវិស័យកសិកម្ម ដូចជា ប្រពលវប្បកម្មដំណាំ និងពិពិធកម្មដំណាំ វារីវប្បកម្ម ការចិញ្ចឹមសត្វ ព្រៃឈើ កៅស៊ូ និងកាលានុវត្តភាពផ្សេងៗ ដែលទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ

យោងតាមព័ត៌មានដែលទទួលបានពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងខេត្តមួយចំនួន ស្ត្រីមានលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបាននូវព័ត៌មាន ជំនាញបច្ចេកទេស ធនធាន និងបច្ចេកវិទ្យា។ ក្រសួង ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់វគ្គបណ្តុះបណ្តាលជាច្រើនអំពីជំនាញកសិកម្ម ដូចជាការចិញ្ចឹមសត្វ ការដាំដំណាំ និងស្រូវ និងការប្រមូលផល (ទោះបីជាមានបញ្ហាប្រឈមក្នុងអំឡុងពេលកូវីត ដែលមានការហាមឃាត់ការជួបជុំគ្នា)។ ទោះបីជាយ៉ាងនេះក្តី ការចូលរួមរបស់ស្ត្រីក្នុងវគ្គបណ្តុះបណ្តាលទាំងនេះ មានភាពខុសប្លែកគ្នា អាស្រ័យលើប្រធានបទនៃវគ្គបណ្តុះបណ្តាល។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំខេត្តសៀមរាប និងបាត់ដំបងបានឱ្យដឹងថាមានស្ត្រីជាច្រើនចូលរួមក្នុងវគ្គបណ្តុះបណ្តាលរបស់ពួកគេ ស្តីអំពីការប្រើប្រាស់ថ្នាំកសិកម្ម ជី និងការដាំបន្លែ ប៉ុន្តែមានស្ត្រីតែពីរ បីនាក់ប៉ុណ្ណោះដែលបានចូលរួមការបណ្តុះបណ្តាលស្តីពីគ្រឿងយន្តកសិកម្ម[64]។

ក្នុងរយៈពេលប្រាំឆ្នាំនេះ កសិករចំនួន ១១៧ ០១០ នាក់ (៤៦ភាគរយជាស្ត្រី) ទទួលបានការបណ្តុះបណ្តាលជំនាញកសិកម្មពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្រសួង ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលបានចាត់ទុកថា សហគមន៍កសិកម្ម និងក្រុមអ្នកផលិតគឺជាមធ្យោបាយដ៏មានសារប្រយោជន៍ សម្រាប់កែលម្អការផលិតកសិកម្ម ចំណេះដឹង និងការចែករំលែកបទពិសោធន៍

---

[62] CAVAC forthcoming recent gender study on mechanisation

[63] MAFF annual report 2019

[64] CAVACs forthcoming study on gender and mechanization identified the same issue.

ព្រមទាំងបង្កើនលទ្ធភាពកសិករ ជាពិសេសស្ត្រី ក្នុងការទទួលបាននូវធាតុចូលកសិកម្ម ព័ត៌មាន បច្ចេកវិទ្យាកសិកម្ម និងទីផ្សារ។ ក្នុងរយៈពេលនេះ ក្រសួងបានចងក្រងសហគមន៍ព្រៃឈើចំនួន ៦៣៦ក្រុម សមាជិក ១៦ ៩២៤ (ស្ត្រីមាន៤៩ភាគរយ) ក្រុមអ្នកនេសាទមាន៥១៦ក្រុម មានសមាជិក ១៩០ ០៧០នាក់ (ស្ត្រីមាន៤៤ភាគរយ) ក្រុមសន្សំប្រាក់មានចំនួន៣២៧ក្រុម[65]។ ដោយឡែកសហគមន៍កសិកម្មដែលបានបង្កើតក្នុងរយៈពេលរាយការណ៍នេះ មានចំនួន៨៨០សហគមន៍ សមាជិកសរុបមានការកើនឡើងពី១៤ ៣៣១៥នាក់ (ស្ត្រីមាន៦០ភាគរយ) នៅឆ្នាំ ២០១៧ មក២៥ ៤៧៥៩នាក់ (ស្ត្រីស្មើនឹង ៦៣ភាគរយ) នៅឆ្នាំ២០២១ ។ ដូចនេះចំនួនសមាជិកជាស្ត្រីមានការកើនឡើង៣ភាគរយ[66]។

**ក្រាហ្វិកទីមួយ៖ សមាជិកសហគមន៍កសិកម្ម ឆ្នាំ ២០១៧ - ២០២១ គិតជាភាគរយ**




នៅក្នុងដំណើរការវាយតម្លៃ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញថា ឥរិយាបថសង្គមចំពោះស្ត្រី មានការផ្លាស់ប្តូរ។ សហគមន៍មានការទទួលស្គាល់ច្រើនជាងមុន ចំពោះការចូលរួមរបស់ស្ត្រី ទាំងនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍ ស្ត្រីមានសម្លេងនិងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងមានភស្តុតាងដែលបញ្ជាក់ពីការធ្លាក់ចុះនៃអំពើហឹង្សាលើស្ត្រី និងកុមារី (ឥទ្ធិពលនៃការរាតត្បាតជាសកលចំពោះប្រេវ៉ាឡង់មិនទាន់បានបញ្ជាក់អំពីបរិមាណ ប៉ុន្តែមានការគិតថាមានកម្រិតខ្ពស់ជាងនេះ)។ ស្ត្រីខ្លួនឯង ហ៊ានលើកឡើងពីការបារម្ភ និងមានទំនុកចិត្តច្រើនជាងមុនក្នុងការចូលរួមសកម្មភាពអភិវឌ្ឍន៍សង្គម។ ពួកគាត់ប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយ ពោលគឺស្មាតហ្វូន (ទូរស័ព្ទឆ្លាតវៃ) ដើម្បីទទួលបានព័ត៌មានទីផ្សារ ឧបករណ៍ និងសម្ភារៈនានា ដើម្បីថែរក្សាបន្លែ និងផលិតផលកសិកម្មដទៃទៀតឱ្យនៅស្រស់។ ជនបង្គោលយេនឌ័ររបស់ក្រសួង បានកត់សម្គាល់ឃើញថា នៅក្នុងក្រុមអ្នកផលិតនិងសហគមន៍កសិកម្ម ស្ត្រីជាអ្នកដឹកនាំមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តដូចអ្នកដឹកនាំបុរសដែរ។ ទោះបីជាយ៉ាងនេះក្តី បន្ទុកការងារ និងភាពក្រខ្សត់ទៅលើពេលវេលារបស់ស្ត្រី នៅតែជាឧបសគ្គរារាំងការចូលរួមរបស់ស្ត្រីដដែល។

### លទ្ធផលរំពឹងទុកទី៣៖ ស្ត្រីមានបណ្តាញកាន់តែរឹងមាំជាមួយនឹងទីផ្សារតាមបែបប្រពៃណី និងទីផ្សារថ្មីៗ

កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មផ្សេងៗរបស់ដៃគូអភិវឌ្ឍន៍ ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក បានអភិវឌ្ឍន៍ និងលើកកម្ពស់កសិកម្មឱ្យឆ្លើយតបតាមតម្រូវការទីផ្សារ និងប្រកបដោយនិរន្តភាព ព្រមទាំងគំនិតផ្តួច

[65] MAFF progress report, 2017 – 2021, on the protection of women’s rights and promotion of gender equality

[66] MAFF annual report 2019

ផ្តើមនានាទាក់ទងនឹងធនធានធម្មជាតិ ដែលផ្តល់ផលប្រយោជន៍សម្រាប់សហគមន៍ជនបទ។ ឧទាហរណ៍ មានកម្មវិធីមួយចំនួនដែលជួយឱ្យសហគមន៍ធន់ទ្រាំនឹងបម្រែបម្រួលអាកាសធាតុ បង្កើនលទ្ធភាពទីផ្សារ និងកែលម្អការគ្រប់គ្រងធនធានធម្មជាតិ ការបង្កើតទិន្នន័យមូលដ្ឋានដែលសមស្របតាមសហគមន៍ និងការធានាចំពោះអ្នកទិញផលិតផលកសិកម្មចំនួនច្រើន តាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យា។ ក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានសហការជាមួយអ្នកពាក់ព័ន្ធផ្សេងៗ រួមទាំងអង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន។

ដូចបានរៀបរាប់ខាងលើ អង្គការក្រៅរដ្ឋាភិបាលខ្លះបានជួយណែនាំឱ្យសហគមន៍កសិកម្មជួបជាមួយអ្នកទិញធំៗ និងសម្របសម្រួលការធ្វើកសិកម្មតាមកិច្ចសន្យា នៅក្នុងខេត្តកំពង់ធំ ព្រះវិហារ និងស្វាយរៀង។ ដៃគូអភិវឌ្ឍន៍ ភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលខ្លះ បានរាយការណ៍ថាពួកគេបានរៀបចំ និងអនុវត្តយុទ្ធសាស្ត្រមួយចំនួន ដូចជាវេទិការធុរកិច្ច ដើម្បីបង្កើនលទ្ធភាពនិងបណ្តាញស្ត្រី។

នៅក្នុងខេត្តខ្លះ ស្ត្រីទទួលបានការគាំទ្រលើការងារទីផ្សារ។ ឧទាហរណ៍ សហគមន៍កសិកម្ម សាងសង់តូបលក់ផលិតផលកសិកម្មនៅក្នុងទីផ្សាររួមខេត្ត ឬនៅតាមអគារសហគមន៍កសិកម្ម សម្រាប់លក់ផលិតផលកសិកម្មរបស់សមាជិក។ លើសពីនេះ ស្ត្រីខ្លះលក់ផលិតផលកសិកម្មតាមអនឡាញ តាមរយៈការជួយគាំទ្រពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការក្រៅរដ្ឋាភិបាល។

**គោលបំណងទី២៖ ពង្រឹងសមត្ថភាព ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម**

**លទ្ធផលរំពឹងទុកទី១៖ តម្រូវការ និងកង្វល់របស់ស្ត្រីក៏ដូចជាបុរស ត្រូវបានដាក់បញ្ចូលទៅគ្រប់គោលនយោបាយ លិខិតបទដ្ឋាន និងក្របខណ្ឌច្បាប់**

ក្នុងអំឡុងពេលប្រាំឆ្នាំ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកកម្ពស់សមភាពយេនឌ័រទៅក្នុងអនុវិស័យទាំងអស់ នៅក្រោមកសិកម្ម។ ការដាក់បញ្ចូលយេនឌ័រចូលទៅក្នុងគោលនយោបាយ បទប្បញ្ញត្តិ និងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព គឺជាសកម្មភាពមួយដ៏សំខាន់ ដែលចូលរួមចំណែកក្នុងការទទួលបាននូវសមិទ្ធផលនានា។ ដោយមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួងនិងក្រុមការងារយេនឌ័រ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រមួយចំនួនឆ្លើយតបនឹងយេនឌ័រ។ ឧទាហរណ៍ ផែនការសកម្មភាពសម្រាប់លើកកម្ពស់សមភាពយេនឌ័រ ក្នុងវិស័យនេសាទ ឆ្នាំ២០១៦ - ២០២០ ត្រូវបានរៀបចំ និងអនុវត្ត។ លើសពីនេះ ក្រសួងក៏បានរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសម្រាប់វិស័យព្រៃឈើឆ្នាំ២០២១ - ២០២៥។ នៅកម្រិតសហគមន៍ ក្រសួងបានបណ្តុះបណ្តាលកសិករចំនួន ៦២៦ នាក់ (ស្ត្រី ៤៨ភាគរយ) ស្ត្រីពី ការកាត់បន្ថយហានិភ័យលើការបម្រែបម្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ។

ទោះបីយ៉ាងនេះក្តី ជនបង្គោលយេនឌ័រយល់ថា ការងារបញ្ជ្រាបយេនឌ័ររបស់ពួកគេ អាចទទួលបានលទ្ធផលប្រសើរជាងនេះ ប្រសិនបើពួកគេមានសមត្ថភាពនិងបទពិសោធន៍ល្អជាងនេះ។ ដៃគូខ្លះបានលើកឡើងអំពីកង្វះព័ត៌មាន ឬទិន្នន័យយេនឌ័រ សម្រាប់វិស័យកសិកម្មទាំងមូល ដែលអាចទទួលបានតាមរយៈការប៉ាន់ប្រមាណយេនឌ័រលើវិស័យកសិកម្ម។ ពួកគេយល់ថាក្រសួងគួរជាអ្នកធ្វើការងារនេះ នៅរៀងរាល់ប្រាំឆ្នាំ ដើម្បីកំណត់និន្នាការថ្មី ជាពិសេសមុនពេលធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។ គួរកត់សម្គាល់ផងដែរថាក្រសួងកិច្ចការនារី ជាមួយដៃគូធ្វើការវាយតម្លៃយេនឌ័រក្នុងវិស័យផ្សេងៗ ដូចជាវិស័យអប់រំ សុខាភិបាល ក៏ដូចជាវិស័យកសិកម្មផងដែរ។

ក្រៅពីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួររៀបចំកិច្ចប្រជុំ និងធ្វើការងារសម្របសម្រួលឱ្យបានទៀងទាត់ជាមួយដៃគូនានា ដើម្បីផ្តល់ឱកាសសម្រាប់ពិភាក្សា ឬផ្លាស់ប្តូរនូវបទពិសោធន៍នៅថ្នាក់ជាតិ។ ការដាក់បញ្ចូលទស្សនទានយេនឌ័រចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលនៃគ្រឹះស្ថានអប់រំកសិកម្ម គឺជាសកម្មភាពដ៏ចម្បងមួយទៀត។ គ្រឹះស្ថានអប់រំកសិកម្មទាំងបី របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកែសម្រួលឯកសារបណ្តុះបណ្តាលដោយដាក់បញ្ចូលនូវទស្សនទានយេនឌ័រ ហើយគ្រូម្នាក់ៗបានខិតខំតតឈប់ឈរលើការដាក់បញ្ចូលយេនឌ័រ នៅពេលរៀបចំមេរៀន ។ កង្វះខាតនូវសមត្ថភាព និងបទពិសោធន៍គឺជាឧបសគ្គសម្រាប់ពួកគេ។

**លទ្ធផលរំពឹងទុកទីពីរៈ បញ្ហាយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំផែនការ ការអនុវត្ត ការតាមដាន និងការវាយតម្លៃលើគ្រប់សកម្មភាព សេវាកម្មបច្ចេកទេស គម្រោង កម្មវិធី និងថវិកា**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានដៃគូជាយុទ្ធសាស្រ្តជាមួយក្រសួងពីរ (ក្រសួងកិច្ចការនារី និងក្រសួងបរិស្ថាន) ដៃគូអភិវឌ្ឍន៍ (សហភាពអឺរ៉ុប ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ) និងជាមួយអង្គការក្រៅរដ្ឋាភិបាល និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មនានា (សង្គ្រោះកុមារ SNV CAVAC WE-EFFECT ) ព្រមទាំងក្រុមហ៊ុនឯកជន។ ដៃគូមួយចំនួនមានអារម្មណ៍ថា គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័ររបស់ក្រសួង មានភាពល្អប្រសើរ និងមានព័ត៌មានច្រើន ហើយពួកគេបានប្រើប្រាស់វាជាឯកសារយោងសម្រាប់ការវិភាគតាមវិស័យនៅពេលរៀបចំគម្រោងថ្មី ផែនការសកម្មភាពប្រចាំឆ្នាំ និងការអនុវត្តសកម្មភាពគម្រោង។

ដៃគូអភិវឌ្ឍន៍ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារអភិវឌ្ឍន៍ដទៃទៀតក៏បានបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មរបស់ពួកគេ ចាប់ពីដំណាក់កាលរៀបចំ រហូតដល់ការអនុវត្ត។

យេនឌ័រគឺជាចំណុចមួយនៃលក្ខណៈវិនិច្ឆ័យរបស់អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងការជ្រើសរើសដៃគូអនុវត្តគម្រោង ដើម្បីធានាថាដៃគូមានការប្តេជ្ញាចិត្ត និងមានសមត្ថភាពក្នុងការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងតំបន់គោលដៅ។ មុនពេលរៀបចំគម្រោង ឬកម្មវិធី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ នឹងនេសាទ ជារឿយៗគឺបានធ្វើការវិភាគយេនឌ័រ ហើយយុទ្ធសាស្រ្តរបស់គម្រោងត្រូវបានរៀបចំឡើងដោយផ្អែកលើការវិភាគនេះ។

នាយកដ្ឋាននិមួយៗនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតប្រព័ន្ធតាមដានការងារដើម្បីប្រមូលទិន្នន័យដែលបែងចែកតាមភេទ ប៉ុន្តែភាគច្រើនជាទិន្នន័យបែបបរិមាណច្រើនជាង ទិន្នន័យបែបគុណភាពដូចនេះហើយរបាយការណ៍របស់នាយកដ្ឋានរដ្ឋបាល និងកម្មវិធីខ្លះមានព័ត៌មានអំពីយេនឌ័រ។ ប៉ុន្តែមន្ត្រីដែលពាក់ព័ន្ធយល់ថាពួកគេមិនទាន់បានប្រមូលព័ត៌មានគុណភាពឱ្យបានគ្រប់គ្រាន់នៅឡើយទេ និងមានផែនការពង្រឹងកិច្ចការនេះនាពេលអនាគត។ ការវិភាគទិន្នន័យក៏នៅមានភាពខ្វះខាតនិងត្រូវពង្រឹង ដើម្បីផ្តល់ព័ត៌មានដល់កម្រិតគោលនយោបាយក្នុងការធ្វើសេចក្តីសម្រេចនិងអនុវត្ត។

ទោះបីជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានលទ្ធផលជាវិជ្ជមានមួយចំនួនក៏ដោយ ក៏ពួកគាត់នៅជួបការលំបាកនៅឡើយ ។ កង្វះមន្ត្រីបង្គោលយេនឌ័រនៅក្នុងក្រុមការងារអនុវត្តគម្រោង ជាពិសេសគម្រោងដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៏អាស៊ី ធនាគារពិភពលោក គឺជាឧបសគ្គ ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពគម្រោង។ នៅក្នុងកំឡុងពេលធ្វើការប៉ាន់ប្រមាណអំពីសមិទ្ធផលនេះដៃគូអភិវឌ្ឍន៍ខ្លះបានផ្តល់ព័ត៌មានថាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនបានចាត់តាំងមន្ត្រីបង្គោលយេនឌ័រឱ្យបានគ្រប់គ្រាន់នៅក្នុងក្រុមការងារអនុវត្តគម្រោងនោះទេ។ ជួនកាល គឺគ្មានសមាជិកណាម្នាក់មានជំនាញយេនឌ័រទាល់តែសោះ ពួកគាត់ផ្តោតតែលើ

ជំនាញបច្ចេកទេស។ ដូចគ្នានេះដែរ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំខេត្តមួយចំនួនបានលើកឡើងអំពីការកង្វល់របស់ពួកគាត់ថា គម្រោងខ្លះមិនអនុញ្ញាតឱ្យមន្ត្រីបង្គោលយេនឌ័រចូលរួមក្នុងអំឡុងពេលរៀបចំ និងអនុវត្តសកម្មភាពគម្រោង។

ដោយយោងទៅតាមកង្វះការគាំទ្រពីថ្នាក់ដឹកនាំ និងធនធានហិរញ្ញវត្ថុ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំខេត្តមួយចំនួន មិនបានអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មនោះទេ។ ទោះជាយ៉ាងនេះក្តី មន្ត្រីធ្វើការនៅតាមអនុវិស័យ អញ្ជើញស្ត្រីជាកសិករមកចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលរបស់គាត់ ដែលពាក់ព័ន្ធនឹងការដាំដំណាំ ចិញ្ចឹមសត្វ យុទ្ធសាស្ត្រទីផ្សារ និងការធ្វើកសិកម្មតាមកិច្ចសន្យា។

**លទ្ធផលរំពឹងទុកទី៣ ៖ ក្រុមការងារយេនឌ័រនិងកុមារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថភាព និងជំនាញច្បាស់លាស់ និងធនធាន សម្រាប់អនុវត្តការងារ ការតស៊ូមតិ ការកសាងសមត្ថភាព ភាពជាដៃគូ ជំនួយបច្ចេកទេស និងតួនាទីត្រួតពិនិត្យ**

ក្រុមការងារយេនឌ័រ មន្ត្រីបង្គោលយេនឌ័រ មន្ត្រីបច្ចេកទេស និងមន្ត្រីជាន់ខ្ពស់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាន់តែមានទំនុកចិត្តក្នុងការបំពេញតួនាទីយេនឌ័រ ក្រោយពេលដែលពួកគេបានចូលរួមវគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សានៅក្នុង និងក្រៅប្រទេស ដែលរៀបចំដោយក្រសួង ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម។ កម្មវិធីបណ្តុះបណ្តាលមានភាពខុសប្លែកគ្នាអាស្រ័យលើគោលបំណងរួម និងគោលបំណងរបស់កម្មវិធីនិមួយៗ។ ឧទាហរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តោតទៅលើអនុសញ្ញាស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ចំណែកអ្នកផ្សេងបណ្តុះបណ្តាលអំពីការបញ្ជ្រាបយេនឌ័រក្នុងការរៀបចំគម្រោង ការធ្វើផែនការ ការត្រួតពិនិត្យ និងវាយតម្លៃ ការបញ្ជ្រាបយេនឌ័រក្នុងបច្ចេកវិទ្យាកសិកម្មថ្មី ដែលមានភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ។ ក្នុងរយៈពេលរាយការណ៍នេះ មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរថ្នាក់ស្រុកចំនួន២៩ ៥២១នាក់ (៣៦ភាគរយជាស្ត្រី) ទទួលបានការបណ្តុះបណ្តាលអំពីអនុសញ្ញាស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារ ។ ដើម្បីធ្វើឱ្យសកម្មភាពគម្រោងមាននិរន្តភាព និងប្រើប្រាស់ធនធានឱ្យបានប្រសើរបំផុត កម្មវិធីខ្លះផ្តោតលើការបណ្តុះបណ្តាលមន្ត្រីក្រសួងឱ្យក្លាយជាអ្នកបណ្តុះបណ្តាល។ ពួកគេបានរៀបចំសិក្សាសាលាបណ្តុះបណ្តាលគ្រូបង្គោលចំនួន ២៩០នាក់ (ស្ត្រីមាន៥០ភាគរយ) ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងបច្ចេកវិទ្យាកសិកម្មថ្មី ដែលមានភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ[67]។

ប៉ុន្តែនៅតែមានគម្លាតចំណេះដឹង និងជំនាញក្នុងផ្នែកខ្លះដូចជាការវិភាគយេនឌ័រ នៅក្នុងចំណោមក្រុមការងារយេនឌ័រ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មន្ត្រីសំខាន់ៗបានលើកឡើងថា ពួកគេត្រូវពង្រឹងចំណេះដឹងយេនឌ័រ ដើម្បីគាំទ្រ និងមានឥទ្ធិពលដល់ដៃគូក្នុងការដាក់បញ្ចូលតម្រូវការរបស់ស្ត្រី និងបុរសចូលក្នុងយុទ្ធសាស្ត្ររបស់គម្រោងឬកម្មវិធី ព្រមទាំងការបែងចែកធនធាន។

**គោលបំណងទី៣៖ បង្កើនភាពជាតំណាង និងការចូលរួមស្មើភាពគ្នាទាំងបុរស និងស្ត្រីក្នុងវិស័យកសិកម្ម**

**លទ្ធផលរំពឹងទុកទី១៖ វត្តមាន និងឥទ្ធិពលរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការកើនឡើង**

---

[67] MAFF five year report, 2017 – 2021 on the protection of women's rights and promotion of gender equality

រាជរដ្ឋាភិបាលកម្ពុជា បានលើកទឹកចិត្តគ្រប់ក្រសួងធ្វើការលើកកម្ពស់ស្ត្រីក្នុងតួនាទីដឹកនាំ ប៉ុន្តែចំណុចនេះ មានការលំបាកសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការធ្វើឱ្យសម្រេច ដោយសារមូលហេតុមួយចំនួន ដូចជា៖ សមត្ថភាពរបស់ស្ត្រីនៅមានកម្រិត ជាពិសេសជំនាញភាសាបរទេស និងជំនាញកុំព្យូទ័រ កង្វះនូវការគាំទ្រឬ ការលើកទឹកចិត្តពីថ្នាក់ដឹកនាំទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។

ដូចមានបង្ហាញក្នុងក្រាហ្វិកខាងក្រោម ប្រសិនបើប្រៀបធៀបនឹងចំនួនថ្នាក់ដឹកនាំក្នុងរយៈពេលប្រាំឆ្នាំ ចំនួន ថ្នាក់ដឹកនាំជាស្ត្រីនៅក្នុងតួនាទីធំៗ គឺនៅមានចំនួនដដែល។

**ក្រាហ្វិកទីពីរ៖ អ្នកដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៧ - ២០២១**




ទោះបីជាយ៉ាងនេះក្តី នៅឆ្នាំ២០១៨ អាណត្តិទីប្រាំនៃរាជរដ្ឋាភិបាលកម្ពុជា (២០១៨ - ២០២៣) ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានតម្លើងតួនាទីស្ត្រីពីររូបជាអនុរដ្ឋលេខាធិការ។

**លទ្ធផលរំពឹងទុកទី២៖ វត្តមាន និងឥទ្ធិពលរបស់ស្ត្រី ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងក្រុមគ្រប់គ្រង ធនធានធម្មជាតិ និងកសិកម្ម មានការកើនឡើង**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងកម្មវិធីអភិវឌ្ឍវិស័យ កសិកម្មបានខិតខំប្រឹងប្រែងឥតឈប់ឈរក្នុងការលើកកម្ពស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច និងការចូលរួមរបស់ស្ត្រី ក្នុងសហគមន៍កសិកម្ម និងក្រុមកសិកម្មដទៃទៀត។ ទោះបីជាយ៉ាងនេះក្តី ចំនួនស្ត្រីជាថ្នាក់ដឹកនាំសហគមន៍កសិកម្ម នៅមានចំនួនតិចជាងបុរសច្រើន ខណៈដែលសមាជិកសហគមន៍ជាស្ត្រីមានចំនួនច្រើនជាងបុរស។

**ក្រាហ្វិកទីបី៖ អ្នកដឹកនាំសហគមន៍កសិកម្ម ២០១៧ – ២០២១**



**លទ្ធផលរំពឹងទុកទី៣៖ ស្ត្រីកាន់តែមានលទ្ធភាពទទួលបានឱកាសអភិវឌ្ឍន៍ជំនាញ និងការសិក្សា ដើម្បីគាំទ្រដល់ការចូលរួមរបស់ពួកគាត់ក្នុងវិស័យកសិកម្ម រួមមានផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ជលផល ព្រៃឈើ និងកៅស៊ូ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលបានសមិទ្ធផលដ៏ធំធេងក្នុងផ្នែកនេះ។ សិក្ខាសាលាបណ្តុះបណ្តាលជាច្រើន ទាំងក្នុង និងក្រៅប្រទេស វគ្គសិក្សាមានសញ្ញាប័ត្រ និងគ្មានសញ្ញាប័ត្រ ត្រូវបានរៀបចំសម្រាប់មន្ត្រីក្រសួង។ តាមរយៈការចូលរួមក្នុងសិក្ខាសាលាដែលបានរៀបចំដោយក្រសួង ដៃគូអភិវឌ្ឍន៍ មន្ត្រីក្រសួងចំនួន៣៣រូប (១រូបជាបុរស) ដែលជាសមាជិក សមាជិកាក្រុមការងារយេនឌ័រ និងកុមារ និងមន្ត្រីសំខាន់ៗដទៃទៀត បានពង្រឹងជំនាញ ទំនុកចិត្ត និងសមត្ថភាពក្នុងការបំពេញការងារគ្រប់គ្រង និងកិច្ចការបច្ចេកទេសរបស់ពួកគាត់។

ការលើកកម្ពស់ស្ត្រីក្នុងតួនាទីខ្ពស់នៅក្នុងគ្រឹះស្ថានអប់រំកសិកម្ម នៅតែជាបញ្ហាប្រឈម។ ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅនេះ ចំនួនស្ត្រីក្នុងតួនាទីដឹកនាំនៅគ្រឹះស្ថានអប់រំកសិកម្មទាំងបីនៅមានចំនួនដដែល មានការផ្លាស់ប្តូរតិចតួចក្នុងតួនាទីទាបៗ និងមានការធ្លាក់ចុះសម្រាប់តួនាទីមួយចំនួន។ នៅសាលាកសិកម្មជាតិព្រែកលៀប និងកំពង់ចាម ចំនួនស្ត្រីក្នុងតួនាទីសំខាន់ៗ នៅមានចំនួនដដែលក្នុងរយៈពេលប្រាំឆ្នាំនេះ។ មានស្ត្រីម្នាក់ត្រូវបានតំឡើងតួនាទីជាសកលវិទ្យាធិការរង ប៉ុន្តែអនុប្រធានការិយាល័យជាស្ត្រីពីររូបត្រូវបានធ្លាក់ចុះ នៅសកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង។

ដូចគ្នានេះដែរ ចំនួនសិស្ស និស្សិតជាស្ត្រីនៅគ្រឹះស្ថានអប់រំកសិកម្មទាំងបី មានការកើនឡើងតិចតួចប៉ុណ្ណោះ ពី៣៤ ភាគរយ នៅឆ្នាំ២០១៧ មក ៣៩ភាគរយនៅឆ្នាំ២០២១។

**ក្រាហ្វិកទីមួយ៖ សិស្ស និស្សិតនៅគ្រឹះស្ថានអប់រំកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**



## ឧបសម្ព័ន្ធទី២ ៖ គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ឆ្នាំ ២០២២-២០២៦

| សកម្មភាពសំខាន់ៗ | អ្នកអនុវត្ត/ការទទួលខុសត្រូវ | សូចនាករ | គោលដៅ | ថវិកា |
|---|---|---|---|---|
| **គោលបំណងទី១: លើកកម្ពស់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈការបង្កើនលទ្ធភាពស្ត្រីក្នុងការទទួលបានទំនិញ សេវា និងលក្ខខណ្ឌនានាប្រកបដោយសមធម៌ សម្រាប់ស្ត្រីក្នុងវិស័យកសិកម្ម** | | | | |
| លទ្ធផលទី១.១៖ ស្ត្រីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបាននូវធាតុចូលកសិកម្ម ហិរញ្ញវត្ថុ និងបច្ចេកវិជ្ជា | | | | |
| ១.១.១. ក្នុងភាពជាដៃគូជាមួយដៃគូពាក់ព័ន្ធដែលបានចូលរួមលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជា និងលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងបុរសឱ្យមានសមធម៌ក្នុងការប្រកបកសិកម្ម និងកម្លាំងពលកម្ម ដោយប្រើប្រាស់អភិក្រមផ្លាស់ប្តូរយេនឌ័រ ដើម្បីដោះស្រាយឧបសគ្គសម្រាប់ស្ត្រី | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | - ភាគរយស្ត្រីនិងបុរសដែលទទួលផលពីកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម<br>- ភាគរយនៃស្ត្រី និងបុរស ដែលបានប្រើប្រាស់ធាតុចូលកសិកម្មកាន់តែប្រសើរ | ស្ត្រីមានយ៉ាងតិច ៤០ - ៥០%នៃក្រុមគោលដៅសរុប | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.១.២. បង្កើតឱកាសកាន់តែប្រសើរឡើងសម្រាប់កសិករជាស្ត្រីក្នុងការចូលរួមនៅតាមសហគមន៍ក្នុងក្របខណ្ឌកសិកម្ម ក្រុមផលិត និងសេវាកម្មផ្សេងៗ ដើម្បីមានលទ្ធភាពទទួលបានសេវាប្រាក់សន្សំ ឥណទាន និងគម្រោងហិរញ្ញវត្ថុដទៃទៀត ឱ្យកាន់តែប្រសើរឡើងទៅតាមតម្រូវការ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ភាគរយស្ត្រី និងបុរសដែលមានលទ្ធភាពទទួលបានសេវាប្រាក់សន្សំ និងឥណទានប្រកបដោយសមធម៌ | ស្ត្រីយ៉ាងតិច ៥០% ទទួលបានសេវាប្រាក់សន្សំ និងឥណទាន | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.១.៣. ក្រសួងសហការជាមួយអ្នកផ្តល់សេវា រួមទាំងក្រុមហ៊ុនលក់ធាតុចូលកសិកម្ម និងអ្នកចែកចាយ ក្នុងការលើកទឹកចិត្តឱ្យពួកគាត់អញ្ជើញស្ត្រី និងបុរសចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ភាគរយស្ត្រី និងបុរសដែលបានចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលាបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា និងទិវាបង្ហាញ | ស្ត្រីមានចំនួន៧០ - ៨០%បានចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| បណ្ដាល ទស្សនកិច្ចសិក្សា ទិវាបង្ហាញបច្ចេកទេសថ្មីៗ ប្រកបដោយសមធម៌ | | | ទស្សនកិច្ចសិក្សា ទិវាបង្ហាញបច្ចេកទេសថ្មីៗ | |
| ១.១.៤. កសាងសមត្ថភាពសហគ្រិនជាស្ត្រីនៅគ្រប់លំដាប់ទាំងអស់នៅក្នុងប្រកបរអាជីវកម្មកសិ-ធុរកិច្ច រួមមានការដាំដុះដំណាំ ព្រៃឈើ ជលផល ការចិញ្ចឹមសត្វ និងសហគ្រាសកែច្នៃកសិផលដោយប្រើប្រាស់អភិក្រមផ្លាស់ប្តូរយេនឌ័រ ដើម្បីដោះស្រាយឧបសគ្គ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ចំនួនសហគ្រិនជាស្ត្រីដែលទទួលបានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល | យ៉ាងតិចសហគ្រិនជាស្ត្រី២០-៣០% ទទួលបានការគាំទ្រអាជីវកម្មពីក្រសួងកសិកម្ម ដៃគូអភិវឌ្ឍន៍ និងអង្គការ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.១.៥. កែលម្អលក្ខខណ្ឌឱ្យមានភាពកាន់តែប្រសើរឡើងសម្រាប់ស្ត្រីជាកម្មករនៅក្នុងខ្សែច្រវាក់តម្លៃកសិកម្ម តាមរយៈការស្រាវជ្រាវ ការផ្តួចផ្តើមគំនិតនានា (កម្មវិធី និងយុទ្ធនាការ) ដែលផ្តោតលើកម្មករ និយោជក និងអ្នករៀបចំគោលនយោបាយ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ការសិក្សា និងការផ្តួចផ្តើមគំនិតនានាត្រូវបានបង្កើតឡើង | យ៉ាងតិចការសិក្សាគំនិតផ្តួចផ្តើមសំខាន់ៗថ្មីចំនួនពីរ (យ៉ាងតិចមួយទាក់ទងនឹងភាគីពាក់ព័ន្ធជាច្រើន) ដោះស្រាយលក្ខខណ្ឌ និងលើកទឹកចិត្តសម្រាប់កម្មករស្ត្រីនៅក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.១.៦.កំណត់គោលនយោបាយជាក់លាក់សម្រាប់ការកែសម្រួលដើម្បីបញ្ចូលយេនឌ័រឱ្យកាន់តែប្រសើរឡើង | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | គោលនយោបាយត្រូវបានកំណត់ និងកែសម្រួលតាមរយៈកិច្ចប្រជុំពិគ្រោះយ៉ាងពេញលេញជាមួយអ្នកពាក់ព័ន្ធ រួមទាំងអង្គការសង្គមស៊ីវិលដែលផ្តោតលើសិទ្ធិស្ត្រី | យ៉ាងតិចគោលនយោបាយសំខាន់ៗពីរត្រូវបានកែសម្រួលដើម្បីគាំទ្រអភិក្រមផ្លាស់ប្តូរយេនឌ័រក្នុងវិស័យកសិកម្ម | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| លទ្ធផលទី១.២ ៖ ស្ត្រីមានលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបាននូវព័ត៌មាន ចំណេះដឹង និងសេវាកម្មជំនាញបច្ចេកទេស ដើម្បីគាំទ្រដល់ការងាររបស់ពួកគាត់ក្នុងវិស័យកសិកម្ម ដូចជាប្រពលវប្ប | | | | |

| | | | | |
|---|---|---|---|---|
| កម្ម ដំណាំនិងការធ្វើពិពិធកម្ម និងកាលានុវត្តភាពដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | | | | |
| ១.២.១ រៀបចំ បណ្តុះបណ្តាល សិក្ខាសាលា ស្តីពីបច្ចេកទេសការដាំដុះដំណាំ ការចិញ្ចឹមសត្វ ផលផល និងកសិ-ឧស្សាហកម្ម ដោយផ្តល់លទ្ធភាពប្រកបដោយសមធម៌សម្រាប់កសិករស្ត្រី និងបុរស | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ភាគរយស្ត្រី ដែលបានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម | យ៉ាងតិច ស្ត្រី ៤០-៥០% បានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និង ២០-៣០% បានប្រើប្រាស់ចំណេះដឹង | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.២.២. ក្នុងភាពជាដៃគូជាមួយក្រុមហ៊ុនលក់ធាតុចូលកសិកម្ម បង្កើត និងគាំទ្រឱ្យស្ត្រី និងបុរសមានលទ្ធភាពចូលរួមប្រកបដោយសមធម៌ក្នុងក្រុមអភិវឌ្ឍកសិកម្ម (ADG) ដោយប្រើប្រាស់បណ្តាញសង្គមដើម្បីសម្របសម្រួលការចែករំលែកចំណេះដឹង ការរៀនសូត្រ និងការសាកសួរព័ត៌មាន | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ចំនួនស្ត្រី និងបុរសដែលបានចូលរួមក្នុងក្រុមអភិវឌ្ឍកសិកម្ម | ចំនួន៣០-៤០% នៃសមាជិកក្រុមអភិវឌ្ឍកសិកម្មជាស្ត្រី | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.២.៣ រៀបចំទស្សនកិច្ចសិក្សា ដោយប្រើប្រាស់អភិក្រមដើម្បីធានាថាស្ត្រី និងបុរសមានលទ្ធភាពចូលរួមប្រកបដោយសមធម៌ និងដោះស្រាយបញ្ហារបស់ស្ត្រី តាមរយៈផ្លាស់ប្តូរទពិសោធន៍ ចែករំលែកចំណេះដឹងនានា | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ភាគរយស្ត្រី ដែលបានចូលរួមទស្សនកិច្ចសិក្សា និងយកបទពិសោធន៍ទៅអនុវត្ត | ស្ត្រីយ៉ាងតិចចំនួន ៣០% បានចូលរួមទស្សនកិច្ចសិក្សា និងបានអនុវត្តបទពិសោធន៍ល្អៗ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.២.៤ បង្កើតខិតប័ណ្ណ និងសម្ភារៈផ្សព្វផ្សាយផ្សេងៗអំពីបច្ចេកវិទ្យាកសិកម្មថ្មីៗ ដែលស្ត្រី និងបុរសអាចទទួលបានប្រកបដោយសមធម៌ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ចំនួនស្ត្រី និងបុរសដែលទទួលបានសម្ភារៈផ្សព្វផ្សាយ | ស្ត្រីយ៉ាងតិច ៣០-៤០%ដែលទទួលបានសម្ភារៈផ្សព្វផ្សាយ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| លទ្ធផលទី ១.៣ ៖ ស្ត្រីមានបណ្តាញកាន់តែរឹងមាំជាមួយនឹងទីផ្សារតាមបែបប្រពៃណី និងទីផ្សារថ្មីៗ | | | | |

| | | | | |
|---|---|---|---|---|
| ១.៣.១. លើកកម្ពស់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធឌីជីថល សម្រាប់ផលិតផលកសិកម្ម ដោយប្រើប្រាស់អភិក្រមផ្លាស់ប្តូរយេនឌ័រ ដើម្បីដោះស្រាយឧបសគ្គសម្រាប់ស្ត្រី | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ចំនួនកសិករជាស្ត្រី និងបុរសដែលមានលទ្ធភាពចូលទៅកាន់ទីផ្សារ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល | កសិករជាស្ត្រីយ៉ាងតិច ២០% មានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថល | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.៣.២.បង្កើតជំនាញបច្ចេកវិទ្យាឌីជីថលសម្រាប់ស្ត្រី និងបុរសដែលប្រកបអាជីវកម្មកសិកម្ម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | - ចំនួនកសិករជាស្ត្រី និងបុរសដែលបានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល<br>- បង្កើតកម្មវិធីស្តីពីបច្ចេកវិទ្យាឌីជីថលរួមបញ្ចូលយុទ្ធសាស្ត្រដោះស្រាយបញ្ហា | - កសិករជាស្ត្រីយ៉ាងតិច២០% បានចូលរួមវគ្គបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.៣.៣. ពង្រឹងសហគមន៍ក្នុងក្របខណ្ឌកសិកម្ម ក្រុមអាជីវកម្មកសិកម្ម ដែលដឹកនាំដោយស្ត្រី ឬមានសមាជិកភាគច្រើនជាស្ត្រីតាមរយៈសេវាកម្មទីផ្សារ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ចំនួនសហគមន៍ក្នុងក្របខណ្ឌកសិកម្ម ក្រុមអាជីវកម្មកសិកម្ម ដែលមានបណ្តាញបញ្ជាទិញ-លក់ច្រើន | យ៉ាងតិច១០-២០% សហគមន៍ក្នុងក្របខ័ណ្ឌកសិកម្ម ក្រុមអាជីវកម្មមានបណ្តាញបញ្ជាទិញ-លក់ច្រើន | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.៣.៤. ផ្សព្វផ្សាយការធ្វើកសិកម្មតាមកិច្ចសន្យាសម្រាប់ផលិតផលកសិកម្ម នៅតាមមូលដ្ឋានប្រកបដោយសមធម៌ ដោយប្រើប្រាស់អភិក្រមផ្លាស់ប្តូរយេនឌ័រ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ចំនួនសហគមន៍ក្នុងក្របខណ្ឌកសិកម្មបានចូលរួមធ្វើកិច្ចសន្យាតាមប្រតិបត្តិការមុខរបរ | យ៉ាងតិច ១០-២០% នៃសហគមន៍ក្នុងក្របខណ្ឌកសិកម្មបានចូលរួមធ្វើកិច្ចសន្យាតាមប្រតិបត្តការមុខរបរទទួលបានវឌ្ឍភាពយេនឌ័រប្រកបដោយសមធម៌ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ១.៣.៥. រៀបចំវេទិកា ឬព្រឹត្តិការណ៍ទំនាក់ទំនងអាជីវកម្មសម្រាប់ស្ត្រី ជាអាជីវករ អ្នកប្រមូលទិញ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ចំនួនស្ត្រី និងបុរសដែលបានចូលរួម និងកិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើ | - ស្ត្រីយ៉ាងតិច ៣០- | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| អ្នកកែច្នៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត និងមានវិធានការចាំបាច់ដើម្បីសម្របសម្រួលដល់ការចូលរួមរបស់ស្ត្រី និងបុរសប្រកបដោយសមធម៌ | | ឡើងដើម្បីធានាឱ្យមានការចូលរួមប្រកបដោយសមធម៌ | ៤០%ចូលរួមវេទិកាទំនាក់ទំនងអាជីវកម្ម<br>-យ៉ាងតិចមាន៤ វេទិកា/ព្រឹត្តិការណ៍ត្រូវបានរៀបចំរៀងរាល់ឆ្នាំ | |
| លទ្ធផលទី១.៤៖ បន្ទុកការងាររបស់ស្ត្រីត្រូវបានកាត់បន្ថយ ហើយការចូលរួមរបស់ពួកគាត់ត្រូវបានទទួលស្គាល់ និងផ្តល់តម្លៃ ច្រើនជាងមុន | | | | |
| ១.៤.១ បញ្ជ្រាបការយល់ដឹងអំពីការបែងចែកបន្ទុកការងារឱ្យមានស្មើគ្នាសម្រាប់ស្ត្រី និងបុរសបញ្ចូលទៅក្នុងសកម្មភាពការងារទាំងអស់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធ | ភាគរយនៃកម្មវិធីផ្សព្វផ្សាយ និងរបាយការណ៍អំពីបញ្ហានៃបន្ទុកការងារ | យ៉ាងតិច៤០% នៃរបាយការណ៍សកម្មភាពលើបញ្ហាបន្ទុកការងារសម្រាប់ស្ត្រី និងការខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាទាំងនេះ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| **គោលបំណងទី២: ពង្រឹងសមត្ថភាព ធនធាន និងការប្តេជ្ញាចិត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធានានូវប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យកសិកម្ម** | | | | |
| លទ្ធផលទី ២.១ : តម្រូវការ និងកង្វល់របស់ស្ត្រីក៏ដូចជាបុរសត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់គោលនយោបាយ លិខិតបទដ្ឋាន និងក្របខ័ណ្ឌច្បាប់ | | | | |
| ២.១.១. ធានាថាគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មដែលបានធ្វើបច្ចុប្បន្នភាពឆ្នាំ២០២២-២០២៦ ត្រូវបានផ្សព្វផ្សាយ តាមរយៈសិក្ខាសាលានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដល់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការប្តេជ្ញាចិត្តអនុវត្តគោលនយោបាយនេះ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | - ចំនួនសិក្ខាសាលាផ្សព្វផ្សាយដែលបានរៀបចំ<br>- គាំទ្រគ្រប់លដាប់ថ្នាក់ក្នុងការអនុវត្ត | យ៉ាងតិចមានសិក្ខាសាលាផ្សព្វផ្សាយចំនួន៤ (មួយនៅថ្នាក់ជាតិ) ត្រូវបានរៀបចំ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| ២.១.២. ពង្រឹងចំណេះដឹងជាមូលដ្ឋាន និងការត្រួតពិនិត្យវឌ្ឍនភាពតាមរយៈការប្រមូលទិន្នន័យ រួមទាំងការវាយតម្លៃយេនឌ័រក្នុងវិស័យកសិកម្ម ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | របាយការណ៍សិក្សាបានផ្សព្វផ្សាយ | យ៉ាងតិចការសិក្សាមួយត្រូវបានធ្វើឡើង | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ២.១.៣. បញ្ចូលបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | គោលនយោបាយ ផែនការ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តរបស់ក្រសួង បានឆ្លើយតបនឹងយេនឌ័រ | យ៉ាងតិច ៣០%នៃគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តរបស់ក្រសួង ឆ្លើយតបនឹងយេនឌ័រ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ២.១.៤. អនុវត្តលទ្ធភាព សិក្សា សាកល្បង បង្កើតទារកដ្ឋាននៅតាមអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | - ចំនួនកន្លែងថែទាំកុមារដែលត្រូវបានសាកល្បង និងបានបង្កើតឡើង<br>-បទពិសោធន៍ត្រូវបានចែករំលែក ជាមូលដ្ឋានសម្រាប់កសាងកន្លែងថែទាំកុមារបន្ថែមទៀត | -យ៉ាងតិចចំនួនទារកដ្ឋានមួយកំពុងប្រតិបត្តិការជោគជ័យ ក្រោមឱវាទក្រសួងទទួលបានជោគជ័យ<br>-គម្រោងសាងសង់បន្ថែមទៀតដោយមានកំណត់ពេលវេលាជាក់លាក់ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ២.១.៥. រៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីថវិកាឆ្លើយតបយេនឌ័រ (GRB) | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | គ្រប់ថវិកាក្រសួងត្រូវឆ្លើយតបយេនឌ័រ | យ៉ាងតិច សិក្ខាសាលាមួយត្រូវបានរៀបចំ | ធនធានក្រសួង ដៃពាក់ព័ន្ធ |
| លទ្ធផលទី២.២៖ ការអនុវត្តសមតាពយេនឌ័រ និងធនធានត្រូវបានពង្រឹង និងបានបញ្ចូលទៅក្នុងការរៀបចំផែនការ ការអនុវត្ត ការតាមដាន និងការវាយតម្លៃលើគ្រប់សកម្មភាព សេវាកម្មបច្ចេកទេស គម្រោង កម្មវិធី និងថវិកា | | | | |

| | | | | |
|---|---|---|---|---|
| ២.២.១. អនុវត្តវាយតម្លៃវឌ្ឍនភាពយេនឌ័រ នៃគម្រោងអភិវឌ្ឍន៍ទាំងអស់ក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីកំណត់សមិទ្ធផល ឧបសគ្គ និងដំណោះស្រាយ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | របាយការណ៍ នៃការវាយតម្លៃ | យ៉ាងតិច មានការវាយតម្លៃមួយអំពីវឌ្ឍនភាព នៃគម្រោងអភិវឌ្ឍន៍ត្រូវបានរៀបចំឡើង | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ២.២.២. បញ្ចូលបញ្ហាយេនឌ័រចូលក្នុងកម្មវិធី ឬការរៀបចំគម្រោង ផែនការ ការអនុវត្ត ការវាយតម្លៃ និងសេវាបច្ចេកទេស | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | គ្រប់កម្មវិធី គម្រោង ទាំងអស់ក្រោមឱវាទក្រសួង គឺឆ្លើយតបនឹងយេនឌ័រ | - គ្រប់កម្មវិធី គម្រោងទាំងអស់បានដាក់បញ្ចូលយេនឌ័រ<br>- យ៉ាងតិចសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានការផ្លាស់ប្តូរយេនឌ័រ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ២.២.៣. ចាត់តាំងមន្ត្រីបង្គោលយេនឌ័រចូលរួមផ្នែកអនុវត្តគ្រប់គម្រោង | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | ចំនួនជនបង្គោលយេនឌ័រក្នុងក្រុមការងារអនុវត្តគម្រោង | យ៉ាងតិច ៨០% នៃមន្ត្រីបង្គោលយេនឌ័រចូលរួមអនុវត្តគម្រោង | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| លទ្ធផលទី២.៣៖ ការវិភាគយេនឌ័រត្រូវបានពង្រឹងតាមរយៈការប្រមូលទិន្នន័យដែលអាចយល់បាន រួមទាំងការបង្កើនទិន្នន័យបែបគុណភាព ការវិភាគ និងការធ្វើរបាយការណ៍ដែលមានទិន្នន័យយេនឌ័រគ្រប់កម្មវិធី និងសកម្មភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | | | |
| ២.៣.១.ពង្រឹងសមត្ថភាពលើការវិភាគយេនឌ័រដល់ក្រុមការងារយេនឌ័រ និងមន្ត្រី ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | ចំនួនសមាជិកក្រុមការងារយេនឌ័រ និងមន្ត្រីរបស់ក្រសួងដែលបានបណ្តុះបណ្តាល | ចំនួនសមាជិកក្រុមការងារយេនឌ័រ ១០០% និងមន្ត្រី៥០%ទទួលបានការបណ្តុះបណ្តាលលើជំនាញការវិភាគយេនឌ័រ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| ២.៣.២. ពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃ ដើម្បីប្រមូលទិន្នន័យបែបគុណភាព បរិមាណ និង ត្រួតពិនិត្យការអនុវត្តគោលនយោបាយ និង ក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | ប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្លើយតបនឹងយេនឌ័រ រួមទាំងការប្រមូលទិន្នន័យបែងចែកភេទ និងបង្កើនការប្រើប្រាស់ទិន្នន័យបែបគុណភាព | - ប្រព័ន្ធតាមដាន និងវាយតម្លៃ ដែលឆ្លើយតបយេនឌ័រ ត្រូវបានបង្កើតឡើង និងដាក់ឱ្យប្រើប្រាស់<br>- ៧០% នៃកម្មវិធីបានប្រមូល និងវិភាគទិន្នន័យយេនឌ័រតាមបែបគុណភាព និងបរិមាណ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ២.៣.៣. រៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការសរសេររបាយការណ៍ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | របាយការការណ៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់ត្រូវមានព័ត៌មានយេនឌ័រ និងការវិភាគ | - យ៉ាងតិចមានសិក្ខាសាលាមួយស្តីពីការបញ្ជ្រាបយេនឌ័រក្នុងការសរសេររបាយការណ៍ត្រូវបានរៀបចំ<br>- យ៉ាងតិច ៧០% នៃរបាយការណ៍ប្រចាំត្រីមាស ឆមាស  និងប្រចាំឆ្នាំ មានព័ត៌មានយេនឌ័រ<br>-  យ៉ាងតិច ៤០% នៃរបាយការណ៍របស់ក្រសួងមានរួមបញ្ចូល | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| | | | ការវិភាគយេនឌ័រ | |
| លទ្ធផលទី២.៤៖ ជំនាញ និងចំណេះដឹងអំពីយេនឌ័រនិងកសិកម្ម ត្រូវបានពង្រឹង រួមទាំងក្រុមការងារយេនឌ័រ មន្ត្រី និងគ្រឹះស្ថានអប់រំកសិកម្ម | | | | |
| ២.៤.១. រៀបចំសិក្ខាសាលាបណ្តុះបណ្តាលជាប្រចាំសម្រាប់ក្រុមការងារយេនឌ័រ មន្ត្រី និងគ្រឹះស្ថានអប់រំកសិកម្ម ស្តីពីយេនឌ័រនិងកសិកម្ម | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | ចំនួនសមាជិកនៃក្រុមការងារយេនឌ័រ មន្ត្រី និងគ្រឹះស្ថានអប់រំកសិកម្ម ដែលបានទទួលការបណ្តុះបណ្តាលអំពីយេនឌ័រ និងកសិកម្ម | - ៣០% នៃមន្ត្រីក្រោមឱវាទក្រសួង និងមន្ត្រីគ្រឹះស្ថានអប់រំកសិកម្មទាំងអស់ទទួលបានវគ្គបណ្តុះបណ្តាល ជារៀងរាល់ឆ្នាំ<br>- ក្រុមការងារបានទទួលការបណ្តុះបណ្តាលរៀងរាល់ឆ្នាំ<br>- ទិន្នន័យអំពីការបណ្តុះបណ្តាលទាំងអស់ត្រូវបានប្រមូលនិងចងក្រង | ធនធានក្រសួងដៃគូពាក់ព័ន្ធ |
| ២.៤.២. រៀបចំសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់មន្ត្រីសំខាន់ៗនៃគ្រឹះស្ថានអប់រំកសិកម្ម ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីសិក្សា | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | ចំនួនមន្ត្រីសំខាន់ៗនៃគ្រឹះស្ថានអប់រំកសិកម្ម និងក្រុមការងារយេនឌ័រមានចំណេះដឹងអំពីការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីបណ្តុះបណ្តាលកសិកម្ម | ៦០% នៃមន្ត្រីសំខាន់ៗនៃគ្រឹះស្ថានអប់រំកសិកម្មទទួលបានការបណ្តុះបណ្តាល | ធនធានក្រសួងដៃគូពាក់ព័ន្ធ |
| ២.៤.៣. គាំទ្រគ្រឹះស្ថានអប់រំកសិកម្មកែសម្រួលដាក់បញ្ចូលទស្សនទានយេនឌ័រទៅក្នុងកម្មវិធីបណ្តុះបណ្តាល | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | ចំនួនកម្មវិធីបណ្តុះបណ្តាលកសិកម្មឆ្លើយតបនឹងយេនឌ័រ | យ៉ាងតិច កម្មវិធីបណ្តុះបណ្តាលមួយបានបញ្ជ្រាបយេនឌ័រយ៉ាងពេញលេញ | ធនធានក្រសួងដៃគូពាក់ព័ន្ធ |

| គោលបំណងទី៣៖ បង្កើតភាពជាតំណាង និងការចូលរួមស្មើភាពគ្នាទាំងស្ត្រី និងបុរសក្នុងវិស័យកសិកម្ម | | | | |
|---|---|---|---|---|
| លទ្ធផលទី៣.១៖ វត្តមាន និងឥទ្ធិពលរបស់ស្ត្រីក្នុងដំណើរការសម្រេចចិត្តនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការកើនឡើង | | | | |
| ៣.១.១. បង្កើនភាពជាតំណាងរបស់ស្ត្រីនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅគ្រប់កម្រិតនិងគ្រប់តួនាទី | ក្រុមការងារយេនឌ័រ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ចំនួនភាពជាតំណាងរបស់ស្ត្រីនៅក្រោមឱវាទក្រសួងមានការកើនឡើង | - ភាពជាតំណាងរបស់ស្ត្រីមានការកើនឡើងពី២៥-៣០%<br>- យ៉ាងតិចមានគំនិតផ្តួចផ្តើមបីសំខាន់ៗក្នុងការបង្កើនតំណាងរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច និងតួនាទីបច្ចេកទេស | ធនធានក្រសួងដៃគូពាក់ព័ន្ធ |
| ៣.១.២. អនុវត្តគំនិតផ្តួចផ្តើមលើកកម្ពស់ស្ត្រី រួមទាំងការផលិត និងផ្សព្វផ្សាយករណីសិក្សាល្អៗអំពីស្ត្រីនៅក្នុងតួនាទីធ្វើសេចក្តីសម្រេច និងបច្ចេកទេសក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារយេនឌ័រ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ចំនួនករណីសិក្សាអំពីតួនាទីរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត | យ៉ាងតិចករណីសិក្សាពីរត្រូវបានបង្កើត និងផ្សព្វផ្សាយរៀងរាល់ឆ្នាំ និងប្រើប្រាស់ដើម្បីផ្តល់ព័ត៌មាន និងលើកកម្ពស់ស្ត្រីនៅក្រោមឱវាទក្រសួង | ធនធានក្រសួងដៃគូពាក់ព័ន្ធ |
| ៣.១.៣. អនុវត្តគំនិតផ្តួចផ្តើមដើម្បីលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបទ និងវប្បធម៌ចំពោះស្ត្រី និងសមភាពយេនឌ័រនៅក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារយេនឌ័រ អង្គភាពក្រោមឱវាទ ថ្នាក់ដឹកនាំ និងប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយអង្គការសិទ្ធស្ត្រី | បង្កើនការយល់ដឹងអំពីផលប្រយោជន៍ និងឧបសគ្គក្នុងការបង្កើនមុខតំណែង និងកិច្ចការបច្ចេកទេស | យ៉ាងតិចមានគំនិតផ្តួចផ្តើមពីរត្រូវបានធ្វើឡើង | ធនធានក្រសួងដៃគូពាក់ព័ន្ធ |

| លទ្ធផលទី៣.២៖ វត្តមាន និងឥទ្ធិពលរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត នៅក្នុងសហគមន៍ក្នុងក្របខណ្ឌកសិកម្ម និងការបម្រែបម្រួលអាកាសធាតុមានការកើនឡើង | | | | |
|---|---|---|---|---|
| ៣.២.១. សហការជាមួយអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើនភាពជាតំណាងស្ត្រីក្នុងសហគមន៍ក្នុងក្របខណ្ឌកសិកម្ម ព្រៃឈើ ជលផល កៅស៊ូ និងការចិញ្ចឹមសត្វ រួមទាំងកម្រិតថ្នាក់ដឹកនាំដើម្បីដោះស្រាយបញ្ហាប្រឈម និងឧបសគ្គយេនឌ័រ | ក្រុមការងារយេនឌ័រ អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន | ចំនួនជាតំណាងរបស់ស្ត្រីនៅក្នុងក្រុមធ្វើអាជីវកម្មកសិកម្មរួមគ្នា និងតាមអនុវិស័យមានកើនឡើង រួមទាំងនៅកម្រិតថ្នាក់ដឹកនាំ | ភាពជាតំណាងរបស់ស្ត្រីក្នុងសហគមន៍កសិកម្ម ព្រៃឈើ ជលផល កៅស៊ូ និងការចិញ្ចឹមសត្វ មានការកើនឡើងពី១៥-២០ % | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ៣.២.២. បង្កើនចំនួនស្ត្រីនៅគ្រប់ដំណើរការនៃការរៀបចំផែនការ ការគ្រប់គ្រងធាតុចូលកសិកម្ម និងក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម | ក្រុមការងារយេនឌ័រ អង្គភាពពាក់ព័ន្ធ | របាយការណ៍វឌ្ឍនភាព | យ៉ាងតិច៤០% នៃស្ត្រីបានចូលរួមគ្រប់ដំណើរការ និងការអនុវត្តសកម្មភាពការងារក្នុងសហគមន៍ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ៣.២.៣. បង្កើនការចូលរួមស្មើភាពគ្នា តាមរយៈការផ្សព្វផ្សាយករណីសិក្សាអំពីភាពជោគជ័យរបស់ស្ត្រីក្នុងសហគមន៍ក្នុងក្របខណ្ឌកសិកម្ម តាមប្រព័ន្ធផ្សព្វផ្សាយ | ក្រុមការងារយេនឌ័រ និងប្រព័ន្ធផ្សព្វផ្សាយ | ចំនួនករណីសិក្សាល្អៗត្រូវបានបង្កើត | -យ៉ាងតិច ១០ ករណីសិក្សា បានបង្កើតឡើង ផ្សព្វផ្សាយ និងប្រើប្រាស់ដើម្បីបង្កើនការយល់ដឹងពីការចំណេះដឹង ផលប្រយោជន៍ និងឧបសគ្គនៃការចូលរួមរបស់ស្ត្រី<br>-គំនិតផ្តួចផ្តើមថ្មីៗ ត្រូវបានបង្កើតឡើងដោយផ្អែកលើការរៀនសូត្រ | ធនធានក្រសួង ដៃពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| ៣.២.៤. សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីផ្តល់ព័ត៌មានសាធារណៈដែលទាក់ទងនិងវិស័យកសិកម្ម ដូចជាគោលការណ៍ណែនាំការធ្វើផលិតកម្ម កសិកម្មតាមកិច្ចសន្យាដល់ប្រជាជន ជាពិសេសស្ត្រីមេគ្រួសារ | ក្រុមការងារយេនឌ័រ និងដៃគូពាក់ព័ន្ធ | ភាគរយនៃស្ត្រីមេគ្រួសារ ទទួលបានព័ត៌មានសាធារណៈ | កសិករជាពិសេសស្ត្រីមេគ្រួសារយ៉ាងតិច ២០%ទទួលបានព័ត៌មានជាសាធារណៈ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| លទ្ធផលទី៣.៣៖ ស្ត្រីកាន់តែមានលទ្ធភាពទទួលបានឱកាសអភិវឌ្ឍន៍ជំនាញ និងការសិក្សា ដើម្បីគាំទ្រដល់ការចូលរួមរបស់ពួកគាត់ក្នុងវិស័យកសិកម្ម រួមមានផលិតកម្មដំណាំ ការចិញ្ចឹមសត្វ ជលផល ព្រៃឈើ និងកៅស៊ូ | | | | |
| ៣.៣.១. បង្កើនឱកាសសម្រាប់មន្ត្រីរាជការជាស្ត្រីក្នុងការចូលរួមវគ្គបណ្តុះបណ្តាល/សិក្ខាសាលាក្នុង និងក្រៅប្រទេស រួមទាំងនៅក្នុងជំនាញដែលមិនមែនជាប្រពៃណី | ក្រុមការងារយេនឌ័រ អង្គភាពពាក់ព័ន្ធ ថ្នាក់ដឹកនាំ និងការប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួង | របាយការណ៍បណ្តុះបណ្តាលនិមួយៗ | -ស្ត្រីបានចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសមានការកើនឡើងពី៣៨-៤៥ %<br>- ស្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសមានការកើនឡើងពី ២៤-៣៥ %<br>- ព័ត៌មានលម្អិតអំពីវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសត្រូវបានប្រមូល | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ៣.៣.២. ផ្តល់អាហារូបករណ៍ដល់និស្សិតស្ត្រីដើម្បីចូលរៀននៅសកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងកំពង់ចាម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាក់ព័ន្ធ និងថ្នាក់ដឹកនាំ | ចំនួននិស្សិតស្ត្រីដែលបានទទួលអាហារូបករណ៍ | និស្សិតស្ត្រី ៥០% នៃនិស្សិតទាំងអស់ជ្រើសរើសតាមកម្រិតនិទ្ទេសទទួលបានអាហារូបករណ៍ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| | | | ពីសកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងកំពង់ចាម | |
| ៣.៣.៣. បង្កើតគំនិតផ្តួចផ្តើមដើម្បីផ្តល់អាទិភាពក្នុងប្រឡងជ្រើសរើសបេក្ខជនជាស្ត្រី សម្រាប់ចូលបម្រើក្របខ័ណ្ឌមន្ត្រីរាជក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមុខងារសាធារណៈ និងអង្គភាពជំនាញ | ចំនួននៃគំនិតផ្តួចផ្តើមដែលបានធ្វើឡើងដើម្បីបង្កើនភាគរយនៃបេក្ខជនជាស្ត្រី | យ៉ាងតិចបេក្ខជនជាស្ត្រីចំនួន៥០%ទទួលបានអាទិភាពប្រលងចូលក្របខ័ណ្ឌ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| គោលបំណងទី៤ ៖ បង្កើនកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដៃគូអភិវឌ្ឍន៍ អង្គការ និងវិស័យឯកជន) ក្នុងវិស័យកសិកម្ម និងជាមួយអ្នកពាក់ព័ន្ធក្នុងការងារបម្រែបម្រួលអាកាសធាតុ | | | | |
| លទ្ធផលទី៤.១៖ ដៃគូពាក់ព័ន្ធបានដាក់បញ្ចូលយេនឌ័រទៅគ្រប់កម្មវិធី គម្រោងដែលស្របគ្នាជាមួយគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រ | | | | |
| ៤.១.១. បញ្ចូលផែនការសកម្មភាពរបស់គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មទៅក្នុងគម្រោងអភិវឌ្ឍន៍វិស័យកសិកម្ម និងដៃគូអភិវឌ្ឍន៍ អង្គការ និងគម្រោងក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រុមការងារយេនឌ័រ អង្គភាពពាក់ព័ន្ធ ថ្នាក់ដឹកនាំ និងក្រសួង | ចំនួនគម្រោងរបស់ដៃគូពាក់ព័ន្ធដែលមានផែនការត្រូវមានសកម្មភាពបញ្ជ្រាបយេនឌ័រ | គម្រោងដៃគូយ៉ាងតិច ១៥- ២០% មានផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| លទ្ធផលទី៤.២ ៖ អ្នកពាក់ព័ន្ធនានាមានឱកាសច្រើនជាងមុនក្នុងការលើកឡើង និងពិភាក្សាពីបញ្ហាយេនឌ័រ បទពិសោធន៍ និងសមិទ្ធិផលនានាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | | | |
| ៤.២.១. បង្កើនកិច្ចសម្របសម្រួល និងចែករំលែកចំណេះដឹងតាមរយៈ ការប្រជុំ/វេទិកា ជាមួយដៃគូអភិវឌ្ឍ អង្គការ និងដៃគូពាក់ព័ន្ធដទៃទៀត ដើម្បីចែករំលែកវឌ្ឍនភាពពីភាគហ្សាបញ្ហាយេនឌ័រក្នុង | ក្រុមការងារយេនឌ័រ ដៃគូពាក់ព័ន្ធ | ចំនួនកិច្ចប្រជុំបានធ្វើឡើងជាទៀងទាត់ដោយមានការចូលរួមយ៉ាងសកម្មពី ដៃគូពាក់ព័ន្ធ | យ៉ាងតិចមានកិច្ចប្រជុំពីរដងក្នុងមួយឆ្នាំ និងមានការចូលរួមយ៉ាងសកម្មភាពដៃគូពាក់ព័ន្ធ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| វិស័យកសិកម្មនិងស្វែងរកដំណោះស្រាយ | | | | |
| ៤.២.២. បង្កើនកិច្ចសម្របសម្រួល និងចែករំលែកចំណេះដឹងនៅក្នុងក្រុមការងារយេនឌ័រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈកិច្ចប្រជុំ សិក្ខាសាលាប្រចាំឆ្នាំ | ក្រុមការងារយេនឌ័រ ដៃគូពាក់ព័ន្ធ | របាយការណ៍ប្រជុំប្រចាំឆ្នាំ និងការផ្តល់ចម្លើយតបប្រកបដោយវិជ្ជមានក្នុងកិច្ចប្រជុំប្រចាំឆ្នាំ | យ៉ាងតិចមានកិច្ចប្រជុំមួយត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ៨០%នៃរបាយការណ៍របស់ក្រុមការងារយេនឌ័រដែលបង្ហាញពីបទពិសោធន៍វិជ្ជមានការរៀនសូត្រ និងបង្កើនកិច្ចសម្របសម្រួលដែលជាលទ្ធផលពីកិច្ចប្រជុំប្រចាំឆ្នាំ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |
| ៤.២.៣. រៀបចំទស្សនកិច្ចសិក្សាសម្រាប់ក្រុមការងារយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរៀនសូត្រពីកម្មវិធីរបស់អង្គការដៃគូពាក់ព័ន្ធដែលទទួលបានជោគជ័យក្នុងការកម្ពស់ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី | ក្រុមការងារយេនឌ័រ ដៃគូពាក់ព័ន្ធ | ចំនួនទស្សនកិច្ចសិក្សា | យ៉ាងតិចមានទស្សនកិច្ចសិក្សាមួយត្រូវបានរៀបចំរៀងរាល់ឆ្នាំ | ធនធានក្រសួង ដៃគូពាក់ព័ន្ធ |

## ឧបសម្ព័ន្ធ៣ ៖ ឯកសារយោង


Ministry of Women's Affairs, *Cambodia Gender Assessment, Policy Brief 10, Gender and Climate Change*, 2014.

http://www.oxfamamerica.org/explore/stories/mechanical-advantage/ - Rice Weeder (Niek Srer - Rice Dragon). Increase Yield 1 Ton/Ha & Save time and labour 80%. Oxfam supported RACHANA in designing and testing the mechanical weeder.

Cambodia: Gender in agriculture Assessment, World Bank, 2014. (Preliminary draft)

Cambodia: Gender in agriculture Assessment, World Bank, 2014. (Preliminary Draft)

National Gender Profile of Agriculture Households, Food and Agriculture Organization of the United Nations-National Institute of Statistics, Ministry of Planning, Cambodia, 2010.

National Gender Profile of Agriculture Households, Food and Agriculture Organization of the United Nations-National Institute of Statistics, Ministry of Planning,

Cambodia: Gender in agriculture Assessment, World Bank, 2014. (Preliminary Draft)

National Gender Profile of Agriculture Households, Food and Agriculture Organization of the United Nations-National Institute of Statistics, Ministry of Planning, Cambodia, 2010.

Gender in Agriculture Source Book, World Bank, IFAD, 2009.

Report of the Socio-economic survey 2019-2020 (NIS-MoP)

MAFF, *Gender Mainstreaming Policy and Strategic Framework in Agriculture 2016 – 2020*

DFAT, 2020-2021 *Cambodia Development Program Progress Report*, 2021,

Gavalyugova, Dimitria & Cunningham, Wendy, *Gender Analysis of the Cambodian Labor Market,* World Bank, 2021

Huot, Sovanneary and Jensen, Leif, *Gender implications of COVID-19 in Cambodia*, in Castellanos, Paige, Sachs, Carolyn E. and Tickamyer, Ann R., eds. *Gender, Food and COVID-19: Global Stories of Harm and Hope*, Routledge, 2022

NIS, *Cambodia Inter-Censal Agriculture Survey 2019 (CIAS19) Final Report,* National Institute of Statistics, Ministry of Planning and Ministry of Agriculture, Forestry and Fisheries, 2019

NIS, *Women and Men in Cambodia: Facts and Figures 2018*, National Institute of Statistics, Ministry of Planning, Phnom Penh, 2018

OECD, *Strengthening Women's Entrepreneurship in Agriculture in ASEAN Countries*, 2021

Oxfam Cambodia 2020. The impact of COVID-19 on Cambodia's most vulnerable populations, 2020

MAFF, *Annual Report 2018-2019 and Direction 2019-2020*, MAFF Conference report 2019

Sok Piseth, Yang Monyoudom, Houn Tynarath *Cambodia's Agri-Food Trade: Structure, New Emerging Potentials, Challenges & Impacts of Covid-19,* Research Paper 5, November 2021 https://www.canr.msu.edu/prci/publications/Research-Papers/PRCI-Research_Paper_5_Cambodia.pdf

Tanyag, Maria and True, Jacqui, *Gender responsive alternatives to climate change: a country report on Cambodia,* Monash Gender, Peace and Security, Monash University, 2018

UN Women and CDRI, *State of Gender Equality and Climate Change in Cambodia*, 2021

UNDP, *The Next Frontier: Human Development and the Anthropocene, Briefing note for countries on the 2020 Human Development Report:* Cambodia, 2020, http://hdr.undp.org/sites/default/files/Country-Profiles/KHM.pdf

UNIDO, *Policy Assessment for the Economic Empowerment of Women in Green Industry Executive Summary: Cambodia*, 2020

UNSDG, *Stepping in: Women prepare for natural disasters*, United Nations Sustainable Development Group, 18 February 2020, https://unsdg.un.org/latest/stories/stepping-women-prepare-natural-disasters